សាលាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de droit et sciences Economiques
Rayal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ស្រាវជ្រាវចាប់ពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ ដល់ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២១

ស្រាវជ្រាវដោយនិស្សិតឈ្មោះ
លោក : **ខាន់ សុខា**
កញ្ញា : **សខ ហ៊ីង**
ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២១

សាស្ត្រាចារ្យណែនាំ
លោក **ហ៊ីង គីមឡេង**

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទ **ខាន់ សុខា** និងនាងខ្ញុំ **សន ហ៊ីង** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី១៧ ឆ្នាំសិក្សា២០១៧-២០២១ ។ សូមគោរពថ្លែងអំណរអរគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅ និងមិនអាចបំភ្លេចបានជូនចំពោះ៖

**អ្នកមានគុណទាំងពីរ** របស់យើងខ្ញុំទាំងពីរនាក់ ដែលបានផ្ដល់កំណើតចិញ្ចឹមបីបាច់ថែរក្សា តាំងពីតូចរហូតដល់ធំ ព្រមទាំងផ្ដល់នូវក្ដីស្រលាញ់ និងការអប់រំទូន្មានប្រដៅកូនៗប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងជម្រុញ និងលើកទឹកចិត្តក្នុងការបញ្ជូនកូនៗទៅទទួលការអប់រំ មិនតែប៉ុណ្ណោះតែងតែផ្ដល់នូវការផ្គត់ផ្គង់គ្រប់បែបយ៉ាង ទាំងផ្នែកសម្ភារៈសិក្សា និងខាងស្មារតី រហូតយើងខ្ញុំទាំងពីរនាក់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះ។ មិនតែប៉ុណ្ណោះ អរគុណដល់បងប្អូន ប្រុស-ស្រី ដែលតែងតែផ្ដល់ការឧបត្ថម្ភបន្ថែមទាំងផ្នែកសម្ភារៈ និងស្មារតី ព្រមទាំងផ្ដល់នូវការទំនុកបម្រុង មើលថែទាំអស់រយៈពេលបួនឆ្នាំកន្លងមកនេះនៅទីក្រុងភ្នំពេញ។

**រាជរដ្ឋាភិបាល ក្រសួងអប់រំ និងឯកឧត្តមសាកលវិទ្យាធិការ ឯកឧត្តមសាកលវិទ្យាធិការរង ព្រមទាំងសាស្ត្រាចារ្យគ្រប់ៗរូប** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំពង្រឹងវិស័យ អប់រំ ផ្ដល់ការអប់រំ ព្រមទាំងឱកាសក្នុងការទទួលបានការអប់រំ និងបង្ហាត់បង្រៀនដោយស្មោះអស់ពីកម្លាំងកាយចិត្ត ក្នុងការផ្ដល់ និងផ្ទេរនូវពុទ្ធិ ដើម្បីឲ្យយើងខ្ញុំបានក្រេបយកនូវចំណេះដឹងទាំងនេះ ។

លោកសាស្ត្រាចារ្យ **ហ៊ីង គឹមឡេង** ដែលជាសាស្ត្រាចារ្យដឹកនាំការស្រាវជ្រាវ និងរៀបចំសារណានេះឲ្យចេញជារូបរាងឡើង ជាពិសេស ចំពោះការខិតខំប្រឹងប្រែង ជួយពន្យល់ណែនាំ យ៉ាងយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្ត ដល់យើងខ្ញុំដោយផ្ដល់នូវចំណេះដឹង និងបទពិសោធន៍ ដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន តាមរយៈ ការផ្ដល់ឯកសារ មតិយោបល់រិះគន់ដើម្បីស្ថាបនា រហូតដល់សារណានេះត្រូវបញ្ចប់ដោយមានន័យ និងខ្លឹមសារ ។

យើងខ្ញុំទាំងពីរនាក់ សូមគោរពជូនដល់ **លោកអ្នកមានគុណទាំងពីរ ឯកឧត្តម សាស្ត្រាចារ្យ សិស្សច្បង និងបងប្អូនប្រុស-ស្រី មិត្តអ្នកអាន** ទាំងអស់ ឲ្យជួបតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

សៀវភៅសារណាស្តីពី " **នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**" ដែលយើងខ្ញុំបានរៀបចំចងក្រងជាសៀវភៅនេះឡើគឺដើម្បីធ្វើការវាស់ស្ទង់សមត្ថភាពរបស់យើងខ្ញុំ ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ អស់ រយៈពេលបួនឆ្នាំ កន្លងមកនេះ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

មូលហេតុដែលក្រុមយើងខ្ញុំលើកយកនូវប្រធានបទសារណានេះឡើង ដោយហេតុថា មានបញ្ហាជាច្រើន បានចោទឡើង ចំពោះការធ្វើកិច្ចសន្យាលក់ទិញអចលនវត្ថុនេះ ដោយកិច្ចសន្យាលក់ទិញ ត្រូវបានបង្កើតឡើងតែខាងភាគីអ្នកលក់ និងភាគីអ្នកទិញ ដោយពុំមានការចុះបញ្ជី និងផ្ទេរសិទ្ធិឲ្យបានត្រឹមត្រូវតាមច្បាប់ ឬពុំបានយល់ដឹងអំពីនីតិវិធីច្បាប់ច្បាស់លាស់នោះទេ។ ជាទូទៅការទិញលក់មានទម្រង់ និងរូបភាពខុសៗគ្នា ដែលសកម្មភាពបែបនេះកើតឡើងនៅគ្រប់ទីកន្លែងក្នុងជីវភាពប្រចាំថ្ងៃមានដូចជាៈ ការប្រកបអាជីវកម្មនានា និងការដោះដូរទំនិញ និងសេវាកម្មផ្សេងៗ។ ដោយសារតែកត្តានៃការមិនបានយល់ដឹងច្បាស់លាស់អំពីការចុះកិច្ចសន្យាទិញលក់នេះហើយ ទើបជាមូលហេតុធ្វើឲ្យមានផលប៉ះពាល់យ៉ាងខ្លាំង ដល់ផលប្រយោជន៍របស់ភាគីទាំងសងខាង ជាពិសេសនោះគឺប៉ះពាល់ យ៉ាងខ្លាំងដល់ផលប្រយោជន៍ភាគីអ្នកទិញ ព្រោះភាគីអ្នកទិញពុំមែនជាម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុ និងពុំមាន ប័ណ្ណកាន់កាប់នោះដែរ។ ម្យ៉ាងទៀតការធ្វើអន្តរាគមន៍ទៅលើការចុះកិច្ចសន្យាទិញលក់អចលនវត្ថុនេះទៀតសោត ក៏ពុំទាន់មានភាពត្រឹមត្រូវនៅឡើយនោះដែរ ព្រោះការទិញលក់ដែលបានធ្វើកន្លងមកខ្លះធ្វើការទិញលក់ដោយគ្រាន់តែធ្វើការដោះដូរនូវទំនិញរវាងគ្នា និងគ្នា តែប៉ុណ្ណោះ ដោយពុំបានធ្វើការដោះដូរដោយមានការផ្ទេរកម្មសិទ្ធិត្រឹមត្រូវចំពោះមុខមន្ត្រីអនុវត្តច្បាប់ឡើយ ពោលគឺមានការដឹងឮត្រឹមតែចំពោះភាគីតែប៉ុណ្ណោះ ។ កត្តាទាំងអស់នេះហើយ ជាហេតុនាំឲ្យកិច្ចសន្យាទិញលក់អចលវត្ថុមានបញ្ហានៅពេលណាមួយ ក្រោយពីចុះកិច្ចសន្យាលក់ទិញរួចនៅក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ន ។ ដោយសម្លឹងឃើញពីបញ្ហាទាំងអស់នេះហើយទើបបានជាយើងខ្ញុំទាំងពីរនាក់ សម្រេចចិត្តជ្រើសរើសយកនូវប្រធានបទនេះឡើង មកសិក្សាស្រាវជ្រាវ ដើម្បីយកស្នាដៃនេះចងក្រងជាឯកសារជំនួយស្មារតីដល់ប្រជាពលរដ្ឋខ្មែរ និងជាជំនួយដល់ការសិក្សាស្រាវជ្រាវរបស់សិស្សច្បង សិស្សប្អូន និងនិស្សិតជំនាន់ក្រោយៗទៀត។

ទន្ទឹមនឹងនេះ យើងខ្ញុំទាំងពីរនាក់នៅតែមានភាពជឿជាក់ថា ទោះបីជាមានការខិតខំរៀបរៀង និងពិនិត្យយ៉ាងលំអិត ប្រកបទៅដោយភាពយកចិត្តទុកដាក់ទៅលើសារណាមួយក្បាលនេះ យ៉ាងណាក៏ដោយ ក៏នៅតែមានចន្លោះខ្វះខាតទាំងផ្នែកអត្ថរស និងអក្ខរាវិរុទ្ធដោយអចេតនា ជាក់ជាពុំខាន ។ យើងខ្ញុំទាំងពីរនាក់សូមខន្តីអភ័យទោសទុកជាមុននូវរាល់កំហុសឆ្គងដោយអចេតនា ហើយយើងខ្ញុំទទួលនូវរាល់ការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់សាស្ត្រាចារ្យ និងនិស្សិតទាំងអស់គ្រប់មជ្ឈដ្ឋាន។

# មាតិកា

ទំព័រ

**បញ្ជីរាយនាមឧបសម្ព័ន្ធ** ........ V

**បញ្ជីរាយនាមពាក្យកាត់** ........ VI

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**ការសិក្សាលិខិតបទដ្ឋានគតិយុត្ត និងទ្រឹស្តីដែលពាក់ព័ន្ធនឹងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

**ផ្នែកទី១ សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ........ ៣

១.១.និយមន័យ ........ ៣

១.២.គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ៤

១.៣.គោលការណ៍ទទួលខុសត្រូវរបស់តុលាការ ........ ៥

១.៤. គោលការណ៍ចំពោះមុខ ........ ៦

១.៥.គោលការណ៍អសាធារណៈ ........ ៦

១.៦. សិទ្ធិអំណាចតុលាការ និងភាគី ........ ៦

២.៧. ភាសាដែលប្រើក្នុងតុលាការ និងសិទ្ធិទាមទារឲ្យមានការបកប្រែភាសារបស់ភាគី ........ ១៣

១.៨. ការពិនិត្យ និងបញ្ជូនពាក្យបណ្តឹង ........ ១៣

**ផ្នែកទី២ ការចាប់ផ្តើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល** ........ ១៤

២.១.ការកំណត់កាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ១៤

២.២.ការប្តូរកាលបរិច្ឆេទ ........ ១៥

២.៣. ការបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ........ ១៥

២.៤.ការកោះហៅ ........ ១៦

២.៥.ការសាកល្បងផ្សះផ្សា ........ ១៦

២.៦.ការធ្វើសេចក្តីថ្លែងការណ៍របស់ភាគី ........ ១៧

២.៦.១. ការធ្វើសេចក្តីថ្លែងការណ៍របស់ដើមចោទ ........................................................ ១៧

២.៦.២.ការធ្វើសេចក្តីថ្លែងការណ៍របស់ចុងចម្លើយ........................................................ ១៨

២.៧.ការដាក់មធ្យោបាយតទល់ ឬការពារខ្លួន............................................................... ១៩

២.៨.ការកំណត់ចំណុចវិវាទ .......................................................................................... ២២

២.៨.១.ការអះអាងរបស់ភាគី ........................................................................................ ២២

២.៨.២.ការរៀបចំចំណុចវិវាទ ........................................................................................ ២៣

២.៩.ការរៀបចំភស្តុតាង និងការពិនិត្យភស្តុតាងជាឯកសារ ........................................... ២៣

២.៩.១ ការរៀបចំភស្តុតាង ............................................................................................ ២៣

២.៩.២.ការពិនិត្យភស្តុតាងជាឯកសារ........................................................................... ២៤

២.១០.ការបំបែក និង ការរួមបញ្ចូលរឿងក្តី នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ............... ២៥

២.១១.ការធ្វើកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល.......................................... ២៥

២.១១.១.កំណត់ហេតុនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ............................................... ២៥

២.១១.២.ការសម្រេចអំពីការប្តឹងតវ៉ានឹងកំណត់ហេតុ.......................................................... ២៧

**ផ្នែកទី៣ ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**.............................................. ២៧

៣.១.ការមកដល់ពេលនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ................................ ២៧

៣.១.១.គោលបំណងត្រូវបានបំពេញ ............................................................................. ២៧

៣.១.២.គោលបំណងមិនទាន់បានបំពេញ ........................................................................ ២៨

៣.២.សកម្មភាពដែលត្រូវបានបំពេញនៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល............ ៣១

៣.២.១. ការបញ្ជាក់ពីអង្គហេតុដែលត្រូវធ្វើការបំភ្លឺ............................................................ ៣១

៣.២.២.ការកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ........................................ ៣១

៣.៣.អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........................................ ៣២

៣.៣.១.ការលើកចោលមធ្យោបាយតទល់ ឬការពារខ្លួន ....................................................... ៣២

៣.៣.២.ករណីលើកលែង................................................................................................ ៣២

## ជំពូកទី២

## ការរកឃើញលើការអនុវត្តជាក់ស្តែងក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផល

**ផ្នែកទី១.ការចាប់ផ្ដើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**......................................៣៤
១.១.ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល.......................................៣៤
១.២.ការស្នើសុំលើកពេលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល...............................................៣៥
១.៣.ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ ..........................................................................................៣៦
១.៤.ការកោះហៅ............................................................................................................................៣៦
**ផ្នែកទី២ ដំណើរការសកម្មភាពនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**................ ៣៧
២.១.ការផ្សះផ្សា...............................................................................................................................៣៧
២.២.ការធ្វើសេចក្ដីថ្លែងការណ៍របស់ភាគី.........................................................................................៣៨
២.២.១ ការធ្វើសេចក្ដីថ្លែងការណ៍របស់ដើមចោទ ...........................................................................៣៨
២.២.២.ការធ្វើសេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ ..........................................................................៣៨
២.៣.ការរៀបចំចំណុចវិវាទ...............................................................................................................៣៨
២.៣.១.ការរៀបចំការអះអាងរបស់ភាគី................................................................................................៣៩
១.៣.២.ការកំណត់ចំណុចវិវាទ ...........................................................................................................៣៩
២.៤.ការស្នើសុំឲ្យពិនិត្យភស្តុតាងដោយភាគី .....................................................................................៣៩
២.៥.ការធ្វើកំណត់ហេតុនីតិវិធីត្រៀមសម្រាប់ការទាញហេតផល.........................................................៤០
**ផ្នែកទី៣ ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**......................................... ៤១
៣.១.ការបញ្ជាក់អំពីអង្គហេតុដែលត្រូវធ្វើការបំភ្លឺ........................................................................ ៤១
៣.២.ការកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ............................................ ៤១

## ជំពូកទី៣

## ការវិភាគប្រៀបធៀបរវាងការអនុវត្តជាក់ស្ដែងដែលរកឃើញជាមួយនឹងទ្រឹស្ដីគតិយុត្ត ដែលពាក់ព័ន្ធ

**ផ្នែកទី១ ចំណុចស្របគ្នាជាមួយលិខិតតូបករណ៍គតិយុត្ត និងការអនុវត្តជាក់ស្ដែង**.......៤៣
១.១.ការធ្វើសេចក្ដីថ្លែងការរបស់ភាគី ..........................................................................................៤៣
១.២.ការកំណត់ចំណុចវិវាទ ............................................................................................................៤៤
១.៣.ការរៀបចំភស្តុតាង ..................................................................................................................៤៥

១.៤.ការធ្វើកំណត់ហេតុរបស់ក្រឡាបញ្ជី ....................................................................................................៤៦
**ផ្នែកទី២ ចំណុចដែលមិនទាន់អនុវត្តបានពេញលេញតាមស្មារតីច្បាប់**....................... ៤៦
១.១.ការកំណត់កាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល...........................................៤៦
១.២. ការប្រើប្រាស់សិទ្ធិបំភ្លឺ......................................................................................... ៤៧
១.៣.ការអនុវត្តនូវគោលការណ៍យុត្តិធម៌ និងឆាប់រហ័ស.......................................................... ៤៧
១.៤.ការបញ្ជូន ..........................................................................................................៤៨
**សេចក្តីសន្និដ្ឋាន**.............................................................................................................៥០
**មតិយោបល់ និងសំណូមពរ**...............................................................................................៥១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីរាយនាមឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី០១ ៖ពាក្យសុំលើកពេល ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១ ។

ឧបសម្ព័ន្ធទី០២ ៖ដីកាបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១ ។

ឧបសម្ព័ន្ធទី០៣ ៖របាយការណ៍ស្ដីពីការបញ្ជូន ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២០ ។

ឧបសម្ព័ន្ធទី០៤ ៖លិខិតអញ្ជើញមេធាវី ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០

ឧបសម្ព័ន្ធទី០៥ ៖ដីកាកោះដើមចោទ និងដីកាកោះចុងចម្លើយ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០ ។

ឧបសម្ព័ន្ធទី០៦ ៖ដីកាបញ្ជូន ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០ ។

ឧបសម្ព័ន្ធទី០៧ ៖ពាក្យស្នើសុំដកពាក្យបណ្ដឹង ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ ។

ឧបសម្ព័ន្ធទី០៨ ៖ពាក្យបណ្ដឹង ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ ។

ឧបសម្ព័ន្ធទី០៩ ៖ពាក្យសុំបញ្ជូលភស្ដុតាង ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ។

ឧបសម្ព័ន្ធទី១០ ៖កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ទី២៤ ខែសីហា ឆ្នាំ២០២០ ។

ឧបសម្ព័ន្ធទី១១ ៖ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រាសំខាន់ៗដែលពាក់ព័ន្ធ ។

# បញ្ជីរាយនាមពាក្យកាត់

| | | |
|---|---|---|
| ១.ក្រមនីតិវិធីរដ្ឋប្បវេណី | | ក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧ និងអនុវត្តទូទាំងប្រទេសនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ។ |
| ២.សេចក្តីកំណត់មាត្រានីមួយៗនៃក្រម នីតិវិធីរដ្ឋប្បវេណី | | សេចក្តីកំណត់មាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលដែលរៀបចំដោយក្រុមការងារជប៉ុនទទួលធ្វើ សេចក្តីក្រមនីតិវិធីរដ្ឋប្បវេណី និងគណកម្មការទទួល បន្ទុកសេចក្តីព្រាងក្រមរដ្ឋប្បវេណី ក្រសួងយុត្តិធម៌ចុះ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៧ ។ |

# សេចក្តីផ្តើម

ក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានបង្កើតឡើងក្នុងគោលបំណងកំណត់អំពីនីតិវិធីដែលទាក់ទងនឹងបណ្តឹងរដ្ឋប្បវេណី ដើម្បីឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់។ ការដោះស្រាយវិវាទរដ្ឋប្បវេណី ធ្វើឡើងដោយការបង្ខំភាគីដោយផ្ទាល់ ឱ្យគោរពតាមសេចក្តីសម្រេចរបស់តុលាការ មិនតែប៉ុណ្ណោះដើម្បីឱ្យបណ្តឹងរដ្ឋប្បវេណីអាចសម្រេចគោលដៅ លុះត្រាតែការដោះស្រាយវិវាទនោះធ្វើឡើងដោយត្រឹមត្រូវនិងធានាបាននូវការគោរពសិទ្ធិរបស់ម្ចាស់សិទ្ធិ ដោយមានការទទួលស្គាល់ពីច្បាប់។ លើសពីនេះទៅទៀតដើម្បីឱ្យការដោះស្រាយវិវាទរដ្ឋប្បវេណី និងការសម្រេចសេចក្តីធ្វើឡើងប្រកបដោយប្រសិទ្ធភាព ចាំបាច់ត្រូវមានការត្រៀមរៀបចំជាមុននូវការជម្រះក្តី ឬ ទាញហេតុផលដោយផ្ទាល់មាត់។

ពេលដែលមានការដាក់ពាក្យបណ្តឹងនោះតុលាការនឹងធ្វើការចាត់ការដំណើរការតាំងពីទទួលពាក្យបណ្តឹងរហូតដល់ចេញសាលក្រម ដែលត្រូវឆ្លងកាត់ការទាញហេតុផលផ្ទាល់មាត់ទើបអាចចេញសាលក្រមបាន ក្នុងនោះដែរ ក៏មាននីតិវិធីមួយដើម្បីឱ្យនីតិវិធីទាញហេតុផលផ្ទាល់មាត់មានភាពរលូនទៅបានគឺនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលជានីតិវិធីមួយរៀបចំឡើងក្នុងគោលបំណងរៀបចំការអះអាងរបស់ភាគី រៀបចំណុចវិវាទបំភ្លឺការអះអាងរបស់ភាគី និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទ ដើម្បីឱ្យតុលាការពិចារណា និងវិនិច្ឆ័យតាមច្បាប់ និងមានភាពឆាប់រហ័យ និងមិនស្មុគស្មាញក្នុងការទាញហេតុផលផ្ទាល់មាត់។

ដោយមើលឃើញពីសារៈសំខាន់នៃការត្រៀមរៀបចំការទាញហេតុផលដោយផ្ទាល់មាត់ ទើបប្រធានបទស្តីពី "**នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**" ត្រូវបានតាក់តែងឡើងក្នុងគោលបំណងដើម្បីពង្រឹង និងពង្រីកចំណេះដឹង ដើម្បីធ្វើការសិក្សាស្រាវជ្រាវឱ្យបានកាន់តែស៊ីជម្រៅលើផ្នែកទ្រឹស្តីគតិយុត្តនិងការអនុវត្តជាក់ស្តែងនៃមណ្ឌលកម្មសិក្សាសាលាដំបូងខេត្តកំពង់ឆ្នាំង ដែលពាក់ព័ន្ធនឹងលំហូរនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយធ្វើការប្រៀបធៀបពីចំណុចដូចគ្នា និងចំណុចមិនទាន់អនុវត្តបានពេញលេញទៅនឹងទ្រឹស្តីគតិយុត្ត និងការអនុវត្តជាក់ស្តែង ។

ចំពោះការសិក្សាលើប្រធានបទនេះ ស្តែងឱ្យឃើញពីអត្ថប្រយោជន៍តាមរយៈការបកស្រាយ ឬ បំភ្លឺលើផ្នែកទ្រឹស្តីគតិយុត្តឱ្យកាន់តែស៊ីជម្រៅ និងឆ្លុះបញ្ចាំងឱ្យឃើញពីការអនុវត្តជាក់ស្តែងផងដែរ។ ក្រៅពីចំណេះដឹងដែលទទួលបានពីផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែង ក៏ផ្តល់នូវបទពិសោធន៍មានតម្លៃ ដែលកើតចេញពីការសរសេរអំពីខ្លឹមសារនៃប្រធានបទ ដើម្បីជាគន្លឹះសម្រាប់ការដឹកនាំនីតិវិធីឱ្យមានភាពល្អប្រសើរជាពិសេសនីតិវិធី

ត្រៀមសម្រាប់ការទាញហេតុផល ដែលជាការត្រៀមរៀបចំដើម្បីឱ្យការជម្រះក្ដីធ្វើឡើងប្រកបដោយភាពងាយស្រួល និងឆាប់រហ័ស ។

សារណានេះ អាចលេចចេញជារូបរាងឡើង ដោយសារតែការព្យាយាមខិតខំប្រឹងប្រែងទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងការសិក្សាលើបទដ្ឋានគតិយុត្ត និងទ្រឹស្ដីគតិយុត្ត ព្រមទាំងការយកចិត្តទុកដាក់ក្នុងការបំពេញកិច្ចការងារក្នុងការអនុវត្តជាក់ស្ដែង និងការពិភាក្សាជាមួយលោកគ្រូ អ្នកគ្រូ ដែលជាចៅក្រម ព្រមទាំងរៀមច្បងដែលជាក្រឡាបញ្ជីនៃមណ្ឌលកម្មសិក្សា។ មិនតែប៉ុណ្ណោះ ក៏បានសិក្សាស្វែងយល់ពីសំណុំរឿងជាច្រើនពាក់ព័ន្ធនឹងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលក្នុងនោះចំណុចមួយចំនួនធ្វើឡើងតាមការកំណត់ដោយច្បាប់ ប៉ុន្តែមួយចំនួនទៀតហាក់មានភាពខុសប្លែកដោយសារស្ថានភាពនៃរឿងក្ដីនិងបច្ចេកទេសក្នុងការដឹកនាំ។ ក្រៅពីនេះ ក៏មានការបង្ហាញពីកំណត់ហេតុនានា ឬ ឯកសារផ្សេងទៀតពាក់ព័ន្ធនឹងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផងដែរ។

ចំពោះវិសាលភាពនៃសារណា គឺធ្វើការបកស្រាយដោយផ្ដោតសំខាន់ទៅលើលំហូរនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយលើកឡើងអំពីសញ្ញាណទូទៅ ការចាប់ផ្ដើម ការដំណើការសកម្មភាព រហូតដល់ការបញ្ចប់នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ចំពោះរចនាសម្ព័ន្ធនៃរបាយការណ៍នេះ នឹងធ្វើការបង្ហាញអំពីខ្លឹមសារនៃប្រធានបទដោយមានការបែងចែកជា បី ជំពូកធំៗគឺៈ

-ជំពូកទី១ៈការសិក្សាទៅលើលិខិតតូបករណ៍គតិយុត្ត និងទ្រឹស្ដីគតិយុត្តពាក់ព័ន្ធនឹងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

-ជំពូកទី២ៈការរកឃើញក្នុងការអនុវត្តជាក់ស្ដែងចំពោះនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

-ជំពូកទី៣ៈការវិភាគប្រៀបធៀបរវាងលិខិតតូបករណ៍គតិយុត្ត និងទ្រឹស្ដីពាក់ព័ន្ធជាមួយនឹងការអនុវត្តជាក់ស្ដែងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតផល ។

# ជំពូកទី១

# ការសិក្សាលិខិតបទដ្ឋានគតិយុត្ត និងទ្រឹស្តីដែលពាក់ព័ន្ធនឹងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ការសិក្សាលិខិតបទដ្ឋានគតិយុត្ត និងទ្រឹស្តីដែលពាក់ព័ន្ធ ដែលយើងនឹងធ្វើការសិក្សាទៅលើប្រធានបទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលគឺត្រូវដឹងអំពីសញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (ចំណុចទី១) ការចាប់ផ្តើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល(ចំណុចទី២) និងការបញ្ចប់នីតិវិធីសម្រាប់ការទាញហេតុផល (ចំណុចទី៣)។

## ១.សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ១.១.និយមន័យ

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីលើកកំពស់ និងសម្រួលដល់ការជម្រះក្តីនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានគោលបំណងបំភ្លឺអំពីចំណុចវិវាទរវាងភាគី ដោយរៀបចំជាមុននូវសេចក្តីអះអាងរបស់ភាគី និងធ្វើការរៀបចំនូវភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទ ដែលត្រូវធ្វើការពិនិត្យ[1] ។ នៅក្នុងការទាញហេតុផលផ្ទាល់មាត់ ភាគីនីមួយៗតែងតែលើកឡើងនូវអង្គហេតុផ្សេងៗដែលខ្លួនយល់ឃើញថាមានប្រយោជន៍សម្រាប់ខ្លួនឯង ដោយពុំគិតថាអង្គហេតុទាំងនោះ មាន ឬ គ្មានសារៈសំខាន់ចំពោះរឿងក្តីនោះទេ ។ នៅក្នុងពេលជាមួយគ្នា ភាគីនីមួយៗតែងតែតវ៉ាចំពោះការលើកឡើងនូវអង្គហេតុទាំងអស់របស់ភាគីម្ខាងទៀត ហើយតែងតែព្យាយាមដាក់ភស្តុតាងទាំងឡាយណាដែលខ្លួនគិតថា មានប្រយោជន៍សម្រាប់ខ្លួនឯង ។ ក៏ប៉ុន្តែការធ្វើបែបនេះ នឹងនាំឱ្យការជម្រះក្តីមានភាពស្មុគស្មាញ និងអូសបន្លាយដោយឥតប្រយោជន៍ និងធ្វើឱ្យលំបាកក្នុងការស្វែងរកការពិត ហេតុនេះហើយមុននឹងចាប់ផ្តើមធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវពិគ្រោះជាមួយភាគីទាំងសងខាង ត្រូវរៀបចំសេចក្តីអះអាងរបស់ភាគី និងត្រូវបំភ្លឺចំណុចវិវាទ តាមវិធីសាស្ត្រដូចតទៅ ស្នើសុំឱ្យភាគីដកការអះអាងអំពីអង្គហេតុដែលមានប្រយោជន៍ចំពោះការសម្រេចអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹង និងផាត់ចោលនូវអង្គហេតុដែលភាគីអះអាងអំពីភាគីធ្វើការអះអាងដូចគ្នាចំពោះចំណុចជាសារវន្តនៃការពិនិត្យភស្តុតាងដោយចាត់ទុកថាជាអង្គហេតុដែលពុំមានវិវាទ។ ជាងនេះទៅទៀតចំពោះភស្តុតាងដែលត្រូវពិនិត្យចំពោះចំណុចវិវាទ តុលាការត្រូវធានាឱ្យបាននូវការពិនិត្យដោយសមូហវិធី ដោយយកចិត្តទុកដាក់តែទៅលើភស្តុតាងដែលសំខាន់ និងមានតម្លៃប៉ុណ្ណោះ ។ ដោយសារហេតុផលនេះហើយបានជា

[1] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០៣ ។

ក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា នៅមុនការជម្រះក្តីដោយការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវរៀបចំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។

-ការរៀបចំនូវការអះអាងរបស់ភាគី គឺជាតួនាទីរបស់តុលាការដែលត្រូវស្តាប់ និងកត់ត្រានូវការ អះអាងរបស់គូភាគី ដើម្បីទុកជាមធ្យោបាយតទល់ ឬមធ្យោបាយការពារនៅក្នុងរឿងក្តីរដ្ឋប្បវេណីរបស់ គូភាគី។ ដើមចោទ ត្រូវដាក់មធ្យោបាយតទល់អំពីខ្លឹមសារនៃសាលក្រមដែលទាមទារឱ្យតុលាការចេញ និង អង្គហេតុចាំបាច់ព្រមទាំងគប្បីបញ្ជាក់ឱ្យបានច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាង។ រីឯ ចុងចម្លើយត្រូវដាក់មធ្យោបាយការពារខ្លួន ឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែល ដើមចោទបានទាមទារ និងការទទួលស្គាល់ ឬមិនទទួលស្គាល់អង្គហេតុ ព្រមទាំងអង្គហេតុតវ៉ា។ ចំពោះ ឯកសារដែលគូភាគីត្រូវតែដាក់ជាមុន ដើម្បីជូនដំណឹងទៅតុលាការ និងភាគីម្ខាងទៀត គឺហៅថា "ឯកសារត្រៀម" សម្រាប់ដើមចោទ និងឯកសារចម្លើយ" សម្រាប់ចុងចម្លើយ។

-ការរៀបចំនូវចំណុចវិវាទនៃរឿងក្តី គឺជាតួនាទីរបស់តុលាការដែលត្រូវកំណត់ចំណុចដែលគូភាគីមិនត្រូវគ្នា ឬប្រកែកគ្នា ដើម្បីសម្រេចអង្គហេតុ ឬចំណុចដែលនឹងត្រូវវិនិច្ឆ័យឱ្យមានភាពងាយស្រួល និងដើម្បីជំរុះរាល់អង្គហេតុណាដែលមិនពាក់ព័ន្ធ ឬដែលគូភាគីបានទទួលស្គាល់។ ជាងនេះទៀត តុលាការ ត្រូវអនុវត្តសិទ្ធិឱ្យបំភ្លឺ និងរៀបចំនូវមធ្យោបាយតទល់ និងការពារខ្លួន ជាពិសេសត្រូវរៀបចំការអះអាង របស់គូភាគីទាំងសងខាង ដើម្បីកំណត់នូវចំណុចវិវាទពិតប្រាកដនៃរឿងក្តី។

-ការរៀបចំនូវភស្តុតាងនានាដែលពាក់ព័ន្ធនឹងចំណុចវិវាទ គឺជាតួនាទីរបស់តុលាការដែលត្រូវរៀប ចំតែភស្តុតាងណាដែលពាក់ព័ន្ធនឹងចំណុចវិវាទ ដែលគូភាគីបានដាក់ជូនតុលាការ ដើម្បីជាផលប្រយោជន៍របស់ខ្លួន។ ការរៀបចំនូវភស្តុតាងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺមិនដូចគ្នានឹងការ ពិនិត្យភស្តុតាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នោះទេ ដូច្នេះសូមកុំច្រឡំ និងត្រូវបែងចែក ឱ្យបានដាច់ស្រឡះពីគ្នា។ ម្យ៉ាងទៀត តុលាការរៀបចំភស្តុតាងដែលពាក់ព័ន្ធនឹងចំណុចវិវាទឱ្យមាន សណ្តាប់ធ្នាប់ លំដាប់លំដោយ និងរបៀបរៀបរយ ដើម្បីត្រៀមជាស្រេចសម្រាប់នីតិវិធីទាញហេតុផល ដោយផ្ទាល់មាត់ ដែលជានីតិវិធីបន្ទាប់។

### ១.២.គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមានគោលបំណងត្រៀមរៀបចំជាមុន សម្រាប់ការទាញ ហេតុផលដោយផ្ទាល់មាត់ ដើម្បីលើកកំពស់ និងសម្រួលដល់ការជម្រះក្តីនៅក្នុងការទាញហេតុផលដោយ ផ្ទាល់មាត់ឱ្យមានប្រសិទ្ធិភាព និងឆាប់រហ័ស ជាពិសេសឱ្យបានល្អិតល្អន់ប្រកបដោយយុត្តិធម៌។

តើតុលាការត្រូវធ្វើអ្វីខ្លះនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីលើកកំពស់ និង សម្រួលដល់ការជម្រះក្តី?

នៅក្នុងទីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវបំភ្លឺចំណុចវិវាទរវាងភាគី ដោយ រៀបចំជាមុននូវ សេចក្តីអះអាងរបស់ភាគី និងរៀបចំនូវភស្តុតាងដែលពាក់ព័ន្ធនឹងចំណុចវិវាទ។យ៉ាងណាមិញ ការជម្រះក្តីនឹងមានភាពស្មុគស្មាញអូសបន្លាយពេលវេលាដោយឥតប្រយោជន៍ និងមានការលំបាកក្នុងការស្វែងរកការពិតប្រសិនបើពុំមាននីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះ ទេ ។ ដូច្នេះ តុលាការត្រូវប្រើប្រាស់ សិទ្ធិឱ្យបំភ្លឺជាអាទិ៍ របស់ខ្លួនក្នុងការពិគ្រោះជាមួយភាគីទាំងសងខាង ដើម្បីរៀបចំសេចក្តីអះអាងរបស់ភាគី និងបំភ្លឺចំណុចវិវាទ ដូចជាៈ (១) ជម្រុះរាល់សេចក្តីអះអាង អំពីអង្គហេតុ ដែលពុំមានប្រយោជន៍ចំពោះអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹង។ (២) ជម្រុះ និងផាត់ចោលនូវអង្គហេតុ ដែលភាគីអះអាងដូចគ្នា ដោយចាត់ទុកជាអង្គហេតុដែលពុំមានវិវាទ។ ជាងនេះទៅទៀត ភស្តុតាងដែលត្រូវរៀបចំជាមុនទាក់ទងនឹងចំណុចវិវាទ តុលាការត្រូវធានានូវ ការពិនិត្យដោយសមូហវិធី ដោយរៀបចំភស្តុតាងដែលសំខាន់ និងមានតម្លៃជាសារវ័ន។ ផ្ទុយមកវិញ ជាគោលការណ៍ ការពិនិត្យភស្តុតាងដើម្បីយកមកធ្វើជាមូលដ្ឋានក្នុងការសំអាងហេតុក្នុងសេចក្តីសម្រេច មិនអាចធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានទេ។ ប៉ុន្តែ លើកលែងតែមានករណីចាំបាច់ដែលត្រូវរៀបចំចំណុចវិវាទ និងភស្តុតាង ទើបតុលាការអាចពិនិត្យភស្តុតាងជាឯកសារបាននៅក្នុង នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

ហេតុដូច្នេះទើបស្មារតីនៃក្រមនីតិវិធីរដ្ឋប្បវេណីចែងអំពីនីតិវិធី ដែលមុននឹងការជម្រះក្តីដោយ ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវរៀបចំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីសម្រួល និងលើកកំពស់ដល់ការជម្រះក្តី ។

## ១.៣.គោលការណ៍ទទួលខុសត្រូវរបស់តុលាការ

ក្នុងនាមជាអ្នកគ្រប់គ្រងនីតិវិធីរដ្ឋប្បវេណី តុលាការត្រូវប្រឹងប្រែងធានាឱ្យបានថា រឿងក្តីរដ្ឋប្បវេណីត្រូវបានប្រព្រឹត្តឡើងដោយភាពយុត្តិធម៌ និង ឆាប់រហ័ស[2] ។ ដោយឡែកចំពោះភាគីវិញ ក្នុងពេលដែលពួកគេត្រូវបានអនុញ្ញាតឱ្យអនុវត្តបណ្តឹងតាមឆន្ទៈរបស់ខ្លួន ដើម្បីឈ្នះក្តី តែពួកគេត្រូវបានហាមឃាត់មិនឱ្យអនុវត្តបណ្តឹងដោយមិនស្មោះត្រង់ និងទុច្ចរិត ចំពោះភាគីម្ខាងទៀតឡើយ ។ សកម្មភាពបណ្តឹងដែលចាត់ទុកថាមិនស្មោះត្រង់ ត្រូវកំណត់តាមការជាក់ស្តែងនីមួយៗ ដូចជា ករណីការដាក់មធ្យោបាយតទល់ ឬ ការពាខ្លួនដែលបានដាក់ទៅតុលាការយឺតយ៉ាវ មិនត្រូវនឹងពេលវេលាសមរម្យ ឬ ដោយកំហុសធ្ងន់ធ្ងររបស់ភាគី ភាគីបានស្បថក្លែងបន្លំ

[2] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៤ ។

សេចក្ដីថ្លែងការណ៍ និងក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្ដល់ឯកសារ ដែលពាក់ព័ន្ធនិងសេចក្ដីអះអាងរបស់ភាគីម្ខាងទៀត ជាអាទិ៍ ។

### ១.៤. គោលការណ៍ចំពោះមុខ

ដើម្បីធានានូវសិទ្ធិទាមទារឱ្យសាកសួរ ឱ្យមានប្រសិទ្ធិភាព ការជម្រះក្ដីត្រូវតែធ្វើឡើងដោយកោះហៅភាគីទាំងសងខាងឱ្យមកបង្ហាញខ្លួននៅកាលបរិច្ឆេទតែមួយ ហើយឱ្យភាគីប្រឈមមុខដាក់គ្នាដោយផ្ទាល់ ។ ប្រសិនបើអនុញ្ញាតឱ្យតុលាការកោះហៅភាគីតែម្ខាង ហើយស្ដាប់ការអះអាងរបស់ភាគីនោះ ដោយពុំមានវត្តមានរបស់ភាគីម្ខាងទៀត នោះអាចនឹងប៉ះពាល់ដល់ទំនុកចិត្តរបស់ភាគី ទៅលើយុត្តិធម៌នៃការវិនិច្ឆ័យ ។ ហេតុនេះហើយទើបមានបញ្ញត្តិចែងថា ជាគោលការណ៍តុលាការត្រូវវិនិច្ឆ័យដោយគោរពនូវគោលការចំពោះមុខ ពោលគឺត្រូវហៅភាគីទាំងសងខាង ឱ្យភាគីទាំងសងខាងថ្លែងអំពីអំណះអំណាងរបស់ខ្លួន និងជជែកតតាំងគ្នាទៅវិញទៅមក ។ ចំពោះគោលការណ៍ចំពោះមុខក៏មានករណីលើកលែងមួយចំនួនដែរ ដូចជា បើដើមចោទ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទដោយសាលក្រមកំបាំងមុខ[3] ។ បើចុងចម្លើយមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការអាចបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយភ្លាមៗ ហើយកំណត់នៃកាលបរិច្ឆេទលើកទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់បាន[4] ។

### ១.៥.គោលការណ៍អសាធារណៈ

ជាគោលការណ៍ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនចាំបាច់បើកជាសាធារណៈទេ ។ មានន័យថា តុលាការធ្វើតែចំពោះភាគីទាំងសងខាងដោយមិនបាច់បើកសវនាការជាសាធារណៈទេ ដោយអាចធ្វើនៅបន្ទប់ចៅក្រមបាន។ ប៉ុន្តែ តុលាការអាចអនុញ្ញាតឱ្យអ្នកដែលតុលាការយល់ឃើញថាសមរម្យចូលស្ដាប់ជាអ្នកសង្កេតការណ៍បាន ។ នេះសបញ្ជាក់ឱ្យឃើញថា អ្នកដែលអាចចូលរួមបានគឺត្រូវមានការអនុញ្ញាតពីតុលាការ ហើយចូលរួមស្ដាប់ក្នុងនាមជាអ្នកសង្កេតការណ៍បាន ។

### ១.៦. សិទ្ធិអំណាចតុលាការ និងភាគី

ការដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវធ្វើដោយ ប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវដឹកនាំចាត់ចែងនីតិវិធីនេះ ។ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់និយាយបាន និងអាចហាមឃាត់ជនដែលមិនស្ដាប់បញ្ជារបស់ខ្លួនមិនឱ្យនិយាយបាន ។ ក្រៅពីនេះតុលាការអាចធ្វើការចាត់ចែងនីតិវិធី និងធ្វើការសម្រេចសេចក្ដីពាក់ព័ន្ធនឹង

[3] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២០០ កថាខណ្ឌទី១ ។

[4] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២០១ កថាខណ្ឌទី១ ។

**- សិទ្ធិអំណាចរបស់តុលាការ ក្នុងការដឹកនាំនីតិវិធីបណ្ដឹង**

ការគ្រប់គ្រងនីតិវិធីឱ្យដើរទៅមុខ ព្រមទាំងចាត់ចែង និងការរៀបចំជំនុំជម្រះ គឺជាសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់តុលាការ ។ ដើម្បីឱ្យការជំនុំជម្រះអាចប្រព្រឹត្តទៅដោយពេញលេញ និងឆាប់រហ័ស គេត្រូវធ្វើយ៉ាងណាឱ្យនីតិវិធីដំណើរការទៅមុខយ៉ាងលឿន ហើយធ្វើការចាត់ចែងឱ្យបានសមរម្យ ស្របទៅតាមស្ថានភាពនៃការជំនុំជម្រះ ។ ហេតុដូច្នេះសិទ្ធិអំណាចនៃការគ្រប់គ្រងនីតិវិធី ដែលបានផ្ដល់ឱ្យតុលាការនោះគេអាចហៅថាសិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីបណ្ដឹង ។ ជាគោលការណ៍សិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីបណ្ដឹង គឺជាសិទ្ធិអំណាចតុលាការ ត្រូវអនុវត្តដោយតុលាការ ដូចជា សិទ្ធិឱ្យបំភ្លឺ លើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់យឺតយ៉ាវ ការបំបែក និងការរួមបញ្ចូលរឿងក្ដី និងការចូលរួមរបស់អ្នកបកប្រែ ជាអាទិ៍។ ខ្លឹមសារនៃការដឹកនាំនីតិវិធីមានវិសាលភាព គ្របដណ្ដប់ទៅលើដំណើរការទាំងមូលនៃការជំនុំជម្រះ មានដូចជា ការកំណត់កាលបរិច្ឆេទ និងការផ្លាស់ប្ដូរកាលបរិច្ឆេទ ការសម្រេចអំពីការពន្យាអំឡុងពេល ដែលបញ្ហាទាក់ទងទៅនឹងនីតិវិធីទាំងស្រុង ការរៀបចំ និងការចាត់ចែងសកម្មភាពរបស់ភាគី នៅកាលបរិច្ឆេទដែលបានកំណត់ ជាដើម។

**- ការរៀបចំសកម្មភាពរបស់ភាគី**

ចំណែកឯកសកម្មភាពរបស់ភាគីក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយភាគីមានសិទ្ធិក្នុងការទាមទាររដោយតុលាការចេញសាលក្រម ដែលគោរពតាមគោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី ដោយភាគីអាចធ្វើការចាប់ផ្ដើមបណ្ដឹង ការកំណត់កម្មវត្ថុ និងទំហំនៃការទាមទារ និងការបញ្ចប់បណ្ដឹងដោយឆន្ទៈរបស់ភាគី ។

**-សិទ្ធិតវ៉ារបស់ភាគី**

ភាគីមានសិទ្ធិអំណាចក្នុងការតវ៉ាចំពោះសិទ្ធិអំណាចក្នុងការដឹកនាំនីតិវិធីបណ្ដឹង ក្នុងករណីភាគីយល់ឃើញថា ផលប្រយោជន៍ស្របច្បាប់របស់ខ្លួនត្រូវបានបំពានដោយការដឹកនាំនីតិវិធីបណ្ដឹង របស់តុលាការ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជាក្នុងនីតិវិធីនៃការទាញហេតុផល ឬ ដោយសារការអនុវត្តសិទ្ធិឱ្យបំភ្លឺ របស់តុលាការ ភាគីអាចប្ដឹងតវ៉ាចំពោះការដឹកនាំនីតិវិធីនេះបាន ។ ក្នុងករណីដែលមានការប្ដឹងតវ៉ាបែបនេះកើតឡើង តុលាការត្រូវសម្រេចសេចក្ដីចំពោះបណ្ដឹងតវ៉ានេះ ដោយដីកាសម្រេច ។

**-ការសម្រេចអំពីកម្មវត្ថុ និងទំហំនៃការជំនុំជម្រះ និងការសម្រេចសេចក្ដីដោយភាគី**

កម្មវត្ថុនៃការជំនុំជម្រះ និងការចេញសាលក្រមក្នុងបណ្ដឹង គឺការទាមទារតាមផ្លូវបណ្ដឹង ដែលបានធ្វើឡើងដោយដើមចោទ តាមរយៈពាក្យបណ្ដឹង ។ តុលាការអាចចាប់ផ្ដើមធ្វើការជំនុំជម្រះលើបណ្ដឹងបាននៅពេលដែលបានទទួលពាក្យបណ្ដឹងរបស់ដើមចោទប៉ុណ្ណោះ ។ តុលាការមិនអាចចាប់ផ្ដើមនីតិវិធីបណ្ដឹងបានឡើយប្រសិនបើពុំមានពាក្យបណ្ដឹងពីភាគីនោះទេ ។ ម៉្យាងទៀតជាគោលការណ៍ នៅពេលដែលមានការដាក់ពាក្យបណ្ដឹង ហើយការជំនុំជម្រះត្រូវបានចាបផ្ដើម ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង ឬ ទាមទារនៅក្នុង

ពាក្យបណ្តឹង អាចត្រូវបានជំនុំជម្រះ និងចេញសាលក្រម តែត្រឹមទំហំដែលបានដាក់ពាក្យសុំប៉ុណ្ណោះ ។ នេះមានន័យថា ភាគីមានសិទ្ធិសម្រេចអំពីកម្មវត្ថុ និងទំហំនៃការជំនុំជម្រះ និងការចេញសាលក្រមនៅក្នុងពាក្យបណ្តឹង ។

**-ការបញ្ចប់បណ្តឹងដោយផ្អែកលើឆន្ទៈរបស់ភាគី**

ទោះបីជានីតិវិធីត្រូវបានចាប់ផ្តើមក៏ដោយ ដើមចោទអាចដកពាក្យបណ្តឹង និងបញ្ចប់បណ្តឹងបាន ។ ហើយការដកពាក្យបណ្តឹងពុំមានអានុភាពឡើយ លើកលែងតែបានទទួលការយល់ព្រមពីចុងចម្លើយ ។ លើសពីនេះទៀត ភាគីអាចបញ្ចប់បណ្តឹង ដោយមិនចាំបាច់រង់ចាំសាលក្រមចុងក្រោយបាន តាមរយៈលះបង់នូវការទាមទារ ឬ ទទួលស្គាល់ការទាមទារ ឬ តាមរយៈការផ្សះផ្សាលើបណ្តឹង ។

**-គោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី និងមូលដ្ឋាននៃសិទ្ធិនេះ**

គោលការណ៍ដែលអនុញ្ញាតឱ្យភាគីអាចធ្វើការសម្រេច ដោយផ្អែកលើឆន្ទៈរបស់ខ្លួន អំពីការចាប់ផ្តើមបណ្តឹង អំពីកម្មវត្ថុបណ្តឹង ទំហំនៃការជំនុំជម្រះ ការចេញសាលក្រម និងការចេញសាលក្រមគេហៅថាសិទ្ធិចាត់ចែងរបស់ភាគី ។ មូលដ្ឋាននៃការកំណត់សិទ្ធិចាត់ចែង មកដាក់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនេះ គឺដោយសារផ្អែកលើគោលការណ៍នៃស្វ័យភាពបុគ្គលឯកជន ។ មានន័យថាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលជាកម្មវត្ថុនៃបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានចាត់ចែងដោយសេរី ដោយផ្អែកតាមឆន្ទៈរបស់ភាគី ។ ហេតុដូច្នេះហើយ ការសង្គ្រោះតាមផ្លូវបណ្តឹង អាចត្រូវបាន អាចធ្វើបានទៅតាមទំហំ និងពេលវេលាដែលភាគីបានទាមទារ ។ ប្រសិនបើតុលាការ ដែលជាស្ថាប័នរបស់រដ្ឋ ចាប់ផ្តើម ហើយចេញសាលក្រម លើសពីទំហំដែលភាគីទាមទារនោះត្រូវចាត់ទុកថាជាការរំលោភបំពានទៅលើគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ។

**-ការបំភ្លឺទំនាក់ទំនងអង្គហេតុ**

កម្មវត្ថុនៃបណ្តឹងគឺជាសិទ្ធ ឬ ទំនាក់ទំនងគតិយុត្តដែលដើមចោទបានអះអាងក្នុងការទាមទារតាមផ្លូវបណ្តឹង ។ ប៉ុន្តែ ដើម្បីឱ្យតុលាការអាចធ្វើការសម្រេចសេចក្តី អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ។ ឧទាហរណ៍ ទោះបីជា ក បានដាក់ពាក្យបណ្តឹងចំពោះ ខ ដោយអះអាងទាមទារឱ្យ ខ សងប្រាក់ចំនួន ១០ លានរៀល ដែលខ្លួនបានខ្ចី ក៏ដោយ ក៏តុលាការមិនអាចសម្រេចសេចក្តីថាតើសិទ្ធិទាមទារ ប្រាក់កម្ចីចំនួន ១០ លានរៀល ដែល ក បានអះអាងនោះ មានអត្ថិភាព ឬ គ្មាននោះទេ លើកលែងតែអង្គហេតុនៃរឿងក្តី ត្រូវបានបំភ្លឺ ។

**-សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់ភាគី**

ក្រមនីតិវិធីរដ្ឋប្បវេណី ទទួលស្គាល់នូវសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់ភាគី ក្នុងការបំភ្លឺទំនាក់ទំនងអង្គហេតុនៃរឿងក្តី ឬ អាចហៅម្យ៉ាងទៀត សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់ភាគីក្នុងការផ្តល់សម្ភារៈជាមូលដ្ឋានផ្សេងៗ ពាក់ព័ន្ធនឹងអង្គហេតុចាំបាច់ដើម្បីឱ្យតុលាការអាចចេញសាលក្រមបាន ។ ដោយតុលាការ

មិនអាចយកអង្គហេតុណាដែលភាគីមិនបានអះអាង មកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ [5]។ មានន័យថា ភាគីមានសិទ្ធិសេរីភាពក្នុងការអះអាង ឬ មិនអះអាងអំពីអង្គហេតុណាមួយ ហើយមានសិទ្ធិអំណាច ក្នុងការកំណត់ទំហំនៃអង្គហេតុដែលតុលាការត្រូវពិចារណា នៅពេលធ្វើការសម្រេចក្តី ។ ម៉្យាងវិញទៀត បើទោះបីជាមានអង្គហេតុជាក់ស្តែង ដែលមានប្រយោជន៍សម្រាប់ភាគីក៏ដោយ តែបើភាគីមិនអះអាងទេ តុលាការមិនអាចពិនិត្យនូវអង្គហេតុនោះ ដើម្បីចេញសាលក្រមបានឡើយ ។ ការណ៍នេះធ្វើឱ្យភាគីរងនូវការខូចប្រយោជន៍ ដោយសារតែតុលាការមិនអាចទទួលស្គាល់នូវអានុភាពគតិយុត្តដែលមានប្រយោជន៍សម្រាប់ភាគីនោះ ។ ដោយហេតុនេះហើយ ភាគីត្រូវទទួលខុសត្រូវធ្វើការអះអាងនូវអង្គហេតុដែលមានប្រយោជន៍ដល់ខ្លួន ប្រសិនបើចង់ឈ្នះក្តី ហើយការទទួលខុសត្រូវនេះគេហៅថា ការទទួលខុសត្រូវក្នុងការអះអាង ។ ឧទាហរណ៍ ទោះបីជាមានអង្គហេតុថា ចុងចម្លើយបានសងប្រាក់កម្ចីរួចហើយក៏ដោយ តែប្រសិនបើចុងចម្លើយមិនបានអះអាងទេ តុលាការមិនអាចយកអង្គហេតុនេះមកពិចារណាបានឡើយ ហើយដោយហេតុនេះតុលាការមិនអាចទទួលស្គាល់ថា កាតព្វកិច្ចរបស់ចុងចម្លើយមិនអាចរលត់ដោយការសងនោះបានទេ ។ ទោះបីជា តាមរយៈចម្លើយរបស់សាក្សី ធ្វើឱ្យតុលាការគិតថា ចុងចម្លើយបានសងបំណុលនោះរួចហើយក៏ដោយ តែប្រសិនបើភាគីមិនបានអះអាងអំពីអង្គហេតុនោះទេ តុលាការមិនអាចយកការគិតឃើញរបស់ខ្លួននេះ មកធ្វើជាមូលដ្ឋាននៃការសម្រេចសេចក្តីទៅលើអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលអះអាងដោយដើមចោទបានឡើយ ។ អង្គហេតុ ដែលតុលាការមិនអាចយកមកធ្វើជាមូលដ្ឋាននៃសាលក្រមបាន លើកលែងតែមានការអះអាងពីភាគី គឺអង្គហេតុដែលមានភាពចាំបាច់ដោយផ្ទាល់ ដើម្បីធ្វើការកំណត់អំពីអានុភាពគតិយុត្តនៃការកកើត ឬ ការរលត់សិទ្ធិ និងកាតព្វកិច្ច ។ នៅពេលភាគីបានលើកឡើងនូវអង្គហេតុផ្ទាល់ហើយ ទោះបីជាមិនបានលើកឡើងពីអង្គហេតុដែលមានប្រយោជន៍ដល់ការសន្និដ្ឋានអំពីអត្ថិភាពនៃអង្គហេតុចម្បងនោះ ក៏ដោយ ក៏តុលាការអាចយកអង្គហេតុប្រយោលនោះមកធ្វើជាមូលដ្ឋាននៃសាលក្រមបានដែរ ព្រោះថា អង្គហេតុប្រយោល មានលក្ខណៈដូចជាភស្តុតាងត្រង់ថា វាគឺជាឧបករណ៍បញ្ជាក់អំពីអត្ថិភាពនៃអង្គហេតុផ្ទាល់ ។

ចំពោះអង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និងអង្គហេតុដែលគ្មានវិវាទរវាងភាគី តុលាការពុំចាំបាច់ទទួលស្គាល់ អង្គហេតុនោះ ដោយភស្តុតាងទេ ។ តាមក្រមនីតិវិធីរដ្ឋប្បវេណី ការសារភាពសំដៅទៅលើសេចក្តីថ្លែងការណ៍ ដែលតាមរយៈនោះ ភាគីទទួលស្គាល់ថា អង្គហេតុដែលមិនមានអំណោយផលល្អដល់ខ្លួន ហើយដែលភាគីម្ខាងទៀតបានអះអាង គឺជាអង្គហេតុពិត ។ ចំពោះអង្គហេតុដែលភាគីបានសារភាព មានន័យថា អង្គហេតុដែលភាគីម្ខាង បានអះអាង ហើយភាគីម្ខាងទៀតមិនតវ៉ា តុលាការពុំចាំបាច់ទទួលស្គាល់

[5] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៥ ។

អង្គហេតុទាំងនោះដោយផ្អែកលើភស្តុតាងទេ ហើយតុលាការក៏មិនត្រូវទទួលស្គាល់អង្គហេតុដែលផ្ទុយពីអង្គហេតុទាំងនោះ៖ តាមរយៈការពិនិត្យ ភស្តុតាងដែរ ។

ចំពោះភស្តុតាងដើម្បីទទួលស្គាល់អង្គហេតុដែលមានវិវាទរវាងភាគី ជាដំបូង តុលាការត្រូវពិនិត្យ ភស្តុតាងដែលភាគីបានស្នើសុំឱ្យពិនិត្យ[6] ។ ក៏ប៉ុន្តែ ប្រសិនបើតុលាការពុំអាច សម្រេចថាត្រូវទទួលស្គាល់ ឬ មិនទទួលស្គាល់នូវការអះអាងអំពីអង្គហេតុ ដោយផ្អែកលើភស្តុតាងដែលគូ ភាគីបានស្នើសុំឱ្យពិនិត្យ ឬ បើយល់ឃើញថាមានការចាំបាច់ផ្សេងទៀត នោះតុលាការអាចធ្វើការពិនិត្យ ភស្តុតាង ដោយឆន្ទានុសិទ្ធិបាន[7] ។

គោលការណ៍នៃការបំភ្លឺអំពីអង្គហេតុនៃរឿងក្តី ដែលចាំបាច់ដើម្បីឱ្យតុលាការចេញសាលក្រម ទៅលើការអះអាងរបស់ភាគី គេហៅថា "គោលការណ៍នៃការទាញហេតុផល"។ ទោះជាយ៉ាងណាក៏ដោយ គួរកត់សំគាល់ថា ក្នុងចំណោមគោលការណ៍ខាងលើនេះ ករណីលើកលែងដ៏សំខាន់មួយ ត្រូវបានទទួលស្គាល់ចំពោះគោលការណ៍ទីបី។ និយាយឱ្យចំទៅ គោលការណ៍នៃការទាញហេតុផល ដែលមាននៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា មិនគ្របដណ្តប់ទៅលើការពិនិត្យភស្តុតាងទេ ។ មូលហេតុ និង ការកម្រិតទៅលើគោលការណ៍នៃការទាញហេតុផល មូលហេតុនៃការប្រកាន់យកគោលការណ៍នៃការទាញហេតុផល នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី គឺដោយសារថា ជាទូទៅ កម្មវត្ថុនៃបណ្តឹងរដ្ឋប្បវេណី គឺជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលអាចចាត់ចែងដោយសេរីរវាងបុគ្គលឯកជន។ ល្គឹកណាដែលភាគីអាចចាត់ចែងដោយសេរី នូវសិទ្ធិឬទំនាក់ទំនងគតិយុត្តរបស់ខ្លួន ដែលជាកម្មវត្ថុនៃបណ្តឹង ទោះជាក្នុងករណីដែលអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តនោះ៖ ក្លាយជាបញ្ហាវិវាទនៅក្នុងបណ្តឹងក៏ដោយ ជាការប្រសើរគួរតែទុកឱ្យភាគីមានសេរីភាពក្នុងការកំណត់ថា អង្គហេតុណាខ្លះដែលខ្លួនត្រូវយកមកអះអាងដើម្បីធ្វើការបញ្ជាក់ និង ក្នុងការកំណត់ថាតើខ្លួនត្រូវធ្វើការតតាំងចំពោះការអះអាងអំពីអង្គហេតុរបស់ភាគីម្ខាងទៀត ត្រឹមកម្រិតណា។ ជាងនេះទៅទៀត រដ្ឋពុំមានផលប្រយោជន៍ដោយផ្ទាល់ណាមួយចំពោះលទ្ធផលនៃការកំណត់អំពីសិទ្ធិវិវាទនៅក្នុងបណ្តឹងឡើយ ។ បន្ថែមពីលើនេះ ចំពោះការបំភ្លឺអំពីអង្គហេតុដែលទាក់ទងទៅនឹងអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិបែបនេះ វិធីដែលលឿន ក្នុងការ ស្វែងរកការពិតនោះ គឺត្រូវប្រគល់បញ្ហានេះទៅឱ្យភាគី ដែលបានដឹងច្បាស់អំពីស្ថានភាពពាក់ព័ន្ធ ។ម្យ៉ាងទៀត ប្រសិនបើយកអង្គហេតុដែលមិនត្រូវបានបង្ហាញនៅក្នុងការអះអាងអំពីអង្គហេតុរបស់ភាគី ទៅធ្វើជាមូលដ្ឋាន ការចេញសាលក្រមនោះ អាចនឹងនាំឱ្យភាគីមានការភ្ញាក់ផ្អើល តែប្រសិនបើទុកតួនាទីនេះឱ្យភាគីវិញ ទើបអាចចៀសវាងការប្រថុយប្រថាននេះបាន ។ ធ្វើដូច្នេះ គេនឹងអាចទទួលបាននូវលទ្ធផលដែលភាគីទាំងសងខាងពេញចិត្ត ។

[6] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១២៤ កថាខណ្ឌទី១ ។

[7] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១២៤ កថាខណ្ឌទី២ ។

គោលការណ៍នៃការទាញហេតុផល សន្មតថា កម្មវត្ថុនៃបណ្តឹង គឺជាសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលអាចចាត់ចែងដោយសេរីរវាងបុគ្គលឯកជន ។ ហេតុនេះហើយ គោលការណ៍នេះ មិនអាចអនុវត្តចំពោះបណ្តឹងដែលមានកម្មវត្ថុជាសិទ្ធិ ឬទំនាក់ទងគតិយុត្ត ដែលមិនអាចចាត់ចែងបានដោយការព្រមព្រៀងរវាងភាគី ដូចជាទំនាក់ទំនងឋានៈបុគ្គល ជាអាទិ៍ បានឡើយ ។ ចំពោះបណ្តឹងប្រភេទទាំងនេះ យកគោលការណ៍នៃការវិនិច្ឆ័យដែលតាមរយៈនោះតុលាការមានឆន្ទានុសិទ្ធិអាចនឹងយកអង្គហេតុដែលភាគីមិនបានអះអាង មកធ្វើជា មូលដ្ឋាននៃការចេញសាលក្រមបាន ហើយអង្គហេតុដែលពុំមានវិវាទរវាងភាគី អាចត្រូវបានទទួលស្គាល់ដោយ ផ្អែកលើភស្តុតាងបាន និង ម្យ៉ាងទៀត តុលាការអាចធ្វើការពិនិត្យភស្តុតាងតាមឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

បន្ថែមពីលើនេះ គោលការណ៍នៃការទាញហេតុផល គឺជាគោលការណ៍ដែលទាក់ទងទៅនឹងការបំភ្លឺអំពីទំនាក់ទំនងអង្គហេតុនៃរឿងក្តី ។ ដោយឡែក ការវិនិច្ឆ័យតាមផ្លូវច្បាប់ ដូចជាការបកស្រាយ ឬ ការអនុវត្តច្បាប់ គឺជាបញ្ហាដែលតុលាការត្រូវចាត់ការដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

**-កិច្ចសហការរបស់តុលាការ សិទ្ធិឱ្យបំភ្លឺ**

ទោះបីជាការបំភ្លឺអំពីទំនាក់ទំនងអង្គហេតុ ត្រូវបានផ្ទុកផ្តាក់ជាសិទ្ធិអំណាច និង ការទទួលខុសត្រូវរបស់ភាគី ក៏ដោយ ក៏វាមិនមែនជាការប្រសើរឡើយ ដែលតុលាការ ក្នុងនាមជាស្ថាប័នរដ្ឋដែលត្រូវទទួលខុសត្រូវដោះស្រាយវិវាទរវាងបុគ្គលឯកជនដោយអនាគតិ និងត្រូវផ្តល់ការការពារចំពោះភាគីដែលមានសិទ្ធនោះ ត្រូវនៅស្ងៀមចាំតែឈរមើលនោះដែរ ។ តុលាការ ត្រូវសហការជាមួយភាគី ដើម្បីឱ្យភាគីអាចរៀបចំ ការអះអាងរបស់ខ្លួនបានហ្មត់ចត់ ។ ហេតុនេះហើយ បានជាមានបញ្ញត្តិចែងថា ដើម្បីឱ្យចំណុចនៃអង្គហេតុ និង អង្គច្បាប់ដែលទាក់ទងនឹងបណ្តឹង មានភាពច្បាស់លាស់ តុលាការអាចសាកសួរភាគី ឬ ឱ្យភាគីអះអាង ឬ បញ្ជាក់ចំពោះចំណុចនោះនៅ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់បាន[8] ។ ឧទាហរណ៍ ក្នុងករណីដែលមានចំណុចមិនច្បាស់លាស់ នៅក្នុងសេចក្តីថ្លែងការណ៍ របស់ភាគី តុលាការអាចសាកសួរភាគី អំពីចំណុចទាំងនោះ ដើម្បីបំភ្លឺឱ្យបានច្បាស់លាស់នូវគោលគំនិតនោះបាន ។ ម្យ៉ាងទៀត ក្នុងករណីដែលមានចំណុចមិនស្របគ្នា នៅក្នុងការអះអាងរបស់ភាគីតុលាការអាចចង្អុលប្រាប់ អំពីចំណុចមិនស្របគ្នានោះ ដើម្បីឱ្យភាគីអាចបំពេញបន្ថែម ឬ កែតម្រូវការអះអាងរបស់ខ្លួនបាន ។ ជាងនេះ៖ ទៅទៀត តុលាការអាចជម្រុញឱ្យភាគីលើកឡើងនូវអង្គហេតុថ្មី ឬ ផ្តល់នូវភស្តុតាងថ្មីបាន ត្រឹមកម្រិតដែលមិន លើសពីភាពយុត្តិធម៌ និងភាពសមហេតុផល។ ប៉ុន្តែទោះបីជាក្នុងករណីដែលតុលាការជម្រុញឱ្យភាគី លើកឡើងនូវអង្គហេតុថ្មីក៏ដោយ

[8] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩០ កថាខណ្ឌទី១ ។

ប្រសិនបើភាគីមិនព្រមលើកឡើងទេ ក៏តុលាការមិនអាចយកអង្គហេតុថ្មីនោះ មកធ្វើជាមូលដ្ឋាននៃសាលក្រមបានដែរ ។

សិទ្ធិអំណាចរបស់តុលាការបែបនេះ គេហៅថា "សិទ្ធិឱ្យបំភ្លឺ" ឬ "សិទ្ធិសួរសំនួរ"។ ភាគី អាចស្នើសុំ ឱ្យតុលាការអនុវត្តនូវសិទ្ធិឱ្យបំភ្លឺ និងសួរសំនួរចាំបាច់ទៅភាគីម្ខាងទៀតនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀម សម្រាប់ការទាញហេតុផល ឬ នៅកាលបរិច្ឆេទនៃការទាញហេតុផលបាន ( មាត្រា ៩០ កថាខណ្ឌទី២) ។

**-ការបង្គាប់ឱ្យត្រៀមរៀបចំការបំភ្លឺ នៅក្រៅកាលបរិច្ឆេទ**

លើសពីនេះទៅទៀត នៅក្រៅកាលបរិច្ឆេទ ពេលធ្វើការស្រាវជ្រាវអំពីឯកសារដែលបានដាក់ដោយភាគីជាដើម ប្រសិនបើតុលាការយល់ឃើញថា មានចំណុចមិនច្បាស់លាស់នៅក្នុងការអះអាង ឬ មានចំណុចខ្វះខាតនៅក្នុងការបញ្ជាក់របស់ភាគី តុលាការអាចបង្គាប់ឱ្យភាគីត្រៀមខ្លួននឹងរៀបចំការឆ្លើយបំភ្លឺអំពីចំណុច ទាំងនោះនៅកាលបរិច្ឆេទបន្ទាប់បាន[9] ។ ជាឧទាហរណ៍មួយចំពោះករណីទាំងនេះ គឺថា ទោះជាក្នុងករណីដែលភាគីមានអ្នកតំណាងដោយអាណត្តិនៅក្នុងរឿងក្តីក៏ដោយ តុលាការអាចបង្គាប់ ឱ្យសាមីភាគី ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ចូលមកតុលាការ ដើម្បីឱ្យតុលាការសួរដោយផ្ទាល់ អំពីស្ថានភាពមួយចំនួន ឬ ឱ្យសាមីភាគី ឬ អ្នកតំណាងដែលច្បាប់បានកំណត់នោះ ដាក់ឯកសារដើមដូចជា កិច្ចសន្យាដែលបានលើកឡើង ជាអាទិ៍ ដើម្បីឱ្យតុលាការអាចយល់បានអំពីការអះអាងរបស់ភាគី ។

**-សិទ្ធិឱ្យបំភ្លឺ និង កាតព្វកិច្ចទាមទារឱ្យបំភ្លឺ**

សិទ្ធិឱ្យបំភ្លឺ គឺជាសិទ្ធិអំណាចដែលត្រូវបានទទួលស្គាល់ចំពោះតុលាការ ដើម្បីបំពេញមុខងារក្នុងការជំនុំជម្រះ ប្រកបដោយយុត្តិធម៌ ហើយ ក្នុងករណីមួយចំនួន តុលាការក៏មានកាតព្វកិច្ចទាមទារឱ្យភាគីធ្វើការបំភ្លឺដែរ ។ ក្នុងករណីដែលតុលាការចេញសាលក្រមដោយមិនបានអនុវត្តសិទ្ធិឱ្យបំភ្លឺ បើទោះណាជាខ្លួនមានកាតព្វកិច្ចទាមទារឱ្យបំភ្លឺក៏ដោយ នោះសាលក្រមដែលបានចេញ គឺជាសាលក្រមដែលបំពានច្បាប់ ។ ហេតុដូច្នេះហើយ ក្នុងករណីដែលការបំពានច្បាប់បែបនេះ បានប៉ះពាល់ទៅដល់សេចក្តីសម្រេចក្នុងសាលក្រមនោះ ។ ក្តីអាចទាមទារឱ្យលុបចោលសាលក្រមនោះបាន តាមរយៈបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់[10] ។ ចំពោះ ថាតើក្នុងករណីណាខ្លះដែលតុលាការមានកាតព្វកិច្ចទាមទារឱ្យបំភ្លឺបែបនេះ គឺត្រូវកំណត់ទៅតាម ខ្លឹមសារជាក់ស្តែងនៃរឿងក្តីនីមួយៗ និង ទៅតាមកាលៈទេសៈ នៃការជំនុំជម្រះលើរឿងក្តីនីមួយៗ ។ ហេតុនេះហើយ បញ្ហានេះមានការពិបាកនឹងធ្វើការវែកញែកជាទូទៅណាស់ ។ ពេលខ្លះ មានកើតឡើងនូវបញ្ហាដែលថា ក្រោយពីបានពិនិត្យភ

[9] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩០ កថាខណ្ឌទី៣ ។

[10] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៨៤ ។

ស្តុតាងហើយ តុលាការអាចមើលឃើញយ៉ាងច្បាស់ថា មានអង្គហេតុផ្ទាល់មួយ ប៉ុន្តែភាគី ដែលមានករណីយកិច្ចត្រូវលើកឡើងនូវអង្គហេតុនោះ បែរជាពុំបានអះអាងទៅវិញ ។ ដូច្នេះមានសំនួរ ចោទឡើងថា តើតុលាការមានកាតព្វកិច្ចទាមទារឱ្យបំភ្លឺ ដែរឬទេ នៅក្នុងករណីបែបនេះ ។ ដោយយោង ទៅតាមដំណាក់កាលនៃរឿងក្តី ប្រសិនបើយល់ឃើញថា ភាគីនឹងមិនលើកឡើងនូវអង្គហេតុណាមួយឡើយ ប្រសិនបើតុលាការមិនអនុវត្តសិទ្ធិឱ្យបំភ្លឺទេនោះ គេអាចនិយាយបានថា ពេលនោះតុលាការត្រូវមានកាតព្វកិច្ច ទាមទារឱ្យបំភ្លឺ ។.

## ២.៧.ភាសាដែលប្រើក្នុងតុលាការ និងសិទ្ធិទាមទារឲ្យមានការបកប្រែភាសារបស់ភាគី

នៅក្នុងតុលាការ គឺត្រូវប្រើភាសាខ្មែរ[11] ។ បានន័យថា នៅក្នុងសាលសវនាការ តុលាការត្រូវតែប្រើភាសាខ្មែរ តែប៉ុណ្ណោះ មិនអាចប្រើភាសាអ្វីផ្សេងបានទេ ដូចដែលរដ្ឋធម្មនុញ្ញបានបញ្ញត្តិថា ភាសា និងអក្សរដែលប្រើជាផ្លូវការ គឺ ភាសា និងអក្សរខ្មែរ ។ ក្នុងករណីភាគីដែលមិនយល់ភាសាខ្មែរ ភាគីអាចស្នើសុំរកអ្នកបកប្រែភាសាខ្មែរដោយខ្លួនឯងបាន ផ្ទុយមកវិញប្រសិនបើភាគីពុំមានលទ្ធភាពរកដោយខ្លួនឯងបានទេរដ្ឋត្រូវរកជំនួស[12] ។ ប្រសិនបើតុលាការជាអ្នករកអ្នកបកប្រែភាសាសម្រាប់ភាគីដែលមិនអាចយល់ភាសាខ្មែរភាគីត្រូវបង់កម្រៃនៃការបកប្រែភាសា សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថមប្រចាំថ្ងៃ និងសោហ៊ុយស្នាក់នៅដែលត្រូវប្រគល់ឲ្យអ្នកបកប្រែជាមុន ។ លើកលែងតែភាគីដែលទទួលបានការសង្គ្រោះលើបណ្តឹងអាចពន្យារពេលបង់ ឬ ត្រូវបានអនុគ្រោះមិនបាច់ឲ្យបង់[13] ។

## ១.៨. ការពិនិត្យ និងបញ្ជូនពាក្យបណ្តឹង

ពាក្យបណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរទៅតុលាការដែលមានសមត្ថកិច្ច ហើយត្រូវគោរពតាមលក្ខខណ្ឌដែលច្បាប់បានកំណត់[14] ។ ប៉ុន្តែក្នុងករណីរឿងក្តីដែលមានចំនួនទឹកប្រាក់តិចការដាក់ពាក្យបណ្តឹងអាចធ្វើឡើងដោយផ្ទាល់មាត់បាន [15] ។

ក្រោយពីបានទទួលពាក្យបណ្តឹង ចៅក្រមដែលទទួលបន្ទុកនៃសំណុំរឿងក្តីនោះត្រូវពិនិត្យលើទម្រង់នៃពាក្យបណ្តឹង ហើយបើមានខ្វះចន្លោះផ្នែកទម្រង់ ឬ មិនបានបង់ពន្ធនៃការដាក់ពាក្យសុំ តុលាការត្រូវបង្គាប់ឲ្យអ្នកធ្វើពាក្យបណ្តឹងកែតម្រូវក្នុងអំឡុងពេលសមរម្យ ។ ក្នុងករណីដែលអ្នកធ្វើបណ្តឹងមិនព្រមធ្វើការកែតម្រូវនូវចំណុចខ្វះខាតតាមការណែនាំរបស់ចៅក្រមនោះទេ តុលាការនឹងលើកពាក្យបណ្តឹងចោលដោយដីកាសម្រេច[16] ។

[11] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥ កថាខណ្ឌទី១ ។

[12] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥ កថាខណ្ឌទី២ ។

[13] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៧០។

[14] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៧៥។

[15] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២២៥។

[16] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៨ ។

ក្រោយពីពិនិត្យពាក្យបណ្តឹងចប់សព្វគ្រប់ហើយ តុលាការត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅភាគីម្ខាងទៀត ដើម្បីឲ្យបានដឹងថាអ្នកណាជាអ្នកប្តឹង តើកម្មវត្ថុនៃបណ្តឹងជាអ្វី និងជាការផ្តល់ឱកាសឲ្យភាគីម្ខាងទៀតបានឆ្លើយដោះសារ និងមានពេលវេលាគ្រប់គ្រាន់នៅក្នុងការរៀបចំមធ្យោបាយការពារខ្លួន ។ បណ្តឹងនោះត្រូវបានចាត់ការលុះត្រាណាតែបណ្តឹងត្រូវបានបញ្ជូនឲ្យទៅដល់ចុងចម្លើយ[17] ។

ក្នុងករណីមិនអាចបញ្ជូនពាក្យបណ្តឹងបាន មានដូចជា អាសយដ្ឋានរបស់ចុងចម្លើយមិនមានភាពច្បាស់លាស់ ចុងចម្លើយជាអសមត្ថជនដែលគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ចុងចម្លើយជាជនបរទេសដែលមានអភ័យឯកសិទ្ធិ បដិសេធទទួលការបញ្ជូនពាក្យបណ្តឹង[18] ។

## ផ្នែកទី២ ការចាប់ផ្តើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ដើម្បីអាចឱ្យ នីតិវិធីរដ្ឋប្បវេណីដំណើរការបានរហូតមាននីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានច្បាស់ណាស់ថាត្រូវមានការដាក់ពាក្យបណ្តឹងជាមុនសិន ដែលអ្នកដាក់ពាក្យបណ្តឹងនោះមានភាគី អ្នកតំណាង ឬអ្នកអាណាព្យាបាលជាអាទិ៍។ បន្ទាប់ពីមានអ្នកដាក់ពាក្យបណ្តឹងហើយត្រូវមានការទទួលពាក្យបណ្តឹងការពិនិត្យពាក្យបណ្តឹង និងធ្វើការកំណត់កាលបរិច្ឆេទ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល(២.១) ប៉ុន្តែទោះជាយ៉ាងណាក្តីកាលបរិច្ឆេទក៏ត្រូវបានផ្លាស់ប្តូរ(២.២) ផងដែរ ក្រោយពេលដែលកំណត់កាលបរិច្ឆេទនៃការទាញហេតុផលរួចហើយនោះតុលាការត្រូវធ្វើការកោះហៅភាគី។ នៅក្នុងការកោះហៅភាគីតុលាការត្រូវបង្គាប់ឱ្យដើមចោទបង់ប្រាក់(២.៣)ជាមុនសម្រាប់ធ្វើការកោះហៅ និងត្រូវអនុវត្តនូវវិធីកោះហៅ(២.៤) ឱ្យបានត្រឹមត្រូវផងដែរ ។ ពេលភាគីទាំងសងខាងមានវត្តមានហើយ តុលាការនឹងសាកល្បងផ្សះផ្សា (២.៥) ជាមុនសិន បន្ទាប់មកតុលាការត្រូវឱ្យភាគីធ្វើសេចក្តីថ្លែងការណ៍ (២.៦)ទើបឱ្យភាគីធ្វើការដាក់មធ្យោបាយតទល់ ឬការពារខ្លួន(២.៧) បន្ទាប់មកតុលាការនឹងធ្វើរៀបចំនូវចំណុចវិវាទ (២.៨) ដោយចំណុចដែលមានវិវាទត្រូវការបញ្ជាក់ដោយភស្តុតាង(២.៩) ប៉ុន្តែក្នុងករណីមួយចំនួនតុលាការអាចធ្វើការ បំបែក ឬ រួមបញ្ចូលរឿងក្តី នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះបានផងដែរ (២.១០.) ទន្ទឹមនឹងដំណើការនៃនីតិវិធី ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (២.១១) ដែលបង្គាប់ដោយចៅក្រម ។

### ២.១.ការកំណត់កាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅពេលដែលបណ្តឹងត្រូវបានដាក់ តុលាការត្រូវកំណត់កាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលយ៉ាងឆាប់រហ័ស និងកោះហៅគូភាគី[19]។ កាលបរិច្ឆេទត្រូវកំណត់ក្នុងអំឡុងពេល ៣០(សាមសិប)ថ្ងៃបន្ទាប់

[17] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៩ ។

[18] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី១៧/មករា/២០០៧ មាត្រា ៧៩

[19] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៨០ កថាខណ្ឌទី១ ។

ពីពាក្យបណ្តឹងត្រូវបានដាក់[20]។ តុលាការត្រូវកំណត់កាលបរិច្ឆេទតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិ។ ប៉ុន្តែនីតិវិធីដែលទទួលដោយចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមដែលទទួលការប្រគល់សិទ្ធិ ចៅក្រមនោះអ្នកកំណត់។ ក្នុងករណីដែលមិនអាចជៀសវាងបាន កាលបរិច្ឆេទត្រូវកំណត់យកថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកដែលកំណត់ដោយច្បាប់ និងបទដ្ឋានគតិយុត្ត ។ កាលបរិច្ឆេទនៃនីតិវិធីត្រៀមអាចធ្វើឡើងដែលអាចឱ្យភាគីចូលរួមបាន[21] ដោយគោរពតាមគោលការណ៍ចំពោះមុខដែលច្បាប់បានធានា។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏តុលាការអាចធ្វើនីតិវិធីត្រៀម ក្នុងករណីដែលបញ្ជូនដីកាកោះ ឬ ផ្តល់ឱកាសឱ្យភាគីនោះបានបង្ហាញខ្លួនហើយ។

## ២.២.ការប្តូរកាលបរិច្ឆេទ

ករណីដែលតុលាការកំណត់កាលបរិច្ឆេទរួច បើភាគីដាក់ពាក្យស្នើសុំប្តូរកាលបរិច្ឆេទ ភាគីនោះត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីការប្តូរកាលបរិច្ឆេទនោះត្រូវធ្វើជាចាំបាច់។ ការប្តូរនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនត្រូវបានអនុញ្ញាតទេ លើកលែងតែករណីដែលមិនអាចជៀសវាងបាន។ ការប្តូរកាលបរិច្ឆេទសម្រាប់ការទាញហេតុផលលើកដំបូងអាចធ្វើបាន ប្រសិនបើមានការព្រមព្រៀងពីសំណាក់គូភាគី[22]។ ដោយហេតុថា ពេលដែលដើមចោទបានដាក់ពាក្យបណ្តឹងទៅតុលាការ ដោយមិនបានទាក់ទងទៅចុងចម្លើយជាមុន ហេតុនេះហើយដើម្បីការពារផលប្រយោជន៍របស់ចុងចម្លើយ ទើបករណីនេះអាចប្តូរបាន។

តុលាការអាចពន្យាកាលបរិច្ឆេទ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ប្រសិនបើយល់ឃើញថាអំឡុងពេលនៃការកោះហៅភាគីមានរយៈពេលខ្លីពេក ឬយល់ថាភាគីមិនអាចបង្ហាញខ្លួនដោយគ្មានកំហុសទេដែលត្រូវធ្វើការកោះហៅភាគីនៅកាលបរិច្ឆេទថ្មី[23]។

## ២.៣. ការបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

នីតិវិធីរដ្ឋប្បវេណី គឺជាវិវាទរវាងបុគ្គលឯកជន និងបុគ្គលឯកជន ហេតុនេះនៅក្នុងនីតិវិធីបណ្តឹង ដើមចោទដែលបានដាក់ពាក្យបណ្តឹងត្រូវចំណាយប្រាក់ សម្រាប់ធ្វើការកោះហៅ[24]។

ក្នុងករណីដែលតុលាការបង្គាប់ឱ្យដើមចោទបង់ប្រាក់ជាមុន ដែលជាការចំបាច់សម្រាប់កោះហៅភាគីឱ្យចូលមកនៅកាលបរិច្ឆេទ ដែលកំណត់អំឡុងពេលសមរម្យ តែដើមចោទមិនបានបង់ប្រាក់នោះជាមុនទេ តុលាការអាចលើកចោលដោយដីការសម្រេចបាន លុះត្រាតែចុងចម្លើយគ្មានការតវ៉ា។ ក្រោយពេលដែលបណ្តឹង

---

[20] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៨០ កថាខណ្ឌទី២ ។

[21] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០៥ កថាខណ្ឌទី១ ។

[22] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៤១ ។

[23] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២០៣ ។

[24] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៦២ ។

ត្រូវបានបញ្ជូនទៅចុងចម្លើយហើយ ចុងចម្លើយត្រូវបង់ជាមុននូវប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ ដែលចាំបាច់សម្រាប់ការកោះហៅភាគី។ ប្រសិនបើដើមចោទមិនបង់ប្រាក់តាមការបង្គាប់តុលាការនោះទេ អាចលើកបណ្ដឹងចោល ប៉ុន្ដែបើមានការតវ៉ាពីចុងចម្លើយ នោះចុងចម្លើយអាចប្ដឹងទាស់នឹងដីកាសម្រេចបាន[25]។តែបើដើមចោទបានបង់ប្រាក់សម្រាប់ការកោះហៅរួចរាល់ហើយ តុលាការនឹងរៀបចំធ្វើការកោះហៅ។

## ២.៤.ការកោះហៅ

ការកោះហៅតាមកាលបរិច្ឆេទ ត្រូវធ្វើដោយបញ្ជូនដីកាកោះ ឬដោយជូនដំណឹងអំពីកាលបរិច្ឆេទ ទៅអ្នកដែលបានបង្ហាញខ្លួននៅតុលាការចំពោះបណ្ដឹងដែលពាក់ព័ន្ធ[26]។

ការជូនដំណឹង អំពីកាលបរិច្ឆេទ ទៅអ្នកដែលបានបង្ហាញខ្លួននៅតុលាការចំពោះបណ្ដឹងដែលពាក់ព័ន្ធដែលតុលាការអាចប្រាប់ដោយផ្ទាល់មាត់អំពីកាលបរិច្ឆេទនោះ។ ក្រៅពីនេះក៏មានវិធីផ្សេងទៀតដែលងាយស្រួលដូចជា ការទាក់ទងតាមទូរស័ព្ទ តាមសំបុត្រធម្មតា ឬ តាមរយៈបុគ្គលិកនៃការិយាល័យមេធាវីជាអាទិ៍។

ការបញ្ជូន គឺជាប្រភេទមួយនៃការជូនដំណឹងអំពីខ្លឹមសារតាមផ្លូវបណ្ដឹងចំពោះភាគី និងអ្នកដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ ដែលត្រូវធ្វើតាមការកំណត់ច្បាប់ ដោយមានរបាយការណ៍ស្ដីពីការបញ្ជូន។ កិច្ចការបញ្ជូន ត្រូវធ្វើឡើងដោយក្រឡាបញ្ជី[27]។ មានន័យថា ក្រឡាបញ្ជីជាអ្នកចាត់ចែងកិច្ចការបញ្ជូនដោយប្រគល់អំណាចនៃការបញ្ជូនឯកសារទៅឱ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនមានបីគឺ បុគ្គលិកប្រៃសនីយ៍ អាជ្ញាសាលា និងក្រឡាបញ្ជីខ្លួនឯងផ្ទាល់ ដែលជាអ្នកទទួលបន្ទុកប្រតិបត្តិការបញ្ជូន[28] ។

នៅក្នុងការបញ្ជូនដីកាកោះ មន្ត្រីទទួលបន្ទុកដែលធ្វើការបញ្ជូនរួច ត្រូវធ្វើរបាយការណ៍អំពីការបញ្ជូនដីកាកោះនោះ ជូនទៅតុលាការ[29]។

## ២.៥.ការសាកល្បងផ្សះផ្សា

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវធ្វើការផ្សះផ្សាជាដំបូងសិន លើកលែងតែយល់ឃើញថាមិនសមរម្យ[30]។ ដោយសារថា នីតិវិធីរដ្ឋប្បវេណី មានគោលបំណងកំណត់អំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ និងកាតព្វកិច្ចតាមច្បាប់សារធាតុ ដែលអាចចាត់ចែងបាន ដោយផ្អែកលើការព្រមព្រៀងរបស់ភាគី។ ដូច្នេះ ទោះបីជានៅពេលនីតិវិធីបណ្ដឹងបានចាប់ផ្ដើមហើយក៏ដោយ ប្រសិនបើភាគីកំណត់ថាសិទ្ធិ ឬ កាតព្វកិច្ច

---

25 ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៨២ ។

26 ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៤២ ។

27 ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៤៦ កថាខណ្ឌទី២។

28 ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៤៦ កថាខណ្ឌទី៣។

29 ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៥៤ កថាខណ្ឌទី១។

30 ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១០៤ ។

នោះ ឬ តាមរយៈការសះជា ហើយភាគីសម្រេចចិត្តបញ្ចប់វិវាទ នោះជាលទ្ធផលមួយដែលគួរឱ្យចង់បាន។ ដើម្បី ផ្សះផ្សាទទួលបានលទ្ធផលតុលាការអាចធ្វើវិធីសាស្ត្រមួយចំនួនក្នុងការផ្សះផ្សាមានការសួរចំពោះមុខភាគីទាំង សងខាង ដើម្បីបង្កើតជម្រើសឱ្យភាគីមានការព្រមព្រៀងគ្នា និងវិធីសាស្ត្រមួយទៀតនោះគឺវិធីសួរឆ្លាស់គ្នា ដោយ ឱ្យភាគីម្ខាងចេញពីបន្ទប់ និងសួរម្នាក់ម្តងៗ។

ការផ្សះផ្សាជោគជ័យមានប្រយោជន៍ច្រើនណាស់សម្រាប់ភាគី មានដូចជា ចំណេញពេលវេលា ចំណេញថវិការមានដូចជាសោហ៊ុយលើចំណាយមធ្យោបាយធ្វើដំណើរ ការស្នាក់នៅ ហូបចុក និងចំណាយផ្សេងៗ ជាពិសេសគឺពន្ធលើពាក្យបណ្តឹង និងភាគីទាំងសងខាងអាចរក្សាទំនាក់ទំនងល្អជាងការបញ្ចប់វិវាទដោយ មិនមានការព្រមព្រៀង។ នៅក្នុងការផ្សះផ្សាអាចទទួលបានលទ្ធផលដូចជា ការដកពាក្យបណ្តឹង ការសះជា ការ លះបង់នូវការទាមទារ ឬការទទួលស្គាល់នូវការទាមទារ ។ នៅពេលដែលមានការដកពាក្យបណ្តឹង នឹងធ្វើឲ្យ ពាក្យបណ្តឹងនោះ ត្រូវចាត់ទុកថា មិនបានចាត់ការតាំងពីដំបូង[31]។ ចំណែកឯ ក្នុងករណីមានការសះជា ការ លះបង់នូវការទាមទារ ឬ ការទទួលស្គាល់នូវការទាមទារវិញ ក្នុងករណីដែលមានការសះជា ការលះបង់នូវការ ទាមទារ ឬការទទួលស្គាល់នូវការទាមទារ ត្រូវបានកត់ត្រានៅក្នុងកំណត់ហេតុ កំណត់ត្រានេះមានអានុភាពដូច គ្នានឹងសាលក្រមស្ថាពរ[32]។

## ២.៦.ការធ្វើសេចក្តីថ្លែងការណ៍របស់ភាគី

នៅពេលដែលធ្វើការផ្សះផ្សាមិនបានសម្រេចតុលាការត្រូវបន្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយឱ្យគូភាគីធ្វើសេចក្តីថ្លែងការណ៍តាមលំដាប់ បន្ទាប់ពីបញ្ចប់ការផ្សះផ្សា ហើយដើមចោទជាអ្នកធ្វើសេចក្តី ថ្លែងការណ៍(២.៦.១.)មុនបន្ទាប់មក ចុងចម្លើយធ្វើសេចក្តីថ្លែការណ៍(២.៦.២.)ជាក្រោយ។

### ២.៦.១. ការធ្វើសេចក្តីថ្លែងការណ៍របស់ដើមចោទ

តុលាការត្រូវឱ្យធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់នូវខ្លឹមសារ នៃសាលក្រមដែលដើមចោទទាមទារ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ អង្គហេតុដែលជាហេតុនៃការទាមទារ និងអង្គហេតុសំខាន់ៗដែល ជាមូលហេតុនៃការទាមទារ ដោយផ្អែកលើពាក្យបណ្តឹង ដូច្នេះគ្រាន់តែពាក្យបណ្តឹងមិនអាចក្លាយជាឯកសារបាន ទេ ចាំបាច់ត្រូវធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់នៅកាលបរិច្ឆេទ ដោយធ្វើសេចក្តីថ្លែងការណ៍ជាសារធាតុ អំពីខ្លឹមសារនៃឯកសារនានាដោយផ្ទាល់មាត់។ ចំពោះសេចក្តីថ្លែងការណ៍អំពីការទាមទារ ត្រូវធ្វើឡើងដោយការ ដាក់មធ្យាបាយតទល់។ ការដាក់មធ្យោបាយតទល់ បន្ទាប់ពីបានដាក់សុំលើអង្គសេចក្តីហើយ ដើមចោទនឹងធ្វើ សេចក្តីថ្លែងការគាំទ្រពាក្យសុំរបស់ខ្លួន។ សេចក្តីថ្លែងការណ៍របស់ដើមចោទគេហៅថាមធ្យោបាយតទល់។

---

[31] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២១៨ កថាខណ្ឌទី១ ។

[32] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២២២ ។

នៅក្នុងមធ្យោបាយតទល់ជាដំបូងដើមចោទធ្វើការអះអាងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលជាការទាមទារតាមផ្លូវបណ្តឹង។ ក៏ប៉ុន្តែ ដោយសារអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិមិនអាចទទួលស្គាល់ដោយផ្ទាល់បានឡើយ ហេតុនេះហើយតុលាការត្រូវធ្វើសេចក្តីសន្និដ្ឋានតាមសមហេតុផល ដើម្បីធ្វើការកំណត់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិនោះ។ ប្រសិនបើសិទ្ធិត្រូវបានបង្កើតឡើង និងមិនត្រូវបានរលត់នាពេលក្រោយនោះទេ ត្រូវមានអានុភាពនាពេលបច្ចុប្បន្ន។ ហេតុនេះដើម្បីឱ្យតុលាការសម្រេចអំពីអត្ថិភាពនៃសិទ្ធិដើម្បីចោទត្រូវអះអាងអំពីអង្គហេតុណាមួយឆ្លើយតបទៅនឹងផ្លូវច្បាប់ ។

### ២.៦.២.ការធ្វើសេចក្តីថ្លែងការណ៍របស់ចុងចម្លើយ

នៅពេលដែលដើមចោទធ្វើសេចក្តីថ្លែងការណ៍រួច ចុងចម្លើយនឹងធ្វើសេចក្តីថ្លែងការណ៍បន្ទាប់ ដោយលើកឡើងពីការទាមទាររបស់ខ្លួនតាមរយៈពាក្យសុំលើអង្គសេចក្តី និងការដាក់មធ្យោបាយការពារខ្លួន។

ប្រសិនបើចុងចម្លើយមិនបានដាក់ឯកសារចម្លើយទេ នៅកាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផល តុលាការឱ្យចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍តាមរយៈពាក្យសុំដោយផ្ទាល់មាត់ តែក្នុងករណីដែលចុងចម្លើយបានដាក់ឯកសារចម្លើយជូនតុលាការ ត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីឯកសារចម្លើយនោះ។

ចម្លើយចំពោះសាលក្រមដែលដើមចោទទាមទារមានបីប្រភេទ៖ (ក)ការទទួលស្គាល់ការទាមទារ ដែលកំណត់ហេតុទទួលស្គាល់នេះមានអានុភាពដូចសាលក្រមស្ថាពរ[33]។ (ខ)ទាមទារឱ្យច្រានចោលនូវការទាមទារដោយអះអាងគ្មានមូលហេតុនៃការទាមទារ (គ) និងទាមទារឱ្យលើកបណ្តឹងចោលដោយសារតែពុំមានលក្ខខណ្ឌបណ្តឹង[34]។

ការដាក់មធ្យោបាយការពារខ្លួន ចុងចម្លើយនឹងធ្វើសេចក្តីថ្លែងការណ៍គាំទ្រពាក្យសុំរបស់ខ្លួន។ ដើម្បីការពារទៅនឹងដើមចោទទាមទារ ក្នុងករណីដែលចុងចម្លើយធ្វើការច្រានចោលនូវការទាមទាររបស់ដើមចោទ តុលាការឱ្យចុងចម្លើយធ្វើការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុផ្សេងទៀត។ ក្នុងការឆ្លើយតបទៅនឹងការអះអាងរបស់ដើមចោទ ចុងចម្លើយអាចធ្វើវិវាទអំពីអត្ថិភាពនៃការទាមទារ តាមរយៈការបង្ហាញនូវមធ្យោបាយការពារខ្លួន ដែលគេហៅថាការតវ៉ា។ ការតវ៉ា គឺអង្គហេតុដែលអះអាងដោយចុងចម្លើយ ដើម្បីបង្កើតឧបសគ្គនៃការកកើតសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលអះអាងដោយដើមចោទ។ ហេតុនេះ ការតវ៉ាជាការអះអាងរបស់ចុងចម្លើយ។

[33] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២២២ ។

[34] សៀវភៅស្តីពីការពន្យល់អំពីនីតិវិធីជម្រះក្តីលើកទី១ ទំព័រទី ២៩ ។

## ២.៧.ការដាក់មធ្យោបាយតទល់ ឬការពារខ្លួន

បន្ទាប់ពីបានដាក់ពាក្យសុំលើអង្គសេចក្ដីនៃរឿងក្ដីហើយ ដើមចោទនឹងធ្វើសេចក្ដីថ្លែងការណ៍គាំទ្រពាក្យសុំរបស់ខ្លួន ទើបចុងចម្លើយធ្វើសេចក្ដីថ្លែងការណ៍ជាក្រោយ ។ សេចក្ដីថ្លែងការណ៍របស់ដើមចោទគេហៅថា មធ្យោបាយតទល់ រីឯសេចក្ដីថ្លែងការណ៍របស់ចុងចម្លើយវិញគេហៅថា មធ្យោបាយការពារខ្លួន ។

នៅក្នុងមធ្យោបាយតទល់របស់ដើមចោទជាដំបូង ដើមចោទធ្វើសេចក្ដីថ្លែងការណ៍អះអាងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលជាការទាមទារតាមផ្លូវបណ្ដឹង ។ ក៏ប៉ុន្តែ ដោយសារថា អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិជាក់លាក់ណាមួយមិនអាចទទួលស្គាល់ដោយផ្ទាល់បាន ហេតុនេះហើយ តុលាការត្រូវ ប្រើប្រាស់នូវវិធីធ្វើសេចក្ដីសន្និដ្ឋានតាមភាពសមហេតុផល ដើម្បីធ្វើការកំណត់នូវអត្ថិភាព ឬ នត្ថិភាព នៃសិទ្ធិនោះ ។ មានន័យថា ជាដំបូងត្រូវកំណត់ថា តើសិទ្ធិនោះត្រូវបានទទួលស្គាល់ថាបានបង្កើតឡើងពីមុន មកដែរឬទេ ហើយប្រសិនបើសិទ្ធិនោះត្រូវបានទទួលស្គាល់ថាបានបង្កើតឡើង នោះត្រូវកំណត់ថា តើសិទ្ធិនោះ ត្រូវបានទទួលស្គាល់ថាបានរលត់នាពេលក្រោយមកដែរឬទេ។ ប្រសិនបើសិទ្ធិនោះ ត្រូវបានទទួលស្គាល់ថា បានបង្កើតឡើង តែមិនត្រូវបានទទួលស្គាល់ថាបានរលត់នាពេលក្រោយមកទេសិទ្ធិនោះ ត្រូវបានវិនិច្ឆ័យថា មានអត្ថិភាពនៅពេលបច្ចុប្បន្ន ។ ហេតុនេះហើយ ដើម្បីឱ្យតុលាការសម្រេចថា សិទ្ធិដែលជាខ្លឹមសារ នៃការទាមទាររបស់ខ្លួន មានអត្ថិភាព ដើមចោទត្រូវធ្វើការអះអាងអំពីអង្គហេតុមួយឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌតាមផ្លូវច្បាប់ ដើម្បីឱ្យសិទ្ធិនោះមានអានុភាពតាមផ្លូវច្បាប់ ។ ឧទាហរណ៍ ក្នុងករណីដែល ក អះអាងថា ខ្លួនមានសិទ្ធិទាមទារឱ្យ ខ បង់ប្រាក់ចំនួន ១០ លានរៀល ដែលជាថ្លៃលក់ទិញរថយន្ត ក ត្រូវ អះអាងអំពីអង្គហេតុដែលថា កិច្ចសន្យាមួយនៃការលក់ទិញរថយន្តដែលជាកម្មសិទ្ធិរបស់ ក ទៅឱ្យ ខ ក្នុង តម្លៃ ១០ លានរៀល ត្រូវបានបង្កើតឡើងរវាង ក និង ខ នៅកាលបរិច្ឆេទជាក់លាក់មួយ ហើយពេលកំណត់ ត្រូវបង់ប្រាក់ បានមកដល់ហើយ ។ ប្រសិនបើ ខ មិនទទួល ស្គាល់នូវអង្គហេតុនេះ ក ត្រូវផ្ដល់ភស្តុតាងដើម្បីបញ្ជាក់អំពីអង្គហេតុនេះ ។

ក្នុងការឆ្លើយតបទៅនឹងការអះអាងនេះ ចុងចម្លើយអាចនឹងធ្វើវិវាទអំពីអត្ថិភាពនៃសិទ្ធិទាមទារឱ្យបង់ ថ្លៃលក់ដែល ក អះអាង ដោយលើកឡើងថា ខ្លួនធ្វើវិវាទអំពីអានុភាពកិច្ចសន្យា ដោយហេតុថា ទោះបីជាកិច្ចសន្យាត្រូវបានបង្កើតឡើងពិតមែនក៏ដោយ ប៉ុន្តែ មានការភ័ន្តច្រឡំនៅក្នុងការបង្ហាញឆន្ទៈដែល ក គួរណាស់តែបានដឹងហើយដោយហេតុនេះ ខ្លួននឹងលុបចោលកិច្ចសន្យា ឬ ម្យ៉ាងទៀត កាតព្វកិច្ចបង់ប្រាក់ បានរលត់ទៅហើយ ព្រោះថ្លៃលក់ទិញនោះ ត្រូវបានបង់រួចរាល់ហើយ ឬ កាតព្វកិច្ចបង់ប្រាក់ បានរលត់ទៅហើយ ព្រោះ អាជ្ញាយុកាលបានផុតទៅហើយ ហើយការផុតអាជ្ញាយុកាលនេះ ត្រូវបានលើកឡើង ។ ការអះអាងទាំងអស់នេះ គឺជាមធ្យោបាយការពារខ្លួនរបស់ ចុងចម្លើយ ហើយគេហៅថា ការតវ៉ា ។ នៅក្នុងករណីនេះ ប្រសិនបើចុងចម្លើយ មិនបានអះអាងអំពីអង្គហេតុដែលថា មានការភ័ន្តច្រឡំនៅក្នុងការបង្ហាញឆន្ទៈក្នុងការចុះកិច្ចសន្យា ហើយថា ក គួរណាស់តែ

បានដឹងអំពីការណ៍នេះ ឬ អង្គហេតុដែលថា ថ្លៃលក់ទិញនោះ ត្រូវបានបង់រួចហើយ ទេនោះ នៅពេលចេញសាលក្រម តុលាការនឹងមិនយកអង្គហេតុទាំងនេះ ទៅធ្វើជាមូលដ្ឋាននៃសាលក្រមឡើយ នៅក្នុង គោលការណ៍នៃការទាញហេតុផល ។ ចំពោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ប្រសិនបើចុងចម្លើយមិនបានលើកឡើងនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ មិនបានអះអាងអំពីអង្គហេតុដែលថា ខ្លួនបានលើក ឡើង អាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះ ក្រៅកាលបរិច្ឆេទតុលាការនោះចុងចម្លើយនឹងមិនទទួលបាននូវសាលក្រមដែលត្រូវនឹងចិត្តរបស់ខ្លួន ដោយផ្អែកលើអង្គហេតុនេះឡើយ ។

ប្រសិនបើដើមចោទមិនទទួលស្គាល់ អង្គហេតុតវ៉ាដែលជាមធ្យោបាយការពារខ្លួននេះ ចុងចម្លើយត្រូវស្នើសុំ ឱ្យពិនិត្យភស្តុតាង ដើម្បីបញ្ជាក់អំពីអង្គហេតុនេះ ។ ម្យ៉ាងទៀត ដើម្បីតទល់នូវការតវ៉ារបស់ចុងចម្លើយ ដើមចោទអាចលើកឡើងនូវអង្គហេតុផ្សេងទៀត ដែលអាចបដិសេធចោលនូវអានុភាពនៃការការតវ៉ានោះ ។ ឧទាហរណ៍ ដើម្បីបដិសេធការតវ៉ាអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិដើមចោទអាចធ្វើសេចក្តីថ្លែងការណ៍ អំពីអង្គហេតុដែលជាមូលហេតុនៃការផ្អាកអាជ្ញាយុកាល[35] ។ នេះគេហៅថា ការតវ៉ាឆ្លើយតបចំពោះការតវ៉ា ។ សេចក្តីថ្លែងការណ៍ដែលជាមធ្យោបាយតទល់ ឬ ការពារខ្លួន អាចបែងចែកជាការដាក់ពាក្យសុំ និងសេចក្តីថ្លែងការណ៍ផ្សេងទៀត ទៅតាមលក្ខណៈ នៃសកម្មភាពរបស់ភាគី។ ការដាក់ពាក្យសុំ និង សេចក្តីថ្លែងការណ៍ផ្សេងទៀត ដែលភាគីបានធ្វើ គេហៅថា ការទាញហេតុផល ។ ពាក្យសុំគឺជាសកម្មភាពរបស់ភាគីដែលទាមទារសុំឱ្យតុលាការធ្វើសកម្មភាពជាក់លាក់ណាមួយ ដូចជាការចេញសាលក្រម ការចេញដីកាសម្រេច ការពិនិត្យភស្តុតាង ការធ្វើសកម្មភាពចាំបាច់ នៅក្នុងនីតិវិធីអនុវត្តដោយបង្ខំ ជាអាទិ៍ ។ ក្រៅពីពាក្យសុំលើអង្គសេចក្តីនៃរឿងក្តី ដែលជាពាក្យសុំឱ្យចេញសាលក្រមចុងក្រោយ មានពាក្យសុំមួយបែបទៀត គឺពាក្យសុំលើចំណុចបន្ទាប់បន្សំ ឬ លើចំណុចដែលមិនទាក់ទងដោយផ្ទាល់ទៅនឹងការទាមទារ ដូចជា ពាក្យសុំឱ្យដកហូតសមត្ថកិច្ចជំនុំជម្រះ ពាក្យសុំប្តឹងជំទាស់ចៅក្រម និង ពាក្យសុំផ្ទេររឿងក្តី ជាអាទិ ។ ពាក្យសុំទាំងនេះ គេហៅថា ពាក្យសុំក្នុងបណ្តឹង ។ សេចក្តីថ្លែងការណ៍ សំដៅទៅលើសកម្មភាពដែល តាមរយៈនោះ ភាគីធ្វើការរៀបរាប់ ឬ ផ្តល់នូវការយល់ ឃើញ ឬ មតិរបស់ខ្លួន ទៅឱ្យតុលាការ ។ ក្នុងចំណោមនោះ ការរៀបរាប់អំពីការយល់ឃើញអង្គហេតុ ហៅថា សេចក្តីថ្លែងការណ៍អំពីអង្គហេតុ ។ ចំណែកការរៀបរាប់អំពីការយល់ឃើញ និង មតិយោបល់តាមផ្លូវច្បាប់ ហៅថា សេចក្តីថ្លែងការណ៍អំពីអង្គច្បាប់ ។ ក្នុងចំណោមសេចក្តីថ្លែងការណ៍ទាំងនេះ សេចក្តីថ្លែងការណ៍ដែល មិនមែនជាការឆ្លើយតបនឹងសេចក្តីថ្លែងការណ៍របស់ភាគីម្ខាងទៀត ហើយដែលរៀបរាប់អំពីអង្គហេតុឯករាជ្យ ឬ មតិយោបល់តាមផ្លូវច្បាប់ គេហៅជាពិសេសថា ការអះអាង ។ ជាគោលការណ៍ នៅក្នុងនីតិវិធីនៃបណ្តឹងដែលធ្វើឡើងតាមគោលការណ៍នៃការ

[35] ក្រមរដ្ឋប្បវេណី មាត្រា ៤៨៩ ។

ទាញហេតុផលអង្គហេតុដែលមិនបានអះអាងដោយភាគីមិនអាចយក មកធ្វើជាមូលដ្ឋាននៃសាលក្រមបានទេ ។ ហេតុនេះហើយ ការអះអាងអំពីអង្គហេតុ មានសារៈសំខាន់ណាស់ ជាពិសេសនៅក្នុងចំណោមសកម្មភាពទាំងអស់ ។

ពេលដាក់មធ្យោបាយតទល់ ឬការពារខ្លួន ភាគី ត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន នៅពេលសមរម្យ ទៅតាមដំណាក់កាលនៃរឿងក្តី[36]។ នេះគឺជានិមិត្តរូបមួយនៃគោលការណ៍ជាមូលដ្ឋាន នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលថា ភាគី ត្រូវអនុវត្តបណ្តឹងរដ្ឋប្បវេណី ដោយសុចរិត និង ស្មោះត្រង់[37] ។ ក្នុងករណីដែលមានមូលហេតុ សមរម្យពិសេសភាគីអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន នៅពេលណាក៏បាន មុនពេលដែល ការវិនិច្ឆ័យលើបណ្តឹងត្រូវបានបញ្ចប់ គឺ មុនពេលដែលការទាញហេតុផលដោយផ្ទាល់មាត់ត្រូវបានបញ្ចប់ ។ ប៉ុន្តែប្រសិនបើពុំមានមូលហេតុពិសេសទេ ភាគីត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន នៅពេលសមរម្យ ទៅតាមដំណាក់កាលនៃការជម្រះក្តី ។ ពេលវេលាសមរម្យ សំដៅទៅលើឱកាស ឬ ដំណាក់កាល នៅក្នុងនីតិវិធី ដែលត្រូវបានសង្ឃឹមថា គួរដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន ដើម្បីដោះស្រាយវិវាទ ឱ្យបានលឿន និង ត្រឹមត្រូវ ។ ដោយសារថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីដែលធ្វើឡើងដើម្បីបំភ្លឺជាមុន នូវចំណុច វិវាទ ដោយត្រូវរៀបចំការអះអាងរបស់ភាគី និង រៀបចំភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទនោះ ដែលត្រូវពិនិត្យ នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីអាចរៀបចំការជម្រះក្តីឱ្យមានប្រសិទ្ធិភាព និង ដោយសមូហវិធីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ហេតុនេះហើយ ភាគីត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនទាំងអស់នៅក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ លើកលែងតែក្នុង កាលៈទេសៈដែលមិនទាន់អាចដាក់បាននៅពេលនេះ។ ដើម្បីឆ្លើយតបទៅនឹងការទាមទារនេះ ភាគីត្រូវធ្វើ ការស្រាវជ្រាវជាមុន ឱ្យបានហ្មត់ចត់ អំពីទំនាក់ទំនងអង្គហេតុចំពោះសាក្សី ឬ ភស្តុតាងដទៃទៀត[38]។ ហេតុនេះហើយ ក្រោយពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញ ហេតុផលហើយ ជាគោលការណ៍ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីទៀត នៅពេល ធ្វើការទាញហេតុផលដោយផ្ទាល់មាត់បានឡើយ ។ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ភាគីត្រូវលើកឡើងនូវការអះអាងរបស់ខ្លួន ឱ្យបាន ទាន់ពេលវេលា ត្រូវឆ្លើយតបទៅនឹងការអះអាងរបស់ភាគីម្ខាងទៀត ហើយត្រូវធ្វើការស្នើសុំឱ្យពិនិត្យភស្តុតាង ចំពោះ អង្គហេតុដែលមានវិវាទ ។ ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួន ដែលបានដាក់ទៅតុលាការ យឺតយ៉ាវ មិនត្រូវនឹងពេលសមរម្យ ដោយចេតនា ឬដោយកំហុសដ៏ធ្ងន់ធ្ងររបស់ភាគី តុលាការអាចចេញដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួន

[36] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៣ ។

[37] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៤ ។

[38] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩២ ។

នោះ បាន តាមពាក្យសុំរបស់ភាគីម្ខាងទៀត ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រសិនបើតុលាការយល់ឃើញថា ការដាក់មធ្យោបាយនោះ ធ្វើឱ្យមានការយឺតយ៉ាវក្នុងការបញ្ចប់ និតិវិធីនៃបណ្តឹង[39]។ នេះក៏ព្រោះថា ប្រសិនបើអនុញ្ញាតឱ្យភាគីណាម្ខាងដាក់ មធ្យោបាយតទល់ ឬ ការពារខ្លួន ក្រោយពេលវេលាសមរម្យ ដោយមានបំណង ឬចេតនាធ្វើការអូសបន្លាយនីតិវិធីនៃបណ្តឹងនោះវាមិនត្រឹមតែធ្វើឱ្យរំខានដល់ភាគីម្ខាងទៀតប៉ុណ្ណោះទេ វាថែមទាំងជាបន្ទុកមួយដ៏ធ្ងន់សម្រាប់តុលាការផងដែរ ដែលការណ៍នេះនឹងធ្វើឱ្យប៉ះពាល់ប្រសិទ្ធិភាពនៃប្រព័ន្ធតុលាការទាំងមូលតែម្តង ។ ក្នុងគោលគំនិត និងអត្ថន័យនៃមធ្យោបាយតទល់ ឬ ការពារខ្លួន ដែលភាគីបានដាក់មានភាពមិនច្បាស់លាស់ ហើយតុលាការបានទាមទារឱ្យបំភ្លឺ តែភាគីមិនផ្តល់ការបំភ្លឺជាចាំបាច់ ឬ មិនបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកំណត់ឱ្យបំភ្លឺទេ តុលាការអាចលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួននោះបាន[40] ។

## ២.៨.ការកំណត់ចំណុចវិវាទ

បន្ទាប់ពីភាគីធ្វើសេចក្តីថ្លែងការណ៍រួច តុលាការត្រូវរៀបចំចំណុចវិវាទ។ នៅក្នុងការរៀបចំណុចវិវាទ តុលាការត្រូវរៀបចំការអះអាងភាគីជាមុនសិន(២.៣.១) បន្ទាប់មកធ្វើការរៀបចំចំណុចវិវាទ(២.៣.២)។

### ២.៨.១.ការអះអាងរបស់ភាគី

កម្មវត្ថុនៃបណ្តឹង គឺជាសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលដើមចោទបានអះអាងនូវការទាមទារតាមផ្លូវបណ្តឹង។ ប៉ុន្តែ ដើម្បីឱ្យតុលាការអាចធ្វើការសម្រេចអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តនោះបាន ត្រូវតែបំភ្លឺនូវអង្គហេតុដោយធ្វើការអះអាងរបស់ភាគី។ នៅពេលធ្វើការអះអាង ចុងចម្លើយអាចធ្វើការទទួលស្គាល់ ឬមិនទទួលស្គាល់ ឬធ្វើការតវ៉ាផងដែរ។ ការរៀបចំការអះអាងតុលាការត្រូវស្នើសុំឱ្យភាគីដកការអះអាងពីអង្គហេតុ ដែលមិនមានប្រយោជន៍ចំពោះការសម្រេចអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិដែលជាកម្មវត្ថុបណ្តឹង។ នៅពេលភាគីណាម្ខាងអះអាងអំពីអត្ថិភាពនៃអង្គហេតុណាមួយ អាកប្បកិរិយារបស់ភាគីត្រូវបែងចែកជាបួនប្រភេទគឺៈ

(ទី១) ភាគីម្ខាងទៀតធ្វើសេចក្តីថ្លែងការណ៍បដិសេធនូវអត្ថិភាពនៃអង្គហេតុនោះ គឺការបដិសេធ ត្រូវធ្វើការបញ្ជាក់ដោយភស្តុតាង

(ទី២) ភាគីនោះធ្វើសេចក្តីថ្លែងការណ៍ទទួលស្គាល់នូវអត្ថិភាពនៃអង្គហេតុនោះ គឺការសារភាព ករណីនេះមិនចាំបាច់បញ្ជាក់ភស្តុតាងទេ[41]

[39] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៤ កថាខណ្ឌទី១ ។

[40] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៤ កថាខណ្ឌទី២ ។

[41] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១២៣ កថាខណ្ឌទី ២ ។

(ទី៣) ភាគីធ្វើសេចក្ដីថ្លែងការណ៍ថាខ្លួនមិនបានដឹងអំពីអត្ថិភាពនៃអង្គហេតុនោះទេ គឺការមិនបានដឹងត្រូវចាត់ទុកថាការតវ៉ាអំពីអង្គហេតុត្រូវបញ្ជាក់ដោយភស្តុតាង និង

(ទី៤) ភាគីនោះមិនឆ្លើយអ្វីទាំងអស់ គឺត្រូវបានសន្មតថាជាការសារភាពចំពោះអង្គហេតុ ។

### ២.៨.២.ការរៀបចំចំណុចវិវាទ

ចំណុចវិវាទគឺជាចំណុចទាំងឡាយណាដែលភាគីប្រកែកគ្នា។ ក្នុងការកំណត់ចំណុចវិវាទតុលាការត្រូវពិចារណាអំពីអាកប្បកិរិយារបស់ភាគីដូចការអះអាងរបស់ភាគីខាងលើ។ នៅពេលភាគីបដិសេធ នោះអង្គហេតុគឺជាចំណុចវិវាទ ហើយប្រសិនបើភាគីសារភាព នោះអង្គហេតុមិនមែនជាចំណុចវិវាទទេ[42]។ ចំពោះភាគីឆ្លើយថាមិនដឹង និងភាគីមិនឆ្លើយអ្វីទាំងអស់។ នៅក្នុងករណីដែលឆ្លើយថាមិនបានដឹង ជាការតវ៉ាចំពោះអង្គហេតុ ដែលនាំឱ្យក្លាយជាចំណុចវិវាទ ។ ចំណែក ករណីដែលភាគីមិនបានឆ្លើយអ្វីទាំងអស់ ចាត់ទុកថាភាគីបានសារភាពចំពោះអង្គហេតុនោះ លើកតែក្នុងករណីតុលាការពិចារណាទៅលើអាកប្បកិរិយារបស់ភាគីនោះបានតវ៉ាចំពោះអង្គហេតុនោះ[43]។ ដោយសារតែក្រមនីតិវិធីរដ្ឋប្បវេណីបានចាត់ទុកថាបានសារ ភាពហេតុនេះមិនមែនជាចំណុចវិវាទឡើយ លើកលែងតែមានករណីដូចខាងលើ។

## ២.៩.ការរៀបចំភស្តុតាង និងការពិនិត្យភស្តុតាងជាឯកសារ

### ២.៩.១ ការរៀបចំភស្តុតាង

ភាពចាំបាច់នៃការពិនិត្យភស្តុតាង ឬអត់ គឺអាស្រ័យទៅលើការទទួលស្គាល់ ឬមិនទទួលស្គាល់។ ដូច្នេះដើម្បីឱ្យមានភាពច្បាស់លាស់ថា ការពិនិត្យលើភស្តុតាងណាមួយ ការទទួស្គាល់ ឬមិនទទួលស្គាល់របស់ភាគី។ អង្គហេតុដែលមានវិវាទរវាងភាគី ត្រូវធ្វើការបញ្ជាក់ដោយភស្តុតាង។

ភស្តុតាងមាន ០៥ប្រភេទគឺៈ

- ការសាកសួរសាមីភាគី
- ការសាកសួរសាក្សី
- ការធ្វើកោសលវិច័យ
- ភស្តុតាងជាឯកសារ និង
- ការត្រួតពិនិត្យ។

ដើម្បីឱ្យតុលាការធ្វើការពិនិត្យភស្តុតាង នៅពេលទាញហេតុផលផ្ទាល់មាត់បាន គឺចាំបាច់ត្រូវមានការៀបចំភស្តុតាងជាមុនសិន ។ ហេតុនេះក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំភស្តុតាង។

[42] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៦ កថាខណ្ឌទី២ ។

[43] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៦ កថាខណ្ឌទី១ ។

### ២.៩.២.ការពិនិត្យភស្តុតាងជាឯកសារ

ជាគោលការណ៍ កាពិនិត្យភស្តុតាងត្រូវធ្វើឡើងទៅតាមការស្នើសុំរបស់គូភាគី ។ ប៉ុន្តែក្នុងករណីដែលតុលាការមិនមានភាពជឿជាក់លើភស្តុតាងដែលបានស្នើសុំឲ្យពិនិត្យនោះ ក្នុងករណីនេះតុលាការអាចធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន[44]។ នៅពេលស្នើសុំឲ្យពិនិត្យភស្តុតាង ភាគីត្រូវកំណត់ឲ្យបានជាក់លាក់ចំពោះអង្គហេតុដែលត្រូវបញ្ជាក់ ការស្នើសុំឲ្យពិនិត្យភស្តុតាងភាគីអាចធ្វើនៅមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ អាចធ្វើនៅមុនកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់បានដែរ[45]។ ចំពោះការពិនិត្យភស្តុតាងនៅក្នុងនីតិវិធីនេះ គឺមានតែភស្តុតាងជាឯកសារតែប៉ុណ្ណោះ[46]។ ចំណែកឯភស្តុតាងជាសាក្សីភាគីអាចស្នើសុំដាក់នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះបាន ប៉ុន្តែច្បាប់មិនបានអនុញ្ញាតឲ្យមានការសាកសួរសាក្សីនៅក្នុងដំណាក់កាលនេះឡើយ ។ ដោយហេតុថាតុលាការមិនអាចធ្វើការរៀបចំភស្តុតាងដោយខ្លួនឯងបាន ដូចនេះគឺត្រូវមានការស្នើសុំឱ្យពិនិត្យភស្តុតាង និងតុលាការធ្វើការសម្រេចទៅលើភស្តុតាងនោះ។

#### ២.៩.២.១.ការស្នើសុំឱ្យពិនិត្យភស្តុតាង

ភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាង ត្រូវកំណត់ឱ្យបានជាក់លាក់ នូវអង្គហេតុដែលត្រូវធ្វើការបញ្ជាក់។ ភាគីដែលបានស្នើសុំពិនិត្យភស្តុតាង គប្បីបំភ្លឺឱ្យបានច្បាស់លាស់អំពីអង្គហេតុដែលត្រូវបញ្ជាក់ និងទំនាក់ទំនងរវាងអង្គហេតុនោះ និងភស្តុតាង ។ ការស្នើសុំឱ្យពិនិត្យភស្តុតាងក៏អាចធ្វើមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានដែរ។ ចំពោះការស្នើសុំឱ្យសាកសួរភាគី និងសាមីភាគី បើអាចធ្វើបាន ត្រូវធ្វើជាមួយគ្នាស្រេចតែម្តង។ ការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ត្រូវធ្វើឡើងដោយផ្តល់ឯកសារដែលសាមីភាគីមាន ឬ ដោយដាក់ពាក្យសុំដោយតុលាការឱ្យបង្គាប់ឱ្យម្ចាស់ឯកសារផ្តល់ឯកសារនោះមក។

#### ២.៩.២.២.ការសម្រេចទៅលើភស្តុតាង

តុលាការត្រូវសម្រេចថាត្រូវទទួលយក ឬ មិនទទួលយកនូវការស្នើសុំពិនិត្យភស្តុតាងរបស់ភាគីតាមរយៈដីកាសម្រេច ។ ការចេញដីកាសម្រេច គឺខុសពីសាលក្រម ដោយមិនចាំបាច់ធ្វើជាលាយលក្ខណ៍អក្សរក៏បានដែរ ឱ្យតែជូនដំណឹងតាមនីតិវិធីដែលអាចទទួលស្គាល់ថាសមរម្យ។ នៅក្នុងករណីដែលបានជូនដំណឹងអំពីការសម្រេច ក្រឡាបញ្ជីត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវហេតុការណ៍ និងវិធីជូនដំណឹងនោះដាក់ក្នុងសំណុំរឿង។

---

[44] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១២៤ ។

[45] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១២៥ ។

[46] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០៦ ។

## ២.១០.ការបំបែក និង ការរួមបញ្ចូលរឿងក្ដី នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចបំបែករឿងក្ដីមួយ ទៅជារឿងក្ដីផ្សេងៗ ហើយធ្វើការជម្រះក្ដីលើរឿងក្ដីទាំងនោះ ដាច់ដោយឡែកពីគ្នាបាន[47] ។ នេះហៅថា ការបំបែករឿងក្ដី ។ ឧទាហរណ៍ ប្រសិនបើនៅក្នុងបណ្ដឹងតែមួយ ដើមចោទបានទាមទារឱ្យចុងចម្លើយសងប្រាក់កម្ចីផង និង បង់ប្រាក់ថ្លៃលក់ទិញផង តុលាការអាចបំបែកការទាមទារឱ្យបង់ប្រាក់ថ្លៃលក់ទិញ ចេញពីបណ្ដឹងនោះ ហើយធ្វើការជម្រះក្ដីដាច់ដោយ ឡែកបាន។ បញ្ច្រាសទៅវិញ តុលាការក៏អាចរួមបញ្ចូលរឿងក្ដីផ្សេងៗដែលកំពុងត្រូវបានចាត់ការនៅក្នុង តុលាការតែមួយ ហើយធ្វើការជម្រះក្ដីសរុប ដោយនីតិវិធីតែមួយបានដែរ ។ នេះហៅថា ការរួមបញ្ចូលរឿងក្ដី ។ ទោះបីជាក្នុងករណីដែលការទាមទារពីរយ៉ាង ត្រូវបានដាក់នៅក្នុងបណ្ដឹងតែមួយក៏ដោយ ប្រសិនបើការទាមទារនីមួយៗ មានខ្លឹមសារពាក់ព័ន្ធគ្នាតែបន្តិចបន្តួច ហើយការជំនុំជម្រះលើការទាមទារមួយ អាចនឹងធ្វើបានឆាប់ជាងការទាមទារមួយទៀត នោះវាជាការសមស្របដែលត្រូវបំបែករឿងក្ដី ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលរឿងក្ដីជាច្រើនដែលមានខ្លឹមសារទាក់ទងគ្នាកំពុងត្រូវបានចាត់ការដាច់ដោយឡែកពីគ្នា ជាញឹកញាប់វាជារឿងសមហេតុផលក្នុងការជំនុំជម្រះរឿងក្ដីទាំងអស់នេះរួមគ្នា តាមរយៈការរួមបញ្ចូលរឿងក្ដី[48] ។

## ២.១១.ការធ្វើកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

### ២.១១.១.កំណត់ហេតុនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

គ្រប់កាលបរិច្ឆេទទាំងអស់នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចាំបាច់ត្រូវតែមានកំណត់ហេតុពីព្រោះនេះជាការតម្រូវរបស់បទបញ្ញត្តិច្បាប់ ។ ហើយចំពោះមូលហេតុដែលក្រមនីតិវិធីរដ្ឋប្បវេណីតម្រូវបែបនេះដោយសារតែពិនិត្យឃើញអំពីភាពចាំបាច់នៃកំណត់ហេតុនេះ។ កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមានភាពចាំបាច់បំផុតសម្រាប់ដំណើរការនេះដោយតុលាការត្រូវឲ្យក្រឡាបញ្ជីធ្វើកំណត់ហេតុនេះនៅគ្រប់កាលបរិច្ឆេទនីមួយៗ[49]។ ចំពោះ មូលហេតុដែលច្បាប់តម្រូវឲ្យតុលាការត្រូវតែធ្វើកំណត់ហេតុនេះអាចដោយសារតែកំណត់ហេតុនេះជា មូលដ្ឋានដ៏សំខាន់បំផុតសម្រាប់តុលាការក្នុងការយល់អំពីសញ្ញាណ និងខ្លឹមសារលម្អិតនៃរឿងក្ដីនីមួយៗ ម្យ៉ាងវិញទៀតតុលាការក៏អាចមានភាពងាយស្រួលក្នុងការរៀបចំចំណុចវិវាទផងដែរ។ ម្យ៉ាងទៀត កំណត់ហេតុនេះក៏មានសារៈសំខាន់ណាស់ នៅពេលដែលភាគីធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការ

---

[47] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៩ កថាខណ្ឌទី១ ។

[48] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៩៩ កថាខណ្ឌទី ២ ។

[49] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០៩ ។

ជាន់ខ្ពស់ ដោយហេតុថាកំណត់ហេតុនេះនឹងក្លាយជាមូលដ្ឋានមួយ សម្រាប់តុលាការជាន់ខ្ពស់អាចធ្វើការពិនិត្យការជំនុំជម្រះនៅតុលាការដើមបាន ។

ជាទូទៅនៅមុនពេលចាប់ផ្តើមនៃកាលបរិច្ឆេទនីមួយៗនៃនីតិវិធីត្រៀម មុននឹងដំណើរការនីតិវិធី ក្រឡាបញ្ជីតែងតែបំពេញចំណុចជារូបមន្តនៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមដែលចំណុចជារូបមន្តនេះ មានដូចជា

ក.សញ្ញាណនៃរឿងក្តី

ខ.ឈ្មោះចៅក្រម និង ក្រឡាបញ្ជី

គ.ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និងអ្នកបកប្រែ (នៅក្នុងករណីដែលមាន)

ឃ.ពេលវេលា និងទីកន្លែង

ក្រៅពីនេះមានចុះហត្ថលេខាប្រធានក្រុមប្រឹក្សា និងក្រឡាបញ្ជីផងដែរ[50] ។ ហើយនៅក្នុងដំណើរការនៃនីតិវិធីត្រៀមវិញ តុលាការក៏ត្រូវធ្វើការកត់ត្រានូវចំណុចជាសារធាតុមួយចំនួនផងដែរ គឺនៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវសេចក្តីសង្ខេប អំពីសកម្មភាពដែលបានធ្វើឡើងនៅកាលបរិច្ឆេទនីមួយៗ ហើយពិសេសត្រូវកត់ត្រាឱ្យបានច្បាស់លាស់ នូវចំណុចដូចខាងក្រោម[51]៖

ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងចម្លើយរបស់ចុងចម្លើយចំពោះការទាមទារនោះ

ខ.ខ្លឹមសារនៃអង្គហេតុដែលបានអះអាង និងការស្នើសុំឱ្យពិនិត្យភស្តុតាង។

គ.ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ភាគីចំពោះអង្គហេតុដែលបានអះអាងដោយភាគីដោយភាគីម្ខាងទៀត និងការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះភាពត្រឹមត្រូវនៃឯកសារ។

ឃ.ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ និងការទទួលស្គាល់ការទាមទារ។

ង.ចំណុចដែលតុលាការបានបង្គាប់ឱ្យកត់ត្រា និងចំណុចដែលតុលាការអនុញ្ញាតឱ្យកត់ត្រាតាមការទាមទាររបស់ភាគី។

ច.ការសម្រេចសេចក្តីដែលបានធ្វើឡើងនៅកាលបរិច្ឆេទនោះ ដោយមិនធ្វើជាលាយលក្ខណ៍អក្សរ។

ការតវ៉ារបស់ភាគី និងអ្នកដទៃដែលពាក់ព័ន្ធត្រូវបានកើតឡើងប្រសិនបើក្រឡាបញ្ជីមិនបានកត់ត្រា ឱ្យបានត្រឹមត្រូវ។ ដូច្នេះភារកិច្ចរបស់ក្រឡាបញ្ជីត្រូវមើលឱ្យបានគ្រប់ជ្រុងជ្រោយ ព្រមទាំងកត់ត្រាឱ្យបានច្បាស់លាស់នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

[50]ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១១០ ។

[51] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១១១ ។

### ២.១១.២.ការសម្រេចអំពីការប្តឹងតវ៉ានឹងកំណត់ហេតុ

ចំពោះកំណត់ហេតុដែលត្រូវបានតាក់តែងឡើង មិនមែនសុទ្ធតែជានាំនូវភាពត្រឹមត្រូវទាំងស្រុង នោះទេ ហេតុនេះហើយទើបបទប្បញ្ញត្តិច្បាប់អនុញ្ញាតឲ្យភាគី ឬ បុគ្គលដទៃទៀតដែលពាក់ព័ន្ធ ប្តឹងតវ៉ា ចំពោះសេចក្តីកត់ត្រាក្នុងកំណត់ហេតុនេះ[52] ។

ការប្តឹងតវ៉ានេះ គឺបទប្បញ្ញត្តិមិនបានចែងថាត្រូវធ្វើជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ទេ ប៉ុន្តែបើតាមពិនិត្យលើទៅលើអត្ថន័យទាំងមូលមានក្នុងមាត្រា១១២ ក្រមនីតិវិធីរដ្ឋប្បវេណីគឺ ភាគី ឬជនដែលពាក់ព័ន្ធនោះ អាចធ្វើការប្តឹងតវ៉ាដោយផ្ទាល់មាត់បាន។ នៅក្នុងករណីដែលមានការតវ៉ាអំពីកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ប្រសិនបើក្រឡាបញ្ជីយល់ឃើញថា ការតវ៉ានេះ មានភាពត្រឹមត្រូវ ឬ ចៅក្រមយល់ឃើញថា ការតវ៉ានេះមានភាពត្រឹមត្រូវ ហើយបង្គាប់ឲ្យក្រឡាបញ្ជីកែតម្រូវ នោះក្រឡាបញ្ជីត្រូវតែកែតម្រូវលើកំណត់ហេតុនោះ ។ ប៉ុន្តែបើនៅក្នុងករណីដែលយល់ឃើញថា ការតវ៉ានោះមានភាពមិនត្រឹមត្រូវ នោះក្រឡាបញ្ជីត្រូវកត់ត្រានូវសេចក្តីតវ៉ានៅក្នុងកំណត់ហេតុនោះ។

## ផ្នែកទី៣ ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបានចាប់ផ្តើមឡើង ដូច្នេះវាក៏ត្រូវបញ្ចប់ទៅវិញផងដែរ ។ ប៉ុន្តែ សួរថា តើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបញ្ចប់នៅពេលណា? (៣.១) ហើយនៅ ពេលដែលបញ្ចប់មានសកម្មភាពអ្វីខ្លះដែលតុលាការត្រូវបំពេញ? (៣.២) ហើយនៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបញ្ចប់នឹងបង្កើតនូវអានុភាព(៣.៣)អ្វីខ្លះ?។

### ៣.១.ការមកដល់ពេលនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ចំពោះពេលវេលានៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺមានភាពប្រែប្រួលទៅតាមគោលបំណងនៃនីតិវិធី ។ ជាការពិត នៅពេលដែលគោលបំណងនៃនីតិវិធី ត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបំពេញ នោះនឹងធ្វើឲ្យនីតិវិធីនេះត្រូវបានបញ្ចប់ (៣.១.១) ។ ប៉ុន្តែ ទោះបីជាគោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនទាន់ត្រូវបានបំពេញក៏ដោយ មានករណីខ្លះក៏ធ្វើឲ្យនីតិវិធីនេះត្រូវបានបញ្ចប់ផងដែរ (៣.១.២) ។

#### ៣.១.១.គោលបំណងត្រូវបានបំពេញ

ជាគោលការណ៍ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបង្កើតឡើងដើម្បីធ្វើឲ្យមានភាពងាយស្រួល និងឆាប់រហ័ស ដល់ការទាញហេតុផលដោយផ្ទាល់មាត់ តាមរយៈការកំណត់ចំណុចវិវាទ និងរៀបចំភស្តុតាងឲ្យបានច្បាស់លាស់[53] ។ ដូច្នេះ នៅពេលដែលចំណុចវិវាទ និងភស្តុតាងត្រូវបាន កំណត់ជាក់លាក់ហើយ

[52] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១១២ កថាខណ្ឌទី១ ។

[53] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១០៣ ។

នោះនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក៏ត្រូវបញ្ចប់ដែរ ។ ចំពោះការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចំនួនប៉ុន្មានលើក ដើម្បីបំពេញនូវគោលបំណងនោះ គឺច្បាប់មិនបានកំណត់នោះទេ ដូច្នេះតុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តែមួយលើកក៏បាន ឬច្រើនលើកក៏បាន សំខាន់គឺតុលាការអាចស្វែងរកចំណុចវិវាទ និងរៀបចំភស្តុតាងរួចរាល់ ។

### ៣.១.២.គោលបំណងមិនទាន់បានបំពេញ

ក្នុងករណីដែលគោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនទាន់បានបំពេញ តាមរយៈការរៀបចំចំណុចវិវាទ និងភស្តុតាងនោះទេ យើងសង្កេតឃើញថា មានករណីមួយចំនួនដែលធ្វើឲ្យ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបញ្ចប់ផងដែរ រួមមានៈ

#### ៣.១.២.១. ការបញ្ចប់ដោយសកម្មភាពរបស់ភាគី

**ក.ការដកពាក្យបណ្តឹង**

ជាសកម្មភាពបណ្តឹងមួយរបស់ដើមចោទ ដោយដកមួយភាគ ឬទាំងស្រុងនូវការទាមទារ ក្នុងបណ្តឹងដែលដើមចោទបានដាក់ទៅតុលាការមានសមត្ថកិច្ច ដើម្បីអាចឱ្យតុលាការចេញសាលក្រមទាមទាររបស់ខ្លួន ។ ដើមចោទអាចដកពាក្យបណ្តឹងគ្រប់ពេល រហូតដល់សាលក្រមចុងក្រោយ ។ ដើមចោទត្រូវដកពាក្យបណ្តឹងមុនពេល ដែលចុងចម្លើយបានដាក់ឯកសារត្រៀមអំពីអង្គសេចក្តី ឬ នីតិវិធីនានា ។ ពាក្យសុំដកត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ លើកលែងតែកាលបរិច្ឆេទនៃការចូលរួមក្នុងនីតិវិធីរបស់តុលាការ ។ ការដកពាក្យបណ្តឹងនោះត្រូវការយល់ព្រមដោយជាក់ស្តែងពីចុងចម្លើយ ដែលចាត់ទុកថាយល់ព្រមបើរយៈពេល ២សប្តាហ៍បានកន្លងផុតចាប់ពីថ្ងៃបានទទួលនូវការបញ្ជូនលិខិតដកពាក្យបណ្តឹងនោះ ។

ផ្នែកដែលត្រូវបានដកពាក្យបណ្តឹង ត្រូវចាត់ទុកថា មិនបានចាត់ការតាំងពីដំបូង ។ ជាគោលការណ៍ការដកពាក្យបណ្តឹង គឺអាចដាក់វិញបានដែរ ។ ប៉ុន្តែបើដើមចោទបានដកពាក្យបណ្តឹងក្រោយចេញសាលក្រមចុងក្រោយអំពីអង្គសេចក្តី មិនអាចដាក់ពាក្យបណ្តឹងដូចគ្នាម្តងទៀតបានទេ[54] ។

ដើមចោទអាចសុំឱ្យតុលការសងវិញ ចំនួនពាក់កណ្តាលនៃពន្ធដាក់ពាក្យបណ្តឹងរបស់ខ្លួន នៅមុនចប់កាលបរិច្ឆេទនៃការទាញហេតុផលលើកដំបូង[55] ។

**ខ.កំណត់ហេតុសះជា**

54 មាត្រា ២១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី

55 មាត្រា ៦១ កថាខណ្ឌទី៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ការសះជា សំដៅទៅលើកិច្ចសន្យាមួយដែលភាគីបានព្រមព្រៀងគ្នាបញ្ចប់វិវាទដែលមានរវាងគ្នា និងគ្នាដោយធ្វើសម្បទានទៅវិញទៅមក[56] ។ ជាសកម្មភាពដែលដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាបញ្ចប់វិវាទដោយធ្វើសម្បទានគ្នាទៅវិញទៅមក ឬ លះបង់នូវការអះអាងរបស់ខ្លួនអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹង ដោយធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការសះជា នោះនៅចំពោះមុខតុលាការដែលមានសមត្ថកិច្ច ។

ការសះជា ការទាមទារនៃបណ្តឹងជាប្រភេទបណ្តឹងទាក់ទងនឹងទំនាក់ទំនងគតិយុត្ត និងសិទ្ធិ មិនមែនជាបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។ ការព្រមព្រៀងរបស់ភាគីអំពីសិទ្ធិ និងទំនាក់ទំនងគតិយុត្តត្រូវមានខ្លឹមសារស្របច្បាប់ មិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ។ កំណត់ហេតុសះជាអាចបញ្ចប់បណ្តឹងដែលកំណត់ហេតុនេះមានអានុភាពដូចសាលក្រមស្ថាពរ[57] ហើយអាចយកទៅអនុវត្តបាន ដែលអាចក្លាយជាលិខិតអនុវត្ត[58]។

**គ.ការទទួលស្គាល់ការទាមទារ ឬលះបង់នូវការទាមទារ**

ការលះបង់នូវការទាមទារ គឺជាសេចក្តីថ្លែងការណ៍តាមផ្លូវបណ្តឹងរបស់ដើមចោទដែលទទួលស្គាល់ដោយគ្មានល័ក្ខខ័ណ្ឌ ការទាមទារតាមផ្លូវបណ្តឹងរបស់ខ្លួន ពុំមានភាពត្រឹមត្រូវ ។ រីឯការទទួលស្គាល់នូវការទាមទារវិញ គឺជាសេចក្តីថ្លែងការណ៍តាមផ្លូវបណ្តឹងរបស់ចុងចម្លើយ ដែលទទួលស្គាល់ដោយគ្មានល័ក្ខខ័ណ្ឌ ថាការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទមានមូលហេតុត្រឹមត្រូវ ។ ការលះបង់នូវការទាមទារ ឬការទទួលស្គាល់នូវការទាមទារ ត្រូវធ្វើនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សា[59]។

ករណីដែលភាគីអវត្តមាន នោះនឹងធ្វើឲ្យនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបញ្ចប់ ដែលពេលខ្លះភាគីអវត្តមានម្ខាង ហើយពេលខ្លះទៀតអវត្តមានទាំងសងខាងតែម្តង ។

**ឃ.ករណីអវត្តមានភាគីម្ខាង**

ភាគីអវត្តមានតែម្ខាង ពេលខ្លះអាចបណ្តាលមកពីដើមចោទ ហើយពេលខ្លះទៀតក៏អាច បណ្តាលមកពីចុងចម្លើយផងដែរ ។

**-ករណីអវត្តមានដើមចោទ**

56 មាត្រា ៧២៤ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា
57 ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២២២ ។
58 ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៣៥០ កថាខណ្ឌទី២ ចំណុច ឈ. ។
59 ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២២១ ។

ប្រសិនបើដើមចោទ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀម សម្រាប់ការទាញហេតុផលទេ តុលាការត្រូវច្រានចោលនូវការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំងមុខ[60] ។ ជាការពិតណាស់ ដើមចោទ គឺជាបុគ្គលដែលដាក់ពាក្យ បណ្តឹងមកតុលាការដើម្បីឲ្យតុលាការសម្រេចពីអត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តរបស់ខ្លួន ហេតុនេះប្រសិនបើដើមចោទមិនបង្ហាញខ្លួនទេ នោះមានន័យថា ដើមចោទគ្មានឆន្ទៈក្នុង ការធ្វើទៅតាមនីតិវិធីបណ្តឹងនោះទេ ហេតុដូច្នេះ តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទ ។

**-ករណីអវត្តមានចុងចម្លើយ**

ប្រសិនបើចុងចម្លើយ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការត្រូវបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុ ផលដោយភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទីមួយនៃការទាញហេតុផលដោយផ្ទាល់មាត់[61] ។ ចំណុចនេះ តុលាការមិនអាចចេញសាលក្រមកំបាំងមុខ ដូចករណីដើមចោទ អវត្តមាននោះទេ ពីព្រោះថា ករណីដែលចុងចម្លើយមិនបានចូលរួមក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចមានករណីដែលការទាមទាររបស់ដើមចោទមិនសមហេតុផលសោះ ដូច្នេះទាមទារឲ្យមានការទាញហេតុផលដោយផ្ទាល់មាត់។ ម្យ៉ាងទៀត តុលាការក៏មិនអាចចេញសាលក្រមដែលទទួលស្គាល់ការទាមទារដោយមិនធ្វើទៅតាមការទាញហេតុផលដោយផ្ទាល់មាត់ដែរ ដូច្នេះហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់វិញ ។

**ង.ករណីអវត្តមានភាគីទាំងសងខាង**

ក្នុងករណីដែលភាគីទាំងសងខាងមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយមិនបានដាក់ពាក្យសុំឲ្យតុលាការកំណត់កាលបរិច្ឆេទជាថ្មីទៀត ក្នុងអំឡុងពេល ០១(មួយ)ខែទេ នោះត្រូវចាត់ទុកថា បានដកពាក្យបណ្តឹង ។ ហើយក៏ត្រូវចាត់ទុកថា បានដកពាក្យបណ្តឹងផងដែរ ក្នុងករណីដែលភាគីទាំងសងខាងមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ០២(ពីរ)ដងជាប់គ្នា[62]។ ការចាត់ទុកយ៉ាងនេះ ពីព្រោះថា ភាគីទាំងសងខាងគ្មានចំណាង និងសេចក្តីត្រូវការក្នុងការធ្វើទៅតាមនីតិវិធីបណ្តឹងនោះទេ ។

### ៣.១.២.២. ការបញ្ចប់ដោយស្វ័យប្រវត្តិ

**ក.ករណីភាគីទទួលមរណភាព**

60 ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២០០ កថាខណ្ឌទី១ ។

61 ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២០១ កថាខណ្ឌទី១ ។

62 ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២១៩ ។

ប្រសិនបើភាគីបានទទួលមរណភាព ហើយគ្មានអ្នក ទទួលបន្តនូវសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង នោះនីតិវិធីនៃបណ្តឹងត្រូវបានបញ្ចប់។ ក្នុងករណីនេះ តុលាការត្រូវចេញសាលក្រមបញ្ចប់បណ្តឹងនោះ ។

**ខ.សិទ្ធ ឬ កាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងត្រូវធ្លាក់ទៅលើបុគ្គលតែម្នាក់**

ករណីរួមបញ្ចូលនីតិបុគ្គល ហើយសិទ្ធិ និងកាតព្វកិច្ចនោះបានធ្លាក់ទៅលើបុគ្គលតែ ម្នាក់ដែលគ្មានអ្នកបន្តសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹង នោះនីតិវិធីត្រូវបានបញ្ចប់ ។ ក្នុងករណីនេះ តុលាការត្រូវចេញសាលក្រមបញ្ចប់បណ្តឹងនោះ ។

ដូច្នេះឃើញថាប្រសិនបើកើតមានករណីដូចខាងលើនោះនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបញ្ចប់ផងដែរ ។

## ៣.២.សកម្មភាពដែលត្រូវបានបំពេញនៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបញ្ចប់ តុលាការត្រូវធ្វើការបញ្ជាក់ ពីអង្គហេតុដែលត្រូវបំភ្លឺ (៣.២.១) ជាមួយភាគី ហើយបន្ទាប់ពីនោះ គឺធ្វើការកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ (៣.២.២) តែម្តង ។

### ៣.២.១. ការបញ្ជាក់ពីអង្គហេតុដែលត្រូវធ្វើការបំភ្លឺ

នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់នូវការរៀបចំចំណុច វិវាទ និងភស្តុតាងរួចហើយ តុលាការត្រូវបញ្ជាក់ជាមួយភាគីទាំងសងខាង អំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់ តាមរយៈការពិនិត្យភស្តុតាង នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដែលនឹងធ្វើបន្ទាប់ពីនោះ[63] ។បាននន័យថា តុលាការ និងភាគីទាំងសងខាង ត្រូវធ្វើការបញ្ជាក់ថាតើអង្គហេតុណាខ្លះដែលជាចំណុចវិវាទ ហើយដែលត្រូវក្លាយជាកម្មវត្ថុនៃការពិនិត្យភស្តុតាង ហើយតុលាការ និងភាគីទាំងសងខាង ត្រូវមានការទទួលស្គាល់រួមគ្នាចំពោះបញ្ហានេះ ដើម្បីអាចធ្វើការពិនិត្យភស្តុតាងដោយសមូហវិធីនៅពេលទាញហេតុផលដោយផ្ទាល់មាត់បាន ។

### ៣.២.២.ការកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចប់សព្វគ្រប់ហើយតុលាការត្រូវកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលផ្ទាល់មាត់ ហើយកោះហៅភាគីឱ្យមកចូលរួមសវនាការ[64]នៅក្នុងការកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវធានាថាភាគី សងខាងអាចមានវត្តមានបាន

63 ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០៧ ។

64 ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១១៣ ។

ដើម្បីគោរពនូវគោលការណ៍ចំពោះមុខ។[65] តុលាការត្រូវកំណត់កាលបរិច្ឆេទតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិ ។ ការប្តូរកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ មិនត្រូវបានអនុញ្ញាតទេ លើកលែងតែមានមូលហេតុមិនអាចជៀសវាងបាន ។ ស្តីពីការកោះហៅឲ្យចូលរួមនៅកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចជូនដំណឹងអំពីកាលបរិច្ឆេទ ឬដោយបញ្ជូនដីកាកោះក៏បាន ។[66]

### ៣.៣.អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានបញ្ចប់ ប្រសិនបើភាគីបានដាក់នូវ មធ្យោបាយតទល់ ឬការពារខ្លួនមកកាន់តុលាការ ជាគោលការណ៍តុលាការនឹងធ្វើការលើកចោលនូវ មធ្យោបាយតទល់ ឬការពារខ្លួន (៣.៣.១) នោះ ។ ប៉ុន្តែ គោលការណ៍នេះ មិនមានលក្ខណៈដាច់ខាតនោះទេ គឺ មានករណីលើកលែង (៣.៣.២) មួយចំនួនផងដែរ ។

#### ៣.៣.១.ការលើកចោលមធ្យោបាយតទល់ ឬការពារខ្លួន

ជាគោលការណ៍ ក្រោយពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលរួចហើយ ភាគីមិន អាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មីបានទៀតទេ[67]។ ប្រសិនបើអនុញ្ញាតឲ្យភាគីអាចដាក់ មធ្យោបាយតទល់ ឬការពារខ្លួន នៅក្រោយការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាននោះ នឹងធ្វើឲ្យចំណុចវិវាទដែលត្រូវបានកំណត់រួចរាល់ តាមរយៈការរៀបចំនូវការអះអាងរបស់ភាគី និងភស្តុតាងដែលត្រូវពិនិត្យ ពុំមានខ្លឹមសារអ្វីឡើយ ។ ហេតុនេះ ប្រសិនបើភាគី ដាក់នូវមធ្យោបាយតទល់ ឬការពារខ្លួនក្រោយពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការនឹងធ្វើការសម្រេចលើកចោលនូវមធ្យោបាយតទល់ ឬការពារខ្លួននោះ ។

#### ៣.៣.២.ករណីលើកលែង

ករណីលើកលែង ដែលតុលាការសម្រេចទទួលយកមធ្យោបាយតទល់ ឬការពារខ្លួន រួមមាន៖

- មធ្យោបាយទាក់ទងនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិ ដូចជា អត្ថិភាព ឬនត្ថិភាពនៃសមត្ថកិច្ចតុលាការ អត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការដកហូតសមត្ថកិច្ចជំនុំជម្រះ ជាអាទិ៍ ។

- មធ្យោបាយថ្មីនោះ មិនធ្វើឲ្យមានការយឺតយ៉ាវដល់នីតិវិធីបណ្តឹង ឧទាហរណ៍ ករណីដែលភាគី បានស្នើសុំឲ្យពិនិត្យភស្តុតាងដែលអាចពិនិត្យភ្លាមៗបានដូចជា ឯកសារដែលភាគីដាក់តាមខ្លួនមក តុលាការនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬសាក្សីដែលភាគីនាំមកតុលាការ ជាមួយជាដើម ។

---

[65] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១១៥ ។

[66] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៤២ ។

[67] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០៨ កថាខណ្ឌទី១ ។

- ករណីដែលភាគីបានធ្វើសេចក្តីបញ្ជាក់ដំបូងថា ខ្លួនមិនអាចដាក់មធ្យោបាយនោះ មុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ដោយគ្មានកំហុស ដូចជា ករណីដែលភាគីអះអាងអំពីអង្គហេតុដែលកើតឡើង នៅក្រោយនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ករណីដែលស្នើសុំឲ្យពិនិត្យភស្តុតាងដែលទើបតែត្រូវបានរកឃើញ ជាអាទិ៍[68] ។ ហេតុនេះករណីដូចបានរៀបរាប់ខាងលើនោះតុលាការអាចសម្រេចទទួលយកមធ្យោបាយតទល់ ឬការពារខ្លួនបាន។

[68] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០៨ ។

# ជំពូកទី២

# ការរកឃើញលើការអនុវត្តជាក់ស្តែងក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផល

នៅក្នុងផ្នែកនេះយើងនឹងធ្វើការបកស្រាយដោយផ្អែកទៅលើការអនុវត្តជាក់ស្តែងក្នុងសាលាដំបូងខេត្តកំពង់ឆ្នាំង។ សាលាដំបូងកំពង់ឆ្នាំង ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៨២ បច្ចុប្បន្ននេះ សាលាដំបូងខេត្តកំពង់ឆ្នាំង មានប្រធាន០១(មួយ)រូប ចៅក្រមពេញសិទ្ធិចំនួន០៦(ប្រាំមួយរូប) និងចៅក្រមកម្មសិក្សា ០១ (មួយ) រូប និងក្រឡាបញ្ជីចំនួន ១៩ ទាំងក្រឡាបញ្ជីកម្មសិក្សា[69]។ ក្រៅពីនេះ ក៏មានលេខាធិការដ្ឋានរដ្ឋបាល តុលាការដែលជាស្ថាប័នជំនួយផ្នែករដ្ឋបាលដល់សាលាដំបូងផងដែរ ។ ដើម្បីដឹងអំពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅសាលាដំបូងខេត្តកំពង់ឆ្នាំង ដើម្បីកាន់តែច្បាស់អំពីការចាប់ផ្តើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល(ចំណុចទី១) ការដំណើការសកម្មភាពនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (ចំណុចទី២) និងការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (ចំណុចទី៣) នឹងមានបង្ហាញដូចខាងក្រោម៖

## ផ្នែកទី១.ការចាប់ផ្តើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ដើម្បីអាចឱ្យនីតិវិធីរដ្ឋប្បវេណីដំណើរការបានរហូតមាននីតិវិធីត្រៀងមសម្រាប់ការទាញហេតុផលបានច្បាស់ណាស់ថាត្រូវមានការដាក់ពាក្យបណ្តឹងជាមុនសិន ដែលអ្នកដាក់ពាក្យបណ្តឹងនោះមានភាគី អ្នកតំណាង ឬអ្នកអាណាព្យាបាលជាអាទិ៍។ បន្ទាប់ពីមានអ្នកដាក់ពាក្យបណ្តឹងហើយត្រូវមានការទទួលពាក្យបណ្តឹងការពិនិត្យពាក្យបណ្តឹងចប់សព្វគ្រប់ហើយតុលាការនឹងធ្វើការកំណត់កាលបរិច្ឆេទ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល(១.១) ប៉ុន្តែទោះជាយ៉ាងណាក្តីកាលបរិច្ឆេទក៏ត្រូវបានផ្លាស់ប្តូរ(១.២) ផងដែរ ក្រោយពេលដែលកំណត់កាលបរិច្ឆេទនៃការទាញហេតុផលរួចហើយនោះតុលាការត្រូវធ្វើការកោះហៅភាគី។ នៅក្នុងការកោះហៅភាគីតុលាការត្រូវបង្គាប់ឱ្យដើមចោទបង់ប្រាក់(១.៣)ជាមុនសម្រាប់ធ្វើការកោះហៅ និងត្រូវអនុវត្តនូវវិធីកោះហៅ (១.៤) ឱ្យបានត្រឹមត្រូវផងដែរ។

### ១.១.ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅពេលដែលពាក្យបណ្តឹងត្រូវបានបញ្ជូនមកកាន់តុលាការ ប្រសិនបើពិនិត្យឃើញថាពាក្យបណ្តឹង នោះត្រឹមត្រូវហើយ តុលាការនឹងកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលភ្លាម។ នៅក្នុងការកំណត់កាលបរិច្ឆេទ តុលាការតែងតែសាកសួរភាគីដើមចោទ ឬអ្នកតំណាងដោយអាណត្តិ របស់ដើមចោទជាមុន ថាតើមានពេលវេលាអាចចូលរួមក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅថ្ងៃណាដែរ ? ហើយនៅពេលដែលដើមចោទ ឬអ្នកតំណាងដោយអាណត្តិរបស់ដើមចោទ បញ្ជាក់ពីថ្ងៃ ដែលអាចចូលរួមបានតុលាការ

[69] ដីការសម្រេចស្តីពីការបែងចែកសំណុំរឿងរដ្ឋប្បវេណី លេខ៥៦៦៧ រ.ប ៦៣១/២០ ។

នឹងធ្វើការផ្ទៀងផ្ទាត់មើលថា តើថ្ងៃនោះ តុលាការមានដាក់កម្មវិធីធ្វើនីតិវិធីអ្វីខ្លះ ? ដើម្បីបង្ការខ្លាចជាន់កម្មវិធីគ្នា ។ ប្រសិនបើមិនមានបញ្ហាទេតុលាការនឹងកំណត់ថ្ងៃនោះ ដើម្បីធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ការសាកសួរជាមុននេះ គឺដើម្បីធានាឲ្យភាគីអាចចូលរួមបានជៀសវាងការដាក់ពាក្យសុំលើកនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នាំឲ្យអូសបន្លាយ ពេលវេលាក្នុងនីតិវិធីបណ្តឹង ហើយក៏ជាការគោរពនូវគោលការណ៍ចំពោះមុខផងដែរ ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើពេលវេលាដែលភាគីស្នើសុំនោះមិនសមរម្យ តុលាការនឹងកំណត់កាល បរិច្ឆេទនេះ ដោយឆន្ទានុសិទ្ធិតែម្តង។

ថ្វីត្បិតតែច្បាប់បានផ្តល់សិទ្ធិអំណាចដល់តុលាការ ក្នុងការកំណត់យកថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃ ឈប់សម្រាកផ្សេងទៀតដែលកំណត់ដោយច្បាប់ ឬបទដ្ឋានគតិយុត្ត ដើម្បីធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក្នុងករណីមិនអាចជៀសវាងបានក៏ដោយ ក៏នៅក្នុងការអនុវត្ត គឺតុលាការមិនដែលយកថ្ងៃ សៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀតដែលកំណត់ដោយច្បាប់ ឬបទដ្ឋានគតិយុត្ត មកធ្វើនីតិវិធីត្រៀមសម្រាប់ទាញហេតុផលនោះទេ ។ ដោយសារថា គូភាគីមិន ទាន់បានយល់អំពីផ្នែកច្បាប់ឲ្យបានទូលំទូលាយនៅឡើយ នៅពេលដែលតុលាការកំណត់យកថ្ងៃទាំងនោះ គូភាគីសន្មតថាតុលាការកំណត់កាលបរិច្ឆេទខុសហើយនាំគ្នាមិនមកបង្ហាញខ្លួននៅកាលបរិច្ឆេទនោះ ហើយគូភាគីមួយចំនួនទៀត នាំគ្នារិះគន់អំពីការងាររបស់តុលាការទៀតផង ។ លើសពីនេះនៅការកំណត់មិនអាចធ្វើការកំណត់តាមច្បាប់កំណត់ទាំងស្រុងនោះទេ ពោលគឺរយៈពេល ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីពាក្យបណ្តឹងត្រូវបានដាក់នោះទេ មូលហេតុធ្វើដូចនេះដោយហេតុថា ចៅក្រមនិងក្រឡាបញ្ជីចំនួនតិច ហើយសំណុំរឿងមានច្រើន មិនអាចធ្វើការដោះស្រាយទៅតាមច្បាប់កំណត់នោះទេ។

### ១.២.ការស្នើសុំលើកពេលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ការប្តូរកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនត្រូវបានអនុញ្ញាតទេ លើកលែងតែមានករណីដែលមានមូលហេតុមិនអាចជៀសវាងបាន ។ ក្នុងករណីដែលភាគីម្ខាងណាបាន ដាក់ពាក្យស្នើសុំប្តូរកាលបរិច្ឆេទ ភាគីនោះត្រូវធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់អំពីមូលហេតុដែលការ ប្តូរកាលបរិច្ឆេទនោះត្រូវធ្វើជាចាំបាច់។ ជាការអនុវត្តនៅពេលភាគីមានបំណងស្នើសុំប្តូរកាលបរិច្ឆេទ ភាគីត្រូវស្នើសុំជាលាយល័ក្ខណ៍អក្សរ ដោយដាក់ទៅកាន់រដ្ឋបាលតុលាការ ដោយមានការបញ្ជាក់អំពី មូលហេតុ និងភស្តុតាងនានាដើម្បីគាំទ្រដល់មូលហេតុដែលខ្លួនបានលើកឡើង ។ បន្ទាប់ពីនេះ រដ្ឋបាលតុលាការនឹងធ្វើការបែងចែកទៅកាន់ចៅក្រមទទួលបន្ទុកសំណុំរឿង ដើម្បីពិនិត្យ ពិចារណា និងសម្រេច ។ ចំពោះការសម្រេចរបស់ចៅក្រមនៅក្នុងការសុំប្តូរកាលបរិច្ឆេទនេះ គឺផ្តោតទៅលើមូលហេតុដែលមិនអាចជៀសវាងបាន ដែលអាចមានទាំងទៅលើភាគីផ្ទាល់ ឬ អ្នកតំណាងដោយអាណត្តិ ។ ដូចនេះ តុលាការត្រូវពិចារណាថា តើមូលហេតុនោះជាមូលហេតុដែលមានលក្ខណៈសមស្រប ឬ

យ៉ាងណា? អាចទទួលយកបានឬអត់អំពីមូលហេតុស្នើសុំនោះ ប៉ុន្តែដើម្បីគោរពនូវគោលការណ៍ចំពោះមុខ តុលាការតែងតែយល់ព្រមចំពោះការស្នើសុំនោះ ។[70]

### ១.៣.ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

ប្រាក់ដែលត្រូវចំណាយ សម្រាប់ធ្វើការកោះហៅ ជាប្រភេទនៃប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ដែលដើមចោទត្រូវទទួលបន្ទុកក្នុងការបង់ជាមុន ។ ហេតុនេះ តុលាការនឹងធ្វើការបង្គាប់ឲ្យដើមចោទបង់ តាមរយៈដីកាបង្គាប់ឲ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ដោយកំណត់អំឡុងពេលសមរម្យ ។

ជាក់ស្តែងនៅសាលដំបូងខេត្តកំពង់ឆ្នាំង គឺតុលាការកំណត់ឱ្យភាគីដែលដាក់ពាក្យបណ្ដឹងធ្វើការបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ តាមរយៈដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ដោយកំណត់ចំនួនពន្ធដែលត្រូវបង់ចំនួន ១០០,០០០ (ដប់ម៉ឺន) រៀល។ ក្នុងករណីដើមចោទមិនបានបង់ប្រាក់នោះទេ តុលាការនឹងលើកបណ្ដឹងចោលដោយដីកាសម្រេច បើមានការយល់ព្រមពីចុងចម្លើយ ។ ប៉ុន្តែ បើដើមចោទបានបង់ប្រាក់សម្រាប់កោះហៅនោះរួចរាល់ តុលាការនឹងបង្គាប់ឲ្យក្រឡាបញ្ជីធ្វើការកោះហៅ ។[71]

### ១.៤.ការកោះហៅ

ថ្វីត្បិតតែការកោះហៅតាមកាលបរិច្ឆេទ អាចធ្វើដោយបញ្ជូនដីកាកោះ ឬ ដោយជូនដំណឹងអំពីកាលបរិច្ឆេទ ទៅអ្នកដែលបានបង្ហាញខ្លួននៅតុលាការចំពោះបណ្តឹងដែលពាក់ព័ន្ធក៏ដោយ ក៏ការអនុវត្តភាគច្រើនក្រឡាបញ្ជីដែលបំពេញភារកិច្ចការកោះហៅ តែងតែអនុវត្តដោយធ្វើការបញ្ជូនដីកាកោះ ដើម្បីមានរបាយការណ៍ស្តីពីការបញ្ជូនទុកក្នុងសំណុំរឿង។[72] ការធ្វើយ៉ាងដូច្នេះ គឺជាការបង្កើតនូវភស្តុតាង ដើម្បីបញ្ជាក់ថា ភាគីបានទទួលព័ត៌មានពីការកោះហៅ ហើយជៀសវាងការបដិសេធពីភាគីថាមិនបានទទួលដំណឹង។ ប្រសិនបើភាគីមានអ្នកតំណាងដោយអាណត្តិ តុលាការនឹងបង្គាប់ឲ្យក្រឡាបញ្ជីចាត់ចែង ដើម្បីកោះហៅតាមរយៈលិខិតអញ្ជើញមេធាវីផងដែរ ។[73]

ប៉ុន្តែ ប្រសិនបើភាគីមានភ្ជាប់នូវលេខទូរស័ព្ទមកជាមួយនៅក្នុងសំណុំរឿង ក្រឡាបញ្ជីនឹងធ្វើការទាក់ទងទៅភាគីតាមលេខទូរស័ព្ទនោះ ដើម្បីជូនដំណឹងអំពីការកោះហៅ នាកាលបរិច្ឆេទនៃនីតិវិធីត្រៀម សម្រាប់

[70] ឧបសម្ព័ន្ធទី១

[71] ឧបសម្ព័ន្ធទី២

[72] ឧបសម្ព័ន្ធទី៣

[73] ឧបសម្ព័ន្ធទី៤

ការទាញហេតុផល ហើយបង្គាប់ឲ្យភាគីមកទទួលដីកាកោះនៅតុលាការ ។ ប៉ុន្តែ ប្រសិនបើភាគី មិនបានមកទទួលដីកាកោះទេ ទើបក្រឡាបញ្ជីធ្វើការបញ្ជូនដីកាកោះនោះទៅកាន់ភាគី។[74]

លើសពីនេះកិច្ចការបញ្ជូនគឺបន្ទុករបស់ក្រឡាបញ្ជី ដោយអ្នកដែលធ្វើការប្រតិបត្តិការបញ្ជូនមានបុគ្គលិកប្រៃសណីយ៍ អាជ្ញាសាលា និងក្រឡាបញ្ជីខ្លួនឯងផ្ទាល់ ប៉ុន្តែការអនុវត្តជាក់ស្តែងករណីក្រៅខេត្តទើបធ្វើការបញ្ជូនតាមរយៈបុគ្គលិកប្រៃសណីយ៍ ហើយអាជ្ញាសាលានៅសាលាដំបូងខេត្តកំពង់ឆ្នាំងពុំមាននោះទេ ចំណែកក្រឡាបញ្ជីមានតួនាទី និងកិច្ចការជាច្រើនមិនអាចធ្វើការបញ្ជូនដោយផ្ទាល់ដៃដល់ភាគីបាននោះទេ ហេតុនោះហើយនៅសាលាដំបូងខេត្តកំពង់ឆ្នាំងធ្វើការបញ្ជូនតាមផ្លូវរដ្ឋបាល។[75]

## ផ្នែកទី២ ដំណើរការសកម្មភាពនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងការអនុវត្តជាក់ស្តែង តុលាការតែងតែធ្វើនីតិវិធីត្រៀមនៅក្នុងបន្ទប់របស់ខ្លួន ដោយមិនអនុញ្ញាតឱ្យអ្នកដែលមិនមានការពាក់ព័ន្ធចូលរួមនោះទេ។ នៅក្នុងដំណើរការនីតិវិធី ជាដំបូងតុលាការនឹង ប្រាប់ទៅភាគីអំពីនីតិវិធីដែលខ្លួនបំពេញ និងសមាសភាពតុលាការ រួចធ្វើសកម្មភាពនីតិវិធីសកម្មភាពនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយតុលាការត្រូវធ្វើការផ្សះផ្សា(២.១) ជាមុនសិន បើមិនទទួលបានលទ្ធផលនោះទេ តុលាការនឹងបន្តនីតិវិធី ដោយបង្គាប់ឲ្យភាគីធ្វើសេចក្តីថ្លែងការណ៍ (២.២) ហើយបន្ទាប់មក តុលាការនឹងធ្វើការរៀបចំចំណុចវិវាទ (២.៣) ដែលគូភាគី យល់មិនស្របគ្នា និងរៀបចំភស្តុតាង (២.៤) ដែលពាក់ព័ន្ធនឹងចំណុចវិវាទនោះ ។

### ២.១.ការផ្សះផ្សា

តុលាការនឹងសាកល្បងផ្សះផ្សាសិន លើកលែងតែយល់ឃើញថាមិនសមរម្យ ។ ក្នុងករណីដែលយល់ឃើញថា ការសាកល្បងផ្សះផ្សាមិនសមរម្យនោះទេ ដូចជាក្នុងករណីដែលសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងគឺជាសិទ្ធិ ឬកាតព្វកិច្ចដែលមិនអាចចាត់ចែងដោយគ្រាន់តែផ្អែកលើការព្រមព្រៀងរបស់គូភាគីប៉ុណ្ណោះទេ ឬក្នុងករណីដែលអាកប្បកិរិយារបស់គូភាគីបង្ហាញយ៉ាងច្បាស់ថា ពួកគេគ្មានឆន្ទៈធ្វើការផ្សះផ្សានោះទេ តុលាការនឹងមិនធ្វើការណែនាំឲ្យភាគីធ្វើការផ្សះផ្សាគ្នាឡើយ ។

ប្រសិនបើភាគីមានបំណងផ្សះផ្សា តុលាការនឹងឲ្យភាគីដើមចោទលើកឡើងពីគោលជំហររបស់ ខ្លួន បន្ទាប់មក ឲ្យភាគីចុងចម្លើយបង្ហាញពីគោលជំហររបស់ខ្លួនដែរ ហើយបន្ទាប់ពីនោះ តុលាការនឹង ព្យាយាមស្វែងរកចំណុចរួមមួយ ដើម្បីឲ្យភាគីស្រុះស្រួលនឹងគ្នា។ បន្ថែមពីនោះ ដើម្បីឲ្យភាគីទាំង សងខាងបន្ថយនូវគោលជំហរ

[74] ឧបសម្ព័ន្ធទី៥

[75] ឧបសម្ព័ន្ធទី៦

រៀងៗខ្លួន តុលាការតែងតែលើកឡើងពីផលប្រយោជន៍ដែលភាគីស្រុះស្រួលគ្នា ដូចជាចំណេញពេលវេលា ប្រាក់កាស និងការរក្សានូវទំនាក់ទំនងជាដើម ទៅកាន់ភាគី ។

នៅក្នុងការអនុវត្ត តុលាការតែងតែធ្វើការផ្សះផ្សានៅចំពោះមុខភាគីទាំងសងខាងជាមួយគ្នាតែម្តង ពីព្រោះថា ការអនុវត្តយ៉ាងដូច្នេះ គឺដើម្បីបង្ហាញពីតម្លាភាពរបស់តុលាការនៅចំពោះមុខភាគី ហើយក៏ធ្វើឲ្យចំណេញពេលវេលាផងដែរ ។ ការផ្សះផ្សាអាចទទួលផលដូចជា ការទទួលស្គាល់ការទាមទារ ការសះជា និងការដកពាក្យបណ្តឹង ដែលក្នុងការអនុវត្តក៏មានការដកពាក្យបណ្តឹងផងដែរ។[76]

## ២.២.ការធ្វើសេចក្តីថ្លែងការណ៍របស់ភាគី

នៅក្នុងការធ្វើសេចក្តីថ្លែងការណ៍ ជាដំបូងតុលាការនឹងបង្គាប់ឲ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍ មុន (១) ហើយបន្ទាប់មកទើបឲ្យចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍តបវិញ (២) ។

### ២.២.១ ការធ្វើសេចក្តីថ្លែងការណ៍របស់ដើមចោទ

ចំពោះដើមចោទ តុលាការនឹងឲ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹង[77] ។ នៅក្នុងពាក្យបណ្តឹងដើមចោទនឹងធ្វើសេចក្តីថ្លែងការណ៍អំពី៖

(១)ខ្លឹមសារសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

(២)អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ

(៣)អង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាងដែលត្រូវធ្វើការបញ្ជាក់អំពីអង្គហេតុ ។

### ២.២.២.ការធ្វើសេចក្តីថ្លែងការណ៍របស់ចុងចម្លើយ

នៅពេលដែលដើមចោទធ្វើសេចក្តីថ្លែងការណ៍រួច តុលាការនឹងឲ្យចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍តបវិញ ។ សេចក្តីថ្លែងការណ៍តបដែលចុងចម្លើយនឹងធ្វើការឆ្លើយតបគឺ ការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះខ្លឹមសារសាលក្រមដែលដើមចោទទាមទារ។ ដោយជាក់ស្តែងដូចក្នុងសំណុំរឿង១២៩ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១៨ គឺភាគីមានការទទួលស្គាល់បីផ្នែក និងមិនទទួលស្គាល់មួយផ្នែក ដែលមានភាពដូចអ្វីដែលច្បាប់បានកំណត់។

## ២.៣.ការរៀបចំចំណុចវិវាទ

បន្ទាប់ពីភាគីធ្វើសេចក្តីថ្លែងការណ៍រួច តុលាការត្រូវធ្វើការរៀបចំចំណុចវិវាទ ។ នៅក្នុងការរៀបចំ ចំណុចវិវាទ តុលាការត្រូវរៀបចំសេចក្តីអះអាងរបស់ភាគីជាមុនសិន (២.៣.១) ហើយបន្ទាប់មកទើបធ្វើការ កំណត់នូវចំណុចវិវាទ (២.៣.២.) ។

[76] ឧបសម្ព័ន្ធទី៧

[77] ឧបសម្ព័ន្ធទី៨

### ២.៣.១.ការរៀបចំការអះអាងរបស់ភាគី

បន្ទាប់ពីភាគីធ្វើសេចក្ដីថ្លែងការណ៍រួច តុលាការនឹងធ្វើការពិចារណាអំពីអង្គហេតុដែលអាចកំណត់ ពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលឆ្លើយតបទៅនឹងច្បាប់សារធាតុ ។ ប្រសិនបើភាគី លើកឡើងនូវអង្គហេតុច្រើន ដែលមិនមានការពាក់ព័ន្ធនឹងរឿងក្ដី តុលាការនឹងប្រាប់ទៅភាគីឲ្យដកនូវការអះអាងនោះ ។ ចំពោះអង្គហេតុដែលភាគីអះអាង តុលាការនឹងពិចារណាថាតើអង្គហេតុណាខ្លះ ដែលភាគីទទួលស្គាល់ ហើយអង្គហេតុណាខ្លះដែលភាគីមិនទទួលស្គាល់ដោយសង្កេតទៅលើអាកប្បកិរិយា របស់ភាគី ដូចជាការ

-ការបដិសេធ

-ការសារភាព

-ការឆ្លើយមិនដឹងនិង

-ការនៅស្ងៀមមិនឆ្លើយតបអ្វីទាំងអស់ ។

បន្ទាប់ពីនោះ តុលាការនឹងធ្វើការញែកអង្គហេតុដែលភាគីទទួលស្គាល់មួយផ្នែក និងអង្គហេតុដែលភាគីមិនទទួលស្គាល់មួយផ្នែក ។

### ១.៣.២.ការកំណត់ចំណុចវិវាទ

ជាការពិតណាស់ ចំណុចវិវាទ គឺជាអង្គហេតុដែលភាគីប្រកែកគ្នា ហេតុនេះតាមរយៈការញែកអង្គ ហេតុដូចបានបញ្ជាក់ខាងលើ នឹងធ្វើឲ្យតុលាការអាចធ្វើការកំណត់ចំណុចវិវាទបាន ។ នៅក្នុងការអនុវត្តជាក់ស្ដែង តុលាការតែងតែបង្កើត ឬកំណត់នូវចំណុចវិវាទ ក្នុងលក្ខណៈជាសំណួរ ដូចជា ក្នុងរឿងជម្លោះដីធ្លី តុលាការបានកំណត់នូវចំណុចវិវាទថា តើដើមចោទ ពិតជាមានអត្ថិភាពនៃសិទ្ធិលើដីរបស់ចុងចម្លើយ និងការខូចខាត ផ្សេងទៀតដែរឬទេ ? ហើយមានក្នុងទំហំប៉ុន្មាន ? នេះដើម្បីអាចធ្វើការកំណត់ចំណុចវិវាទបាន។[78] បន្ទាប់មកធ្វើការបែងចែករៀបចំណុចវិវាទ និងចំណុចដែលភាគីព្រមព្រៀងគ្នាដោយផ្នែក។

## ២.៤.ការស្នើសុំឲ្យពិនិត្យភស្តុតាងដោយភាគី

នៅពេលដែលតុលាការកំណត់ចំណុចវិវាទហើយ តុលាការនឹងធ្វើការសួរបញ្ជាក់ ទៅភាគីថា តើអង្គហេតុដែលមានវិវាទនោះ ភាគីចង់បញ្ជាក់ដោយភស្តុតាងអ្វីដែរ ? បើភាគីមានអ្វីចង់បញ្ជាក់ ភាគីអាចស្នើសុំមកតុលាការ ដើម្បីឲ្យតុលាការធ្វើការពិនិត្យភស្តុតាងនោះ នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន ។ បន្ទាប់ពីនោះ ភាគីដែលធ្វើការអះអាងពីអង្គហេតុមានវិវាទ ដែលមានភស្តុតាងបញ្ជាក់ នឹងធ្វើការស្នើសុំមកតុលាការ ។ ភាគីដែលស្នើសុំឲ្យពិនិត្យភស្តុតាង ត្រូវកំណត់ឲ្យបាន ជាក់លាក់នូវអង្គហេតុដែលត្រូវបញ្ជាក់[79] ។

[78] ឧបសម្ព័ន្ធទី១០

[79] ឧបសម្ព័ន្ធទី៩

នៅក្នុងការអនុវត្ត ភស្តុតាងដែលភាគីស្នើសុំឲ្យពិនិត្យ យើងសង្កេតឃើញថា ភាគច្រើនជា សាក្សី និង ភស្តុតាងជាឯកសារ ។ បន្ទាប់ពីនោះ តុលាការនឹងធ្វើការញែកអង្គហេតុដែលភាគីទទួលស្គាល់មួយផ្នែក និងអង្គហេតុដែលភាគី មិនទទួលស្គាល់មួយផ្នែក ។

បន្ទាប់ពីស្នើសុំឱ្យពិនិត្យភស្តុតាង តុលាការ នឹងសម្រេចទទួលយក ឬមិនទទួលយកនូវការស្នើសុំពិនិត្យភស្តុតាងរបស់ភាគី តាមរយៈ ដីកាសម្រេច ។ នៅក្នុងការអនុវត្តជាក់ស្តែង ការចេញដីកាសម្រេច តុលាការតែងតែធ្វើឡើងដោយផ្ទាល់មាត់ ដោយជូនដំណឹងអំពីដីកាសម្រេចនេះនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតែម្តង។នៅក្នុងពេលជូនដំណឹងអំពីដីកាសម្រេចតុលាការនឹងបង្គាប់ឲ្យក្រឡាបញ្ជី បញ្ជាក់ឲ្យបាន ច្បាស់លាស់នូវហេតុការណ៍ និងវិធីជូនដំណឹងនោះ នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីដាក់ចូលក្នុងសំណុំរឿង។

## ២.៥.ការធ្វើកំណត់ហេតុនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការនឹងបង្គាប់ឲ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅគ្រប់កាលបរិច្ឆេទនីមួយៗ ។

កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលរួមមានៈ

(១) សញ្ញាណនៃរឿងក្តី

(២)កាលបរិច្ឆេទ និងទីកន្លែង

(៣)ឈ្មោះចៅក្រម និងក្រឡាបញ្ជី

(៤) អត្តសញ្ញាណភាគី

(៥) ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

(៦) សេចក្តីថ្លែងការណ៍របស់ដើមចោទ និងចុងចម្លើយ ។

មួយវិញទៀត កំណត់ហេតុត្រូវបញ្ជាក់នូវចំណុចសារជាតុដូចតទៅ

(ក)ខ្លឹមសារដែលស្នើសុំឱ្យសាលាដំបូងខេត្តកំពង់ឆ្នាំងចេញសាលក្រម

(ខ)ការអះអាងរបស់ភាគី

(គ)ការកំណត់ចំណុចព្រមព្រៀម និងចំណុចវិវាទ ។

លើសពីនេះដើម្បីឱ្យជាក់លាក់ និងមិនមានបញ្ហានៅពេលក្រោយថាភាគីណាមួយមិនបានចូលរួមតម្រូវឱ្យភាគីទាំងសងខាង ធ្វើការផ្តិតមេដៃស្តាំជាភស្តុតាង និងមានហត្ថលេខាមេធាវីផងដែរ[80] ។

[80] ឧបសម្ព័ន្ធទី១០

ចំពោះកំណត់ហេតុនេះ ភាគី ឬបុគ្គលដទៃទៀតដែលពាក់ព័ន្ធ អាចប្តឹងតវ៉ា ចំពោះសេចក្តីកត់ត្រាក្នុងកំណត់ហេតុនេះបាន ប៉ុន្តែការអនុវត្តនៅសាលាដំបូងខេត្តកំពង់ឆ្នាំង មិនដែលធ្លាប់ជួបប្រទះភាគីធ្វើការប្តឹងចំពោះកំណត់ហេតុស្តីពីនីតិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ។

## ផ្នែកទី៣ ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការនឹងធ្វើការបញ្ជាក់ពីអង្គហេតុដែលត្រូវធ្វើការបំភ្លឺ (៣.១) ទៅដល់ភាគី ហើយបន្ទាប់មកតុលាការនឹងធ្វើការកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ (៣.២) ។

### ៣.១.ការបញ្ជាក់អំពីអង្គហេតុដែលត្រូវធ្វើការបំភ្លឺ

នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់នូវការរៀបចំចំណុចវិវាទ និងភស្តុតាងរួចហើយ តុលាការត្រូវបញ្ជាក់ជាមួយភាគីទាំងសងខាង អំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់ តាមរយៈការពិនិត្យភស្តុតាង នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដែលនឹងធ្វើបន្ទាប់ពីនោះ ។ ការបញ្ជាក់នេះគឺអាស្រ័យទៅតាមភស្តុតាងដែលភាគីស្នើសុំឲ្យតុលាការពិនិត្យ ។ មានន័យថា ចំពោះអង្គហេតុ ដែលភាគីចង់បញ្ជាក់ដោយការពិនិត្យភស្តុតាង តុលាការនឹងធ្វើការបញ្ជាក់ម្តងទៀតទៅ ភាគីថាតើចំពោះអង្គហេតុនោះ ភាគីនឹងបញ្ជាក់ដោយភស្តុតាងមួយណា? ឬមួយភស្តុតាងដែលភាគីស្នើសុំឲ្យពិនិត្យនោះ នឹងត្រូវបញ្ជាក់ទៅលើអង្គហេតុទាំងមូល ឬចំណុចណាមួយជាដើម? ដើម្បីឲ្យមានភាពកាន់តែច្បាស់លាស់ ។ ការបញ្ជាក់នេះ ធ្វើឡើងដើម្បីឲ្យតុលាការ និងភាគីទាំងសងខាងមានការទទួលស្គាល់រួមគ្នា ដើម្បីអាចធ្វើការពិនិត្យភស្តុតាងដោយសមូហវិធី នៅពេលទាញហេតុផលដោយផ្ទាល់មាត់បានរលូន ។

### ៣.២.ការកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់ហើយ តុលាការនឹងកំណត់កាលបរិច្ឆេទ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយកោះហៅគូភាគីមកចូលរួម ។ នៅក្នុងការកំណត់កាលបរិច្ឆេទ តុលាការតែងតែសាកសួរភាគីទាំងសងខាងជាមុន ថាតើភាគីមានពេលវេលាអាចចូលរួមក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃណាដែរ? ហើយនៅពេលដែលភាគី ទាំងសងខាងបញ្ជាក់ពីថ្ងៃដែលអាចចូលរួមបាន តុលាការនឹងផ្ទៀងផ្ទាត់មើលថាតើថ្ងៃនោះតុលាការមានដាក់កម្មវិធីធ្វើនីតិវិធីផ្សេងដែរឬទេ ? ប្រសិនបើមិនមានបញ្ហាទេ តុលាការនឹងកំណត់ថ្ងៃនោះ ដើម្បីធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនភាគី ទាំងសងខាងមិនមានការឯកភាពគ្នា ឬពេលវេលាដែលភាគីស្នើសុំនោះ មិនសមរម្យនោះតុលាការនឹងកំណត់កាលបរិច្ឆេទនេះ ដោយឆន្ទានុសិទ្ធិតែម្តង ។ ចំពោះការកោះហៅឲ្យចូលរួមនៅកាល

បរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការនឹងធ្វើជូនដំណឹងដោយផ្ទាល់មាត់ នៅពេលនោះតែម្តង ដោយចាត់ទុកថា ភាគីបានទទួលដំណឹង ហើយមិនធ្វើដីកាកោះ ឬលិខិតអញ្ជើញនោះទេ។

# ជំពូកទី៣

# ការវិភាគប្រៀបធៀបរវាងការអនុវត្តជាក់ស្តែងដែលរកឃើញជាមួយនឹងទ្រឹស្តីគតិយុត្តដែលពាក់ព័ន្ធ

បន្ទាប់ពីបានសិក្សាទៅលើទ្រឹស្តីគតិយុត្ត និងការអនុវត្តជាក់ស្តែងក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលរួចមក យើងសង្កេតឃើញថា នៅក្នុងនីតិវិធីទាំងមូល គឺមានចំណុចដែលស្របនឹងលិខិតូបករណ៍គតិយុត្ត(ចំណុចទី១)ជាច្រើនដែលនឹងធ្វើការលើកយកចំណុចមួយចំនួន និងលេចចេញនូវចំណុចមួយចំនួនដែលមិនទាន់បានអនុវត្តពេញលេញតាមស្មារតីច្បាប់(ចំណុចទី២) ដោយសារតែជួបប្រទះនូវបញ្ហាប្រឈមនានា ។ ការស្គាល់នូវបញ្ហាប្រឈមនេះ គឺមានសារៈសំខាន់ណាស់ ពីព្រោះថា នៅពេលដែលបញ្ហាប្រឈមត្រូវបានបង្ហាញ នោះយើងអាចស្វែងរកដំណោះស្រាយ ដើម្បីលុបបំបាត់ នូវរាល់បញ្ហាទាំងនោះបាន ។

## ផ្នែកទី១ ចំណុចស្របគ្នាជាមួយលិខិតូបករណ៍គតិយុត្ត និងការអនុវត្តជាក់ស្តែង

លិខិតូបករណ៍គតិយុត្ត និងការអនុវត្តជាក់ស្តែងគឺមានភាពស្របគ្នាជាច្រើនដោយហេតុថាជាធម្មតាតុលាការធ្វើការចាត់ការនីតិវិធីដូចគ្នានូវអ្វីដែលច្បាប់បានកំណត់មក ហើយក្រោយពីការសិក្សាទៅលើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អំពីលិខិតូបករណ៍គតិយុត្ត និងបានចុះមកកម្មសិក្សានៅសាលាដំបូងខេត្តកំពង់ឆ្នាំងផ្ទាល់ឃើញថាចំណុចដែលស្របគ្នាមានភាពល្អប្រសើរទៅតាមស្មាតីច្បាប់មានដូច ការធ្វើសេចក្តីថ្លែងការណ៍របស់ភាគី (១.១)ការកំណត់ចំណុចវិវាទ (១.២)ការរៀបចំភស្តុតាង (១.៣)និងការធ្វើកំណត់ហេតុរបស់ក្រឡាបញ្ជី (១.៤) ។

### ១.១.ការធ្វើសេចក្តីថ្លែងការរបស់ភាគី

ដើមចោទការធ្វើសេចក្តីថ្លែងការណ៍អំពីពាក្យបណ្តឹង គឺធ្វើការលើកឡើងនូវអ្វីដែលដើមចោទទាមទារឱ្យតុលាការចេញដូចមានកំណត់ក្នុងមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី កថាខណ្ឌទី៣ ដែលក្រៅពីសរសេរនូវខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ដើមចោទគប្បីសរសេរឱ្យបានច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ អង្គហេតុសំខាន់ៗ នៃអង្គហេតុទាំងមូលដែលទាក់ទងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាង ។ បន្ថែមពីនេះមាត្រា ១០១ នៃក្រមដដែលនេះ កថាខណ្ឌទី២ បានកំណត់ថា នៅក្នុងឯកសារត្រៀម ត្រូវមានសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួន និងសេចក្តីថ្លែងការចំពោះមធ្យោបាយតទល់ ឬការពារខ្លួនរបស់ភាគីម្ខាងទៀត ។ នៅក្នុងការអនុវត្តនៅសាលាដំបូងខេត្តកំពង់ឆ្នាំងឃើញថា ភាគីដើមចោទធ្វើសេចក្តីថ្លែងការណ៍ទៅតាមពាក្យបណ្តឹងដែលបានដាក់ដែលជាទូទៅបញ្ជាក់ថា សូមធ្វើសេចក្តីថ្លៃការណ៍តាមពាក្យបណ្តឹង បន្ទាប់មកតុលាការ អនុញ្ញាតឱ្យធ្វើ

សេចក្ដីបញ្ជាក់ដោយផ្ទាល់មាត់ ដែលខ្លួនបានដាក់ពាក្យបណ្ដឹងទាមទារឱ្យតុលាការចេញ ។ ក្រោយមកទើបតុលាការឱ្យចុងចម្លើយធ្វើសេចក្ដីថ្លែងការណ៍ជាក្រោយ ។

ចុងចម្លើយការធ្វើសេចក្ដីថ្លែការណ៍តប នៅក្នុងឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង ត្រូវមានសរសេរអំពីការឆ្លើយតប ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរទាមទារក្នុងពាក្យបណ្ដឹង និងការទទួលស្គាល់ ឬមិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរទាមទារនៅក្នុងពាក្យបណ្ដឹង និងអង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង ។ ចម្លើយចំពោះខ្លឹមសារនៃសាលក្រមដែលទាមទារ មានបីប្រភេទគឺ ការទទួលស្គាល់ការទាមទារ ត្រូវធ្វើនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលត្រូវកត់ត្រាក្នុងកំណត់ហេតុ ហើយកំណត់ហេតុនេះមានអានុភាពដូចសាលក្រមស្ដាពរ ការទាមទារឱ្យប្រានចោលនូវការទាមទារ ដោយអះអាងថាគ្មានមូលហេតុនៃការទាមទារ និងឱ្យលើកបណ្ដឹងចោល ដោយសារតែពុំមានលក្ខខណ្ឌបណ្ដឹង ។ ជាក់ស្ដែងនៅក្នុងសំណុំរឿងលេខ១២៩ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១៨ ចុងចម្លើយធ្វើសេចក្ដីថ្លែងការណ៍ ធ្វើការទទួលស្គាល់នូវការទាមទារចំណុចទីមួយ ទីពីរ និងបី ហើយមិនយល់ព្រមត្រង់ចំណុចទីបួន ដែលមានលក្ខណៈស្របគ្នាជាមួយទ្រឹស្ដីច្បាប់ជាមួយនឹងការអនុវត្តជាក់ស្ដែងនៅសាលាដំបូងខេត្តកំពង់ឆ្នាំង ។ ការធ្វើសេចក្ដីថ្លែងការណ៍របស់ភាគីដែលតុលាការដឹកនាំនីតិវិធីធ្វើបានត្រឹមត្រូវតាមច្បាប់បែបនេះគឺមានភាពងាយស្រួលដើម្បីឈានទៅរកការកំណត់ចំណុចវិវាទបានឆាប់រហ័ស និងល្អប្រសើរ ដែលមិនមានភាពស្មុគស្មាញដល់តុលាការនោះទេ ប្រសិនបើភាគីធ្វើសេចក្ដីថ្លែងការដូចអ្វីដែលចៅក្រមចង់បានដើម្បីរៀបចំចំណុចវិវាទ និងភស្តុតាង។

## ១.២.ការកំណត់ចំណុចវិវាទ

ដើម្បីអាចកំណត់ចំណុចវិវាទបានត្រូវធ្វើការស្ដាប់ការអះអាងរបស់របស់ភាគីតាមរបៀបទទួលស្គាល់ ឬមិនទទួលស្គាល់តាមការអះអាងទាំង០៤ បែបនេះគឺ

(ទី១) មាត្រា ១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី កថាខណ្ឌទី២ ការសារភាព គឺការទទួលស្គាល់អង្គហេតុ

(ទី២) មាត្រាដដែល កថាខណ្ឌទី១ ការបដិសេធ

(ទី៣) ការមិនដឹង នេះបើតាមមាត្រា ៩៦ នៃក្រមនេះ និង

(ទី៤) គឺភាគីនៅស្ងៀមមិនបង្ហាញឆន្ទៈអ្វីទាំងអស់ ។ មិនខុសគ្នាទៅនឹងការអនុវត្តនេះបើតាមកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក្នុងសំណុំរឿង ១២៩ ដែលភាគីធ្វើការទទួលស្គាល់ពោលគឺបានសារភាពចំពោះអង្គហេតុ ហើយក៏បានបដិសេធមិនយល់ព្រមចំពោះការទាមទារមួយផ្នែកផងដែរនេះ ចំណែកការដែលភាគីឆ្លើយមិនដឹង និងនៅស្ងៀមមិនបង្ហាញឆន្ទៈនៅសាលាដំបូងខេត្តកំពង់ឆ្នាំងមិនធ្លាប់

ជួបប្រទះនោះទេក្នុងអំឡុងពេលចុះកម្មសិក្សានេះ។ នេះឃើញថាការអនុវត្តមានលក្ខណៈដូចទៅនឹងទ្រឹស្តីចំពោះការទទួលស្គាល់ និងការបដិសេធមួយផ្នែក ឬច្រើនផ្នែកដែលមានក្នុងការអនុវត្តតែងតែជួបប្រទះ។

បន្ទាប់មកតុលាការនឹងធ្វើការរៀបចំចំណុចវិវាទ ជាចំណុចដែលភាគីប្រកែកគ្នា ហើយចំពោះចំណុចវិវាទគឺធ្វើការរៀបចំតាមការអះអាងរបស់ភាគីមាន ការសារភាពចំពោះអង្គហេតុ ការបដិសេធចំពោះអង្គហេតុ ការឆ្លើយថាមិនដឹងចំពោះអង្គហេតុ និងការនៅស្ងៀមមិនបង្ហាញឆន្ទៈ។ ដូច្នេះចំណុចវិវាទគឺ ការបដិសេធ ការមិនដឹងចំពោះអង្គហេតុ ហើយការដែលភាគីបានទទួលស្គាល់ និងនៅស្ងៀមមិនតវ៉ាចំពោះអង្គហេតុនេះ មិនមែនជាចំណុចវិវាទនោះទេ ។ ដូចគ្នាផងដែរទៅនឹងការអនុវត្ត គឺតុលាការបង្កើតជាសំណួរដើម្បីស្វែងរកចំណុចវិវាទ ថាតើភាគីទទួលស្គាល់ ឬមិនទទួលស្គាល់ ចំណុចដែលភាគីទទួលស្គាល់នោះជាចំណុចដែលគ្មានវិវាទ និងការមិនទទួលស្គាល់គឺជាចំណុចវិវាទ នេះគឺដូចគ្នាទៅនឹងការអនុវត្តនៅសាលាដំបូងខេត្តកំពង់ឆ្នាំង ។ ហើយចំណុចដែលមានវិវាទត្រូវការបញ្ជាក់ដោយភស្តុតាង។ ដែលទ្រឹស្តីច្បាប់ និងការអនុវត្តមានភាពដូចគ្នា ដែលជាការល្អប្រសើរមួយសម្រាប់តុលាការធ្វើការកំណត់ចំណុចវិវាទនាំឱ្យមានភាពស្មុគស្មាញដល់តុលាការដើម្បីបន្តនីតិវិធីជាបន្តបន្ទាប់ទៀត ។

## ១.៣.ការរៀបចំភស្តុតាង

ការរៀបចំភស្តុតាង ចំពោះអង្គហេតុទាំងឡាយណាដែលមានវិវាទត្រូវសម្រេចដោយភស្តុតាង ហើយភស្តុតាងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីមាន០៥ ប្រភេទគឺ ការសាកសួរភាគី ការសាកសួរសាក្សី ការធ្វើកោសលវិច័យ ការត្រួតពិនិត្យ និងភស្តុតាងជាឯកសារ។ ការរៀបចំនេះគឺដើម្បីធ្វើការទាញហេតុផលផ្ទាល់មាត់មានភាពរលូនត្រូវធ្វើការរៀបចំភស្តុតាង ។ នៅសាលាដំបូងខេត្តកំពង់ឆ្នាំង គឺមានភាគីស្នើសុំឱ្យពិនិត្យភស្តុតាងដែលមានភាគច្រើនគឺភស្តុតាងជាឯកសារ ហើយសំណុំរឿងខ្លះក៏មានកាសាកសួរសាក្សីផងដែរ ដែលមានភាពដូចគ្នាទៅនឹងស្មារតីច្បាប់ ។ រីឯភស្តុតាងកោសលវិច័យ និងភស្តុតាងត្រួតពិនិត្យ មិនធ្លាប់ជួបប្រទះនៅសាលាដំបូងខេត្តកំពង់ឆ្នាំងក្នុងអំឡុងពេលកម្មសិក្សានោះទេ។ ភស្តុតាងដើម្បីអាចពិនិត្យបានត្រូវធ្វើការស្នើសុំដោយភាគី ប៉ុន្តែតុលាការអាចធ្វើពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន។ ចំពោះភស្តុតានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលអាចធ្វើការពិនិត្យបានចំពោះតែភស្តុតាងជាឯកសារប៉ុណ្ណោះ ប៉ុន្តែការស្នើសុំសាកសួរសាក្សីអាចធ្វើបាន តែច្បាប់មិនអនុញ្ញាតឱ្យធ្វើការសួរនោះទេ។ នៅពេលភស្តុតាងត្រូវបានដាក់តាមការស្នើសុំរបស់ភាគីតុលាការនឹងធ្វើការសម្រេចថាទទួលយក ឬ មិនទទួលដោយដីកាសម្រេច។ ការអនុវត្តឃើញថាភាគីតែងតែដាក់ភស្តុតាងជាឯកសារដើម្បីឱ្យតុលាការពិនិត្យ ដែលមានភាពដូចជាមួយនឹងលិខិតូបករណ៍គតិយុត្ត។ ការរៀបចំភស្តុតាងបានល្អប្រសើរនឹងនាំឱ្យការទាញហេតុផលផ្ទាល់មាត់មានភាពរលូន និងឱ្យតុលាការចេញសាលក្រមមានភាពត្រឹមត្រូវ និងយុត្តិធម៌ដោយពិចារណាទៅលើភស្តុតាងនេះឯង។

### ១.៤.ការធ្វើកំណត់ហេតុរបស់ក្រឡាបញ្ជី

តុលាការឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅគ្រប់កាលបរិច្ឆេទនីមួយៗ ដែលនេះបញ្ជាក់ថា និតិវិធីត្រៀមអាចធ្វើមួយលើក ឬច្រើនលើកបាន។ កំណត់ហេតុត្រូវធ្វើតាមចំណុចរូបមន្តដូចមានចែងក្នុងមាត្រា១១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី មានដូចតទៅ សញ្ញាណរឿងក្តី ឈ្មោះចៅក្រម និងក្រឡាបញ្ជី ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និងអ្នកបកប្រែដែលបានបង្ហាញខ្លួន ពេលវេលា និងទីកន្លែង ព្រមទាំងចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងក្រឡាបញ្ជី ។ មួយវិញទៀត កំណត់ហេតុត្រូវកត់ត្រានូវសារជាតុនូវសកម្មភាពដែលមានចំណុច ដូចចែងក្នុងមាត្រា ១១១ នៃក្រមដដែលនេះ ។ ដោយមើលទៅលើសំណុំរឿងជាក់ស្តែងនៅសាលាដំបូងខេត្តកំពង់ឆ្នាំងមានភាពដូចគ្នា តុលាការតែងតែធ្វើគោរពទៅតាមស្មារតីដែលច្បាប់បានចែងដូចក្នុងកំណត់ហេតុជាក់ស្តែង លើសពីនេះក៏មានបញ្ជាក់នូវការផ្តិតមេដៃស្តាំរបស់ភាគីដើមចោទ ចុងចម្លើយ និង ហត្ថលេខារបស់មេធាវីផងដែរដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ថាភាគីទាំងនេះបានចូលរួមក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ។ កំណត់ហេតុជាភស្តុតាងដ៏សំខាន់មួយសម្រាប់កំណត់ចំណុចវិវាទ និងគ្មានវិវាទ ជាពិសេសសម្រាប់ការប្តឹងឧបាស្រ័យនោះនឹងមានភាពងាយស្រួលដោយគ្រាន់តែមើលតាមកំណត់ហេតុ ដែលបានកត់ត្រានោះនឹងដឹងអំពីដំណើរសេចក្តី ចំណុចវិវាទជាដើម ដើម្បីងាយស្រួលក្នុងការសម្រេចសេចក្តីនឹងឈានដល់ការចេញសាលក្រមបន្ទាប់ពីការទាញហេតុផលផ្ទាល់មាត់ត្រូវបានបញ្ចប់ ។

## ផ្នែកទី២ ចំណុចដែលមិនទាន់អនុវត្តបានពេញលេញតាមស្មារតីច្បាប់

ឆ្លងតាមការសិក្សាទៅលើទ្រឹស្តីគតិយុត្ត និងការសង្កេតទៅលើការអនុវត្តផ្ទាល់នៅសាលាដំបូង ខេត្តកំពង់ឆ្នាំង យើងសង្កេតឃើញថា មានចំណុចមួយចំនួនដែលមិនទាន់បានអនុវត្តពេញលេញតាម ស្មារតីច្បាប់ដែលពាក់ព័ន្ធទៅនឹងការកំណាត់កាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផល(១.១.) ការប្រើប្រាស់សិទ្ធិបំភ្លឺ (១.២.) របស់តុលាការ ការអនុវត្តគោលការណ៍យុត្តិធម៌ និងឆាប់រហ័ស (១.៣.) និងការបញ្ជូន (១.៤.) ។

### ១.១.ការកំណត់កាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ការកំណត់កាលបរិច្ឆេទគឺកំណត់ដោយច្បាប់ក្នុងអំឡុងពេល៣០ (សាមសិប) ថ្ងៃបន្ទាប់ពីពាក្យបណ្តឹងត្រូវបានដាក់នោះតុលាការត្រូវចាត់ការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តែការអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តកំពង់ឆ្នាំងឃើញថា សុំណុំរឿងមានច្រើនរួមទាំងសំណុំរឿងព្រហ្មទណ្ឌផងនោះដែលតុលាការត្រូវចាត់ការ ។ ប៉ុន្តែ ក្រឡេកមកមើលចំនួនចៅក្រម និងក្រឡាបញ្ជីមានចំនួនតិច មិនសមមាត្រគ្នានឹងសំណុំរឿងដែលមាននៅសាលាដំបូងខេត្តកំពង់ឆ្នាំងនោះទេ ។ ដូច្នេះមិនអាចធ្វើការអនុវត្តតាមស្មារតីច្បាប់ទាំងស្រុងបានទេ ។ ហើយតុលាការក៏អាចកំណត់ថ្ងៃសៅរ៍ អាទិត្យ ឬ ថ្ងៃឈប់សម្រាកបាន ប៉ុន្តែប្រជាពលរដ្ឋទូទៅដឹងថាថ្ងៃឈប់

ដោយមិនបានយល់ដឹងអំពីកំណត់ច្បាប់អាចធ្វើទៅបាន បើធ្វើការកំណត់យកថ្ងៃទាំងនោះពួកគាត់យល់ថាជាការកំណត់ខុស ហើយមិនធ្វើការចូលរួមតាមការកំណត់ ហេតុនេះក៏មិនអាចអនុវត្តបានចំពោះថ្ងៃដែលច្បាប់បញ្ញត្តិករណីពិសេសនេះបានដែរដោយកំណត់យកថ្ងៃទាំងនោះទេ ។ ការដែលមិនអាចធ្វើបានដូចកំណត់ច្បាប់បែបនេះនាំឱ្យសំណុំរឿងមានការកក់ស្ទះ ឱ្យនាំឱ្យមានការយឺតយ៉ាវដែលបង្ករជាការមិនពេញចិត្តចំពោះសេវាយុត្តិធម៌ ដោយធ្វើការរិះគន់តុលាការយឺតយ៉ាង ឬ អយុត្តិធម៌ជាដើម ។

### ១.២. ការប្រើប្រាស់សិទ្ធិបំភ្លឺ

នៅក្នុងប្រព័ន្ធនៃនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ពីគោលការណ៍អកម្ម របស់តុលាការ មានន័យថា តុលាការមិនអាចលូកដៃចូលទៅក្នុងទំនាក់ទំនង ឬផលប្រយោជន៍របស់ភាគី នោះទេ ។ ជាការពិតណាស់ វិវាទរដ្ឋប្បវេណី គឺជាវិវាទរវាងបុគ្គលឯកជន និងបុគ្គលឯកជន ហេតុដូច្នេះ ភាគីត្រូវធ្វើការស្រាវជ្រាវឲ្យបានលម្អិតជាមុននូវទំនាក់ទំនងនៃអង្គហេតុចំពោះសាក្សី និងភស្តុតាងផ្សេងៗ ដើម្បីធ្វើការអះអាង និងបញ្ជាក់ឲ្យបានច្បាស់លាស់ក្នុងបណ្តឹង ។ ប៉ុន្តែ ដោយសារតែចំណេះដឹង ផ្នែកច្បាប់របស់ប្រជាពលរដ្ឋនៅមានកម្រិតទាប ធ្វើឲ្យភាគីមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការអះអាង និងរៀបចំភស្តុតាងនោះទេ ហេតុនេះទើបច្បាប់របស់ប្រទេសកម្ពុជា ជាពិសេសគឺក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់ពីការប្រើប្រាស់សិទ្ធិបំភ្លឺ ។ ការប្រើប្រាស់សិទ្ធិបំភ្លឺនេះ គឺជាសិទ្ធិរបស់តុលាការដើម្បីបញ្ជាក់ពី ចំណុចនៃអង្គហេតុ និងអង្គច្បាប់ដែលទាក់ទងនឹងបណ្តឹងឲ្យមានភាពច្បាស់លាស់ តាមរយៈការសាកសួរ ភាគី ឬឲ្យភាគីអះអាង ឬបញ្ជាក់ភស្តុតាង ចំពោះចំណុចណាមួយ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀម សម្រាប់ការទាញហេតុផល ។

នៅក្នុងការអនុវត្តជាក់ស្តែង ប្រសិនបើភាគីមានអ្នកតំណាងដោយអាណត្តិ គឺមិនសូវជាមានបញ្ហា ចោទនោះទេ ហេតុនេះនៅក្នុងដំណើរការនីតិវិធី តុលាការតែងតែណែនាំភាគីឲ្យស្វែងរកមេធាវី ដើម្បី តំណាងឲ្យខ្លួននៅក្នុងបណ្តឹង ។ ប៉ុន្តែ ប្រសិនបើភាគីមិនមានលទ្ធភាពក្នុងការពឹងពាក់មេធាវី ចង់ ឬមិនចង់ តុលាការត្រូវតែដំណើរការនីតិវិធី ហេតុនេះ ក្នុងការអនុវត្តជាក់ស្តែង ការប្រើប្រាស់សិទ្ធិបំភ្លឺរបស់ តុលាការ ច្រើនតែបំពានទៅលើគោលការណ៍អកម្ម មានន័យថាតុលាការតែងតែប្រើប្រាស់ពាក្យពេចន៍ ឬប្រើប្រាស់សំណួរនាំមុខដើម្បីទាញភាគីមករកអង្គហេតុដែលកំណត់ពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ទៅតាមការយល់ឃើញរបស់ខ្លួនដើម្បីងាយស្រួលក្នុងការកំណត់ចំណុចវិវាទ ។

### ១.៣.ការអនុវត្តន្លូវគោលការណ៍យុត្តិធម៌ និងឆាប់រហ័ស

ដើម្បីធានានូវភាពយុត្តិធម៌ដល់គូភាគីតុលាការត្រូវតែគោរពនូវគោលការណ៍យុត្តិធម៌ និងឆាប់រហ័ស ។ មានន័យថា តុលាការមិនត្រឹមតែត្រូវអព្យាក្រឹត និងមិនលម្អៀងប៉ុណ្ណោះទេ ថែមទាំងត្រូវធ្វើឲ្យនីតិវិធីមានភាពឆាប់រហ័សទៀតផង ពីព្រោះថា បើសិនជាការស្វែងរកយុត្តិធម៌មានភាពយឺតយ៉ាវ គឺស្មើនឹងបដិសេធយុត្តិធម៌។ ជាការ

ពិតណាស់ តុលាការគឺជាអ្នកដឹកនាំចាត់ចែងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលមានតួនាទីធ្វើឲ្យនីតិវិធីទាំងមូលមានដំណើរការប្រព្រឹត្តទៅដោយរលូន និងឆាប់រហ័ស ។ ប៉ុន្តែ នៅក្នុងការអនុវត្ត ភាគីដែលមានវិវាទនឹងគ្នា តែងតែអះអាងយកត្រូវរៀងៗខ្លួនដោយធ្វើការអះអាងនូវអង្គហេតុ ឬចំណុចណាដែលខ្លួនយល់ឃើញថាមានភាពល្អប្រសើរដល់ខ្លួន ដែលធ្វើឲ្យតុលាការមានភាពស្មុគស្មាញក្នុងការគ្រប់គ្រង។ ប្រសិនបើតុលាការបណ្ដោយឲ្យភាគីថ្លែងការណ៍ទៅ តាមការយល់ឃើញរបស់ខ្លួននោះ នឹងធ្វើឲ្យនីតិវិធីត្រូវអូសបន្លាយ ប៉ុន្តែប្រសិនបើតុលាការហាមឃាត់ ភាគីមិនឲ្យលើកឡើងនូវអង្គហេតុដែលមិនមានការពាក់ព័ន្ធទៅនឹងរឿងក្ដី ធ្វើឲ្យភាគីទោះយល់ថា តុលាការមានភាពលម្អៀង និងអយុត្តិធម៌ ។ ហេតុនេះ ចង់ ឬមិនចង់ តុលាការតែងតែអនុញ្ញាតឲ្យភាគីលើកឡើងអង្គហេតុមួយចំនួន បើទោះបីជាយល់ឃើញថាអង្គហេតុនោះ មិនអាចឲ្យតុលាការកំណត់ពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តក៏ដោយ ។

ចំណេះដឹងរបស់ភាគី ក៏ជាបញ្ហាមួយ ប៉ុន្តែ ទន្ទឹមនឹងនោះបើទោះជាភាគីមានអ្នកតំណាងដោយ អាណត្តិហើយក៏ដោយ ពេលខ្លះក៏នីតិវិធីត្រូវអូសបន្លាយផងដែរ ដោយសារតែមេធាវីមួយចំនួន តែងតែក្រឡុកនីតិវិធីរបស់តុលាការ ក្នុងគោលបំណងធ្វើឲ្យនីតិវិធីមានភាពយឺតយ៉ាវ ។ ឧទាហរណ៍ដូចជា ការជូនដំណឹងពីកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយក្រឡាបញ្ជី បានជូនដំណឹងតាមទូរស័ព្ទរួចហើយ ប៉ុន្តែ នៅពេលដល់កាលបរិច្ឆេទនោះ គាត់បែរជាមិនមក ហើយឆ្លើយថាភ្លេច ឬមិនដឹងជាដើម ជាពិសេសមេធាវី ដែលយល់ថាខ្លួនឯងនឹងចាញ់ក្ដី ។

នៅក្នុងការអនុវត្តជាក់ស្ដែង ភាគីដែលយល់ថាខ្លួនចាញ់ក្ដី តែងតែធ្វើសកម្មភាពដើម្បីពន្យារនីតិវិធីរបស់តុលាការឲ្យមានភាពយឺតយ៉ាវ ដូចជាៈ ការស្នើសុំលើកពេលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ការប្ដឹងតវ៉ានឹងការដឹកនាំនីតិវិធីរបស់តុលាការ ការដាក់បណ្ដឹងតប ការស្នើសុំដាក់ភស្តុតាងក្នុងអំឡុងពេលវែង និងធ្វើសកម្មភាពផ្សេងៗទៀត ។

### ១.៤.ការបញ្ជូន

ក្រមនីតិវិធីរដ្ឋប្បវេណី បានកំណត់ថាកិច្ចការបញ្ជូនត្រូវធ្វើឡើងដោយក្រឡាបញ្ជី ចំណែកឯការ បញ្ជូនត្រូវបានប្រតិបត្តិដោយបុគ្គលិកប្រៃសណីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី ។ ប៉ុន្តែ ក្នុងការអនុវត្តជាក់ ស្ដែង ក្រឡាបញ្ជីដែលជាអ្នកចាត់ចែងការបញ្ជូន តែងតែបង្គាប់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ដែលប្រចាំការនៅតុលាការជាអ្នកបញ្ជូនទៅភាគី ។ ចំណុចនេះ យើងសង្កេតឃើញថា ជាការអនុវត្តដែលមិនស្របទៅ នឹងស្មារតីនៃក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៤៦ ដែលធ្វើឲ្យគូភាគីអាចប្ដឹងតវ៉ាចំពោះការចាត់ចែងរបស់ ក្រឡាបញ្ជីបានថែមទៀតផង ។

ក្រឡាបញ្ជី គឺជាមន្ត្រីចាត់ចែងការបញ្ជូន ដែលប្រគល់អំណាចដល់អ្នកប្រតិបត្តិការបញ្ជូនដើម្បីបញ្ជូនឯកសារ ដែលអាចប្រគល់សិទ្ធិដល់ខ្លួនឯង ប្រគល់សិទ្ធិដល់បុគ្គលិកប្រៃសណីយ៍ និងប្រគល់សិទ្ធិដល់អាជ្ញា

សាលា ។ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែង ជាពិសេសក្នុងសាលាដំបូងខេត្តកំពង់ឆ្នាំង ក្រឡាបញ្ជីមានតួនាទីច្រើនដែលត្រូវបំពេញទាំងការងារព្រហ្មទណ្ឌ ដូចជាការធ្វើកំណត់ហេតុបង្ហាញខ្លួន លើកដំបូងកំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ កំណត់ហេតុសួរចម្លើយជនត្រូវចោទ កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី កំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រាងដីកាជូនចៅក្រមស៊ើបសួរចូលរួមសវនាការក្នុងរឿងក្តីព្រហ្មទណ្ឌ និងព្រាងសាលក្រមជូនចៅក្រមជំនុំជម្រះជាដើម ។ ចំណែកឯ ក្នុងរឿងក្តីរដ្ឋប្បវេណីវិញ នៅក្នុងនីតិវិធីបណ្តឹងក្រឡាបញ្ជី ត្រូវធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចូលរួមក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ធ្វើកំណត់ហេតុស្តីពីនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ព្រាងសាលក្រមជូនចៅក្រម ហើយក្រៅពីនេះ នៅមានការងារជាច្រើនទៀតក្នុងការអនុវត្តដោយបង្ខំ រឿងក្តីរក្សាការពារ ការងាររដ្ឋបាល និងការធ្វើរបាយការណ៍ជាដើម ។ ហេតុនេះ ទោះបីជាច្បាប់បានអនុញ្ញាតដល់ក្រឡាបញ្ជី ក្នុងការប្រគល់ សិទ្ធិដល់ខ្លួនឯងក្នុងការបញ្ជូនក៏ដោយ ក្នុងការអនុវត្តជាក់ស្តែង ក្រឡាបញ្ជី មិនអាចធ្វើការបញ្ជូនដោយខ្លួនឯងបាននោះទេ ពីព្រោះថាមានការងារច្រើនដែលក្រឡាបញ្ជីត្រូវបំពេញ ។ ចំពោះបុគ្គលិកប្រៃសណីយ៍វិញ ក៏មិនអាចធ្វើការបញ្ជូនបានដែរ ពីព្រោះថាប្រៃសណីយ៍មិនទាន់មានដំណើរការបានល្អ ដោយអាចបញ្ជូនបានតែតំបន់មួយចំនួនប៉ុណ្ណោះ ។រីឯអាជ្ញាសាលាវិញ យើងសង្កេតឃើញថា អាជ្ញាសាលាត្រូវ បានបណ្តុះបណ្តាលមួយជំនាន់មកហើយ និងបានចេញទៅបម្រើការងារនៅតាមសាលាជម្រះក្តីមួយចំនួន ដោយឡែកចំពោះសាលាដំបូងខេត្តកំពង់ឆ្នាំង វិញ គឺមិនមានអាជ្ញាសាលានោះទេ ដូច្នេះ ការប្រគល់សិទ្ធិ ដល់អាជ្ញាសាលាក្នុងការបញ្ជូន គឺមិនអាចធ្វើទៅបាននោះទេ ។

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការបកស្រាយខាងលើ យើងសង្កេតឃើញថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីមួយដែលសំខាន់ ហើយមិនអាចខ្វះបាន នៅក្នុងការជំនុំជម្រះក្តីលើកទី១ ពីព្រោះថា វាបានជួយសម្រួលដល់ការទាញហេតុផលដោយផ្ទាល់មាត់ធ្វើឲ្យការទាញហេតុផលដោយផ្ទាល់មាត់នាពេលសវនាការមានភាពច្បាស់លាស់ ហើយក៏ជាមូលដ្ឋានដ៏សំខាន់សម្រាប់តុលាការក្នុងការចេញសាលក្រមដើម្បីឆ្លើយតបចំពោះភាគីនៃរឿងក្តីផងដែរ។ ប្រសិនបើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលធ្វើឡើងដោយមិនច្បាស់លាស់ ពិតណាស់ គឺតុលាការនឹងមិនអាចធ្វើការពិនិត្យភស្តុតាងដោយសមូហវិធី នៅពេលទាញហេតុផលដោយផ្ទាល់មាត់បាននោះទេ ដោយត្រូវបង្វិលនីតិវិធីដើម្បីត្រឡប់មកធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលម្តងទៀត ធ្វើឲ្យការផ្តល់យុត្តិធម៌ជូនភាគីត្រូវចំណាយនូវពេលវេលាច្រើន ។ ហេតុនេះ ដើម្បីជៀសវាងនូវការអូសបន្លាយពេលវេលា គឺទាមទារឲ្យតុលាការ ត្រូវមានការយកចិត្តទុកដាក់ខ្ពស់ក្នុងការស្វែងរកចំណុចស្នូលនៃចំណុចវិវាទ ។

ជាការពិតណាស់ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលគឺត្រូវដឹកនាំចាត់ចែងដោយតុលាការ ចំណែកឯភាគីវិញ គឺជាអ្នកធ្វើសកម្មភាព ទៅតាមការបង្គាប់ ឬ ដោយមានការអនុញ្ញាតពីតុលាការ ។ ប៉ុន្តែ ក្នុងដំណើរការនីតិវិធី ភាគីដែលមានវិវាទនឹងគ្នា តែងតែធ្វើសកម្មភាពផ្សេងៗដើម្បីជាប្រយោជន៍ដល់ខ្លួន ហេតុនេះ តុលាការមានការពិបាកក្នុងការគ្រប់គ្រងនីតិវិធីឲ្យប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពណាស់ ។ បញ្ហានេះទាមទារឲ្យតុលាការត្រូវតែមានចំណេះដឹង និងបទពិសោធន៍ ។ ជាក់ស្តែង ប្រសិនបើចៅក្រមនីមួយៗក្នុងស្ថាប័នមានទំនាក់ទំនងល្អ នៅពេលដែលមានជួបប្រទះបញ្ហានៅក្នុងដំណើរការនីតិវិធី គឺអាចផ្លាស់ប្តូរមតិ ឬតាមរយៈការផ្តល់យោបល់ឲ្យគ្នាទៅវិញទៅមក ដើម្បីស្វែងរកដំណោះស្រាយ ។

ជាលទ្ធផលជាក់ស្តែងយើងសង្កេតឃើញថា នៅតែមានចំណុចមួយចំនួនដែលមិនទាន់ មានការអនុវត្តពេញលេញតាមស្មារតីច្បាប់ដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់សិទ្ធិបំភ្លឺរបស់តុលាការ ការអនុវត្តគោលការណ៍យុត្តិធម៌និងឆាប់រហ័ស និងការបញ្ជូនដោយសារតែការជួបប្រទះនូវបញ្ហាប្រឈមដែលបណ្តាលមកពីបញ្ហាការយល់ដឹងរបស់ភាគី ការពន្យារពេលរបស់ភាគី និងកង្វះអ្នកទទួល បន្ទុកប្រតិបត្តិការបញ្ជូន ក៏ដោយ ក៏យើងនៅតែសង្ឃឹមថាប្រសិនបើមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ទាំងអស់ទាំងស្ថាប័នតុលាការ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ដូចជាក្រសួងយុត្តិធម៌ ជាដើម ក្នុងការចូលរួមដោះស្រាយបញ្ហាប្រឈមដែលកើតមានឡើង នោះយើងនឹងអាចស្វែងរកដំណោះស្រាយរួមមួយដោយមានការទទួលស្គាល់ពីគ្រប់ភាគីបាន ។

# មតិយោបល់ និងសំណូមពរ

ការអនុវត្តជាក់ស្តែង បានជួបនូវបញ្ហាប្រឈម ប៉ុន្តែដើម្បីធានានូវតម្លាភាពក៏ដូចជាការបង្កើននូវការជឿទុកចិត្តពីសាធារណជនចំពោះប្រព័ន្ធតុលាការ គប្បីមានការចូលរួមលុបបំបាត់នូវរាល់ បញ្ហាប្រឈមដែលកើតមានឡើងតាមរយៈកែទម្រង់ ក៏ដូចជាខិតខំរាប់រងបញ្ហាមួយចំនួនដូចជាៈ

ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនអាចធ្វើការអនុវត្តបានទាំង ស្រុងតាមស្មារតីច្បាប់នោះទេ កំណត់ច្បាប់ដោយហេតុថាចៅក្រម និងក្រឡាបញ្ជីចំនួនតិច ចំណែកសំណុំរឿងមានច្រើន មិនអាចធ្វើការកំណត់ដូចអ្វីដែលច្បាប់កំណត់ទាំងស្រុងនោះទេ ។

ការប្រើប្រាស់សិទ្ធិបំភ្លឺឲ្យបានត្រឹមត្រូវ នៅក្នុងការប្រើប្រាស់សិទ្ធិបំភ្លឺ ទន្ទឹមនឹងការពិចារណា ទៅលើកម្រិតនៃការយល់ដឹងរបស់ភាគី តុលាការក៏ត្រូវតែយល់ឲ្យបានច្បាស់ផងដែរ ពីគោលការណ៍អកម្ម ដែលមិនអនុញ្ញាតឲ្យតុលាការជ្រៀតជ្រែកចូលទៅក្នុងទំនាក់ទំនងរបស់បុគ្គលឯកជននោះទេ ។ មានន័យថា តុលាការត្រូវតែស្វែងរកចំណុចកណ្តាលមួយ ទើបការប្រើប្រាស់សិទ្ធិបំភ្លឺនោះស្របនឹងគោលគំនិតច្បាប់ ជៀសវាងការលើកឡើងពីភាគីថាតុលាការមានភាពលម្អៀង ។

ការអនុវត្តនីតិវិធីឲ្យបានត្រឹមត្រូវ នៅក្នុងការអនុវត្តនីតិវិធីតុលាការត្រូវធានាឲ្យបាននូវការ ដឹកនាំនីតិវិធីឲ្យមានប្រសិទ្ធិភាព និងភាពច្បាស់លាស់ ដោយប្រើប្រាស់នូវចំណេះដឹង និងបទពិសោធន៍ របស់ខ្លួន ។ ទន្ទឹមនឹងនោះ អាកប្បកិរិយាក៏មានភាពសំខាន់ផងដែរ មានន័យថា តុលាការក៏ត្រូវមាននូវ កាយវិការ និងពាក្យសម្តីសមរម្យទៅកាន់គូភាគី ទាំងដើមចោទ និងចុងចម្លើយ ពីព្រោះថាប្រសិនបើ អាកប្បកិរិយារបស់តុលាការក្នុងការដឹកនាំនីតិវិធី មិនមានភាពសមស្របនោះនឹងធ្វើឲ្យភាគីយល់ថា តុលាការមានភាពលម្អៀង ។ មិនត្រឹមតែប៉ុណ្ណោះ ភាគីដែលមានចេតនាអូសបន្លាយនីតិវិធី នឹងយកបញ្ហានេះ ក្នុងការប្តឹងតុលាការ បើទោះបីជាតុលាការបានដឹកនាំនីតិវិធីត្រឹមត្រូវហើយក៏ដោយ ។

ការរៀបចំអ្នកប្រតិបត្តិការបញ្ជូនអ្នកប្រតិបត្តិការបញ្ជូន រួមមាន ក្រឡាបញ្ជី បុគ្គលិកប្រៃសណីយ៍ និងអាជ្ញាសាលា ។ ចំពោះ ក្រឡាបញ្ជី គប្បីមានការបណ្តុះបណ្តាលបន្ថែមទៀត ។ ជាការពិតណាស់ ជាក់ស្តែងយើងសង្កេតឃើញថា ក្រសួងយុត្តិធម៌ តាមរយៈរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការបានធ្វើការបណ្តុះបណ្តាលក្រឡាបញ្ជីបានប្រាំមួយជំនាន់មកហើយ ចាប់ពីជំនាន់ទី១ ដល់ជំនាន់ទី៦ ហើយបច្ចុប្បន្ននេះ សិស្សក្រឡាបញ្ជីជំនាន់ទី៧ កំពុងទទួលការបណ្តុះបណ្តាល ។ មិនត្រឹមតែប៉ុណ្ណោះ ក្រសួងយុត្តិធម៌ ក៏បានរៀបចំក្នុងការប្រឡងប្រជែងជ្រើសរើស

សិស្សក្រឡាបញ្ជីជំនាន់ទី៨ ផងដែរ។ ចំណុចនេះគឺជាការអនុវត្តដ៏ល្អ ហេតុនេះ ក្រសួងយុត្តិធម៌គប្បីអនុវត្តសកម្មភាពនេះបន្តទៀត ដើម្បីបណ្តុះបណ្តាលក្រឡាបញ្ជីឲ្យបានច្រើន ដើម្បីមានភាពសមស្របទៅនឹងសំណុំរឿងក្តីនៅសាលាជម្រះក្តី ។ ចំពោះបុគ្គលិកប្រៃសណីយ៍ ក្រសួងយុត្តិធម៌ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ គប្បីសហការជាមួយក្រសួងសាមី គឺក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីរៀបចំនូវប្រៃសណីយ៍នៅតាមបណ្តារាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ និងឃុំ/សង្កាត់ ដើម្បីអាចធ្វើការបញ្ជូនឯកសារទៅគ្រប់ទីកន្លែងបាន ។ ចំណែកឯ អាជ្ញាសាលាវិញ យើងសង្កេតឃើញថា អាជ្ញាសាលាត្រូវបានបណ្តុះបណ្តាលបានមួយចំនួនមកហើយ ប៉ុន្តែ អាជ្ញាសាលាដែលបានបណ្តុះបណ្តាលហើយនោះ គឺត្រូវបានចាត់តាំងឲ្យទៅ បម្រើការងារនៅតាមសាលាជម្រះក្តីមួយចំនួនប៉ុណ្ណោះ មិនបានគ្រប់សាលាជម្រះក្តីនោះទេ ។ ជាការពិតណាស់ ក្រសួងយុត្តិធម៌បាននឹងកំពុងរៀបចំប្រឡងប្រជែងសិស្សអាជ្ញាសាលាបន្ថែមទៀត ប៉ុន្តែ យើងសង្កេតឃើញថា ទោះបីជាសិស្សអាជ្ញាសាលាត្រូវបានបណ្តុះបណ្តាលបន្តបន្ទាប់ ក៏ដោយក៏ចំនួននេះ នៅតែមានភាពតិចតួច និងមិនមានភាពគ្រប់គ្រាន់នោះទេ ហេតុនេះ ក្រសួងយុត្តិធម៌គប្បីបន្តធ្វើការបណ្តុះបណ្តាលអាជ្ញាសាលាបន្ថែមទៀត ។

# ឯកសារយោង

### ❖ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ។

២.ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ។

២.ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ។

៣.ក្រមរដ្ឋប្បវេណី លេខ នស/រកម/១២០៧ ចុះថ្ងៃទី១៨ ខែធ្នូ ២០០៧ ។

### ❖ សៀវភៅ

១.សេចក្តីកំណត់មាត្រានីមួយនៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលរៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុក ធ្វើសេចក្តីព្រាងក្រមនីតិវិធី និងគណៈកម្មកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនិតិវិធីរដ្ឋប្បវេណី និងក្រសួងយុត្តិធម៌ឆ្នាំ២០០៨ ។

២.សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគី១ នីតិវិធីបណ្តឹង ដែលរៀបចំដោយក្រុមការងារជប៉ុនដែលទទលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងក្រសួងយុត្តិធម៌ឆ្នាំ២០០៨ ។

៣.សៀវភៅពន្យល់ ស្តីពី នីតិវិធីជំនុំជម្រះលើកទី១ រៀបរៀងដោយគ្រូបង្គោល នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ បោះពុម្ភៈលើកទី២ នៅខែវិច្ឆិកា ឆ្នាំ២០០៩ ។

### ❖ សំណុំរឿងរដ្ឋប្បវេណី

១.សំណុំរឿងរដ្ឋប្បវេណីលេខ ៣៧២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

២.សំណុំរឿងរដ្ឋប្បវេណីលេខ ១៣១ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

៣.សំណុំរឿងរដ្ឋប្បវេណីលខេ ២០១ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

### ❖ វចនានុក្រម

១.វចនានុក្រម សម្តេចសង្ឃរាជ ជួន ណាត ។

២.សន្ទានុក្រម នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ។

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**លិខិតស្នើសុំ**

នាងខ្ញុំឈ្មោះ ភេទ ស្រី កាន់អត្តសញ្ញាណប័ណ្ណលេខ 040405927 មានទីលំនៅ ភូមិដំណាក់ពពូល សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។

**លោក ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង**

**កម្មវត្ថុ**: ស្នើសុំលើកថ្ងៃការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលពាក្យបណ្តឹងសុំរំលាយ កិច្ចសន្យាទិញលក់រថយន្ត ចុះថ្ងៃទី ០៣ មិនា ឆ្នាំ ២០១៨ របស់ឈ្មោះ ញ៉ ណៃហៀក។

តតាមកម្មវត្ថុ ខាងលើដោយមូលហេតុ នាងខ្ញុំ ហើង ទិត្យរាត្រីលក្ខណ៍ មានធុរៈ ចាំបាច់ដែលត្រូវបំពេញនៅក្រៅខេត្ត ទើបមិនបានមកចូលរួមតាមការកោះហៅ។

អាស្រ័យដូចបានជម្រាបខាងលើនេះសុំលោកចៅក្រម មេត្តា លើកថ្ងៃដែលណាត់ជួបនៅថ្ងៃទី ០៦ ខែមករា ឆ្នាំ២០២១ សុំប្តូរមក ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ៨ម៉៣០នាទី ព្រឹកវិញ។

សូមលោកចៅក្រមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ធ្វើនៅថ្ងៃទី ០៥ ខែមករា ឆ្នាំ២០២១

**ជ. អ្នកស្នើសុំ**

ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

លេខ: ០៦ / ២០២១

**<u>ដីកាបង្គាប់ឲ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ</u>**

យើង ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង ។

បានឃើញ មាត្រា៦២ កថាខណ្ឌទី៣ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសតាមព្រះរាជក្រមលេខនស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ: ៣៧២ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

-ដើមចោទឈ្មោះញឹម សាគីន ភេទស្រី អាយុ៣៣ ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិ ក្រសះថ្មី ឃុំ ឈូកស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

-ចុងចម្លើយឈ្មោះស្មាន វណ្ណី ភេទប្រុស អាយុ៣៣ ឆ្នាំ មានទីលំនៅសព្វថ្ងៃភូមិក្រសះថ្មី ឃុំឈូកស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

ដែលមានកម្មវត្ថុ:

-សុំលែងលះប្ដី ។

**<u>សំអាងហេតុ</u>**

-យល់ឃើញថា ដើម្បីដំណើរការនីតិវិធីបណ្ដឹងទៅតាមច្បាប់បាន លុះត្រាតែបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធជាមុនសិន ។

-យល់ឃើញថា ដើមចោទដែលមានកាតព្វកិច្ច បង់ប្រាក់សម្រាប់សកម្មភាពចាំបាច់របស់តុលាការ ក្នុងនីតិវិធីបណ្ដឹង ដូចមានចែងក្នុងមាត្រា៦២ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនទាន់បានបង់ប្រាក់នេះនៅឡើយ។ ហេតុនេះគប្បីតុលាការបង្គាប់ឱ្យដើមចោទបង់តាមកំណត់ច្បាប់ ។

**<u>ហេតុដូច្នេះសម្រេច</u>**

១-បង្គាប់ឱ្យដើមចោទឈ្មោះ ញឹម សាគីន បង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ ចំនួន ១០០,០០០ (ដប់ម៉ឺន)រៀល នៅសាលាដំបូងខេត្តកំពង់ឆ្នាំង ក្នុងអំឡុងពេល០១ សប្ដាហ៍ គិតចាប់ពីពេលទទួល ដំណឹងអំពីដីកាជាកំណត់ ដើម្បីតុលាការចាត់ការរឿងក្ដីនេះតាមច្បាប់ ។

២-ប្រាក់ដែលបានបង់ពន្ធនេះ បើសល់ពីការចំណាយត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ ។

ថ្ងៃសុក្រ ៨ រោច ខែមាឃឆ្នាំជូត ទោស័ក ព.ស២៥៦៤

កំពង់ឆ្នាំង ; ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១

ចៅក្រម

បានទទួលដំណឹង

ថ្ងៃទី........ខែ............. ឆ្នាំ២០២១

ស្នាមមេដៃ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

## កំណត់ហេតុស្តីពីការទទួលប្រាក់ប្រដាប់ក្តីតុលាការក្រៅពន្ធ

ឆ្នាំពីរពាន់មភ្លៃ ខែសីហា ថ្ងៃ.[illegible]...... វេលាម៉ោង..[illegible].. និង...[illegible]..។

យើង សេង សាគល ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ឆ្នាំង។

**បានឃើញ** សំណុំរឿងរដ្ឋប្បវេណីលេខ១៣១ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ដោយដើមចោទឈ្មោះ **តុប រតនា** ភេទស្រី អាយុ២៦ឆ្នាំ។

**បានឃើញ** ដីកាបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធលេខ..[illegible]....ចុះថ្ងៃទី.៣. ..ខែ សីហា ឆ្នាំ២០២០ របស់លោកចៅក្រម **ភី ដារ៉ូ** ។

បានទទួលប្រាក់ចំនួន ១០០.០០០រៀល (មួយសែនរៀល) ពីឈ្មោះ.....[illegible]..............

ជា[illegible]...។

បញ្ឈប់កំណត់ហេតុនៅវេលាម៉ោងដដែល នាថ្ងៃខែឆ្នាំដូចខាងលើ ។

អ្នកបង់ប្រាក់

ស្នាមមេដៃ

[illegible]

អ្នកទទួលប្រាក់

ក្រឡាបញ្ជី

ឧបសម្ព័ន្ធទី៣

# របាយការណ៍អំពីការបញ្ជូន

*ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី*

កាលបរិច្ឆេទផ្ញើចេញ : 15.02.2021

លេខសំណុំរឿង : ........ 211 / 13.07.2020

ឈ្មោះឯកសារដែលត្រូវបានបញ្ជូន : ..........

ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : ..........

អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : ..........

ឈ្មោះជនដែលត្រូវទទួលការបញ្ជូន : ..........

*ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង :* ..........

*ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន ( កញ្ញាប្រៃសណីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី )*

ទីកន្លែងដែលធ្វើការបញ្ជូន : ..........

កាលបរិច្ឆេទនៃការបញ្ជូន : ថ្ងៃទី 15 ខែ 02 ឆ្នាំ 2021 ម៉ោង 2 ព្រឹក/រសៀល

**វិធីជាក់ស្តែងក្នុងការបញ្ជូន**

| | | |
|---|---|---|
| ១ | ☐ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ |
| | | ☐ ខ្ញុំបានពន្យល់ដល់ជនដែលត្រូវទទួលការបញ្ជូន នូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអានអក្សរ |
| ២ | ☐ | បានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូន ដោយផ្ទាល់នៅកន្លែងដែលត្រូវបញ្ជូននោះទេ |
| | | ☐ អ្នកបម្រើ ☐ អ្នកជិតខាងដែលធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ |
| | | ឈ្មោះ : .......... |
| ៣ | ☐ | ឯកសារត្រូវបានទុកនៅឯទីកន្លែងដែលត្រូវធ្វើការបញ្ជូន ដោយហេតុថាបុគ្គលខាងក្រោមនេះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល |
| | | ☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបម្រើ |
| | | ☐ អ្នកនៅជាមួយ ☐ អ្នកជិតខាងដែលធ្វើការនៅទីនោះ |
| | | ឈ្មោះ : .......... |

☐ *ខ្ញុំបានបញ្ជូនឯកសារដូចនីតិវិធីខាងលើ*

☐ *ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែល មានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះ ។*

កាលបរិច្ឆេទធ្វើរបាយការណ៍ : ថ្ងៃទី 15 ខែ .......... ឆ្នាំ 2021

ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍ : ..........

# របាយការណ៍អំពីការបញ្ជូន

*ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី*

កាលបរិច្ឆេទផ្ញើចេញ : 21 - មករា - 2021

លេខសំណុំរឿង : [illegible] 2.11/13.07.2020

ឈ្មោះឯកសារដែលត្រូវបានបញ្ជូន : [illegible]

ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : [illegible]

អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : [illegible]

ឈ្មោះជនដែលត្រូវទទួលការបញ្ជូន : ...

*ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង :*

*ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន ( កត្តាប្រៃសណីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី )*

| | |
|---|---|
| ទីកន្លែងដែលធ្វើការបញ្ជូន : | |
| កាលបរិច្ឆេទនៃការបញ្ជូន : ថ្ងៃទី 21 ខែ មករា ឆ្នាំ 2021 ម៉ោង 10 ព្រឹក ព្រឹក/រសៀល | |
| **វិធីជាក់ស្តែងក្នុងការបញ្ជូន** | |
| ☑ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ |
| ១ | ☐ ខ្ញុំបានពន្យល់ដល់ជនដែលត្រូវទទួលការបញ្ជូន នូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអានអក្សរ |
| ☐ | បានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ |
| ២ | ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូន ដោយផ្ទាល់នៅកន្លែងដែលត្រូវបញ្ជូននោះទេ |
| | ☐ អ្នកបម្រើ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ |
| | ឈ្មោះ : |
| ☐ | ឯកសារត្រូវបានទុកនៅឯទីកន្លែងដែលត្រូវធ្វើការបញ្ជូន |
| ៣ | ដោយហេតុថាបុគ្គលខាងក្រោមនេះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល |
| | ☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបម្រើ |
| | ☐ អ្នកនៅជាមួយ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ |
| | ឈ្មោះ : |
| ☐ *ខ្ញុំបានបញ្ជូនឯកសារដូចនីតិវិធីខាងលើ* | |
| ☐ *ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែល មានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះ ។* | |
| កាលបរិច្ឆេទធ្វើរបាយការណ៍ : ថ្ងៃទី 21 ខែ មករា ឆ្នាំ 2021 | |
| ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍ : | |

ឧបសម្ព័ន្ធទទី៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តកំពង់ឆ្នាំង

សំណុំរឿងលេខ ១៣១
ចុះថ្ងៃទី០៤/០៥/២០២០

# លិខិតអញ្ជើញមេធាវី

យើង ចៅក្រម នៃសាលាដំបូងខេត្តកំពង់ឆ្នាំង។

អញ្ជើញឈ្មោះ អត្តលេខ:៨១២ ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងឈ្មោះ តុប រតនា ។

ឱ្យចូលមកកាន់ សាលាដំបូងខេត្តកំពង់ឆ្នាំងបន្ទប់ចៅក្រមទី៨ នៅថ្ងៃទី..២៤......ខែសីហា ឆ្នាំ២០២០ វេលាម៉ោង...០៩... និង...៣០...នាទី ព្រឹក.....។

ដើម្បី: ចូលរួមក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

ពីដំណើររឿង: ប្តឹងសុំលែងលះប្តីឈ្មោះ មួង ហុក ។

សូមអញ្ជើញលោកមេធាវីមកកាន់សាលាដំបូង ឱ្យបានទាន់ពេលវេលាតាមកាលបរិច្ឆេទដូចបានកំណត់ខាងលើ ព្រមទាំងយកនូវឯកសារផ្សេងៗដែលពាក់ព័ន្ធក្នុងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ថ្ងៃចន្ទ ១៤កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ធ្វើនៅកំពង់ឆ្នាំង, ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០
**ចៅក្រម**

ឧបសម្ព័ន្ធទទី៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

សំណុំរឿងរដ្ឋប្បវេណីលេខៈ ១៣១
ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០

## ដីកាកោះ

យើង ក្រុមសាលាដំបូងខេត្តកំពង់ឆ្នាំង។

| | |
|---|---|
| -អញ្ជើញឈ្មោះ គុប រតនា ភេទស្រី អាយុ២៦ឆ្នាំ ជនជាតិខ្មែរ (ជាដើមចោទ)<br>-អាសយដ្ឋានបច្ចុប្បន្នភូមិអណ្តូងច្រុះ ឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ | |
| | សំណុំរឿងរដ្ឋប្បវេណីលេខលេខ ១៣១ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ ។<br>ដើមចោទឈ្មោះ គុប រតនា ភេទស្រី អាយុ២៦ឆ្នាំ ។ |
| កាលបរិច្ឆេទ និង ទីកន្លែងដែលត្រូវបង្ហាញខ្លួន | ថ្ងៃទី.២៤ ខែ.សីហា.. ឆ្នាំ២០២០ វេលាម៉ោង.៨:៣០..ព្រឹក......។<br>នៅបន្ទប់ចៅក្រម ទី៨ នៃសាលាដំបូងខេត្តកំពង់ឆ្នាំង ។ |
| ប្រភេទដំណាក់កាលនៃនីតិវិធី | ចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។ |
| អំពីដំណើររឿង | ប្តឹងសុំលែងលះប្តីឈ្មោះ មួង ហុក ។ |
| យកឯកសារផ្សេងៗភ្ជាប់មកជាមួយ ប្រសិនបើមាន | ឯកសារភស្តុតាងផ្សេងៗដែលពាក់ព័ន្ធ នៅក្នុងសំណុំរឿងនេះ ។ |
| ទណ្ឌកម្ម ជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួន ដោយគ្មានមូលហេតុត្រឹមត្រូវ | ចំពោះសាមីភាគី ៖ បើពុំចូលខ្លួននោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតទុកជាការពិតបាន តាមបញ្ញត្តិមាត្រា ១២០ កថាខណ្ឌទី២ និងមាត្រា ២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ |
| សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើ ។ | |

ថ្ងៃចន្ទ ១៤កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ធ្វើនៅកំពង់ឆ្នាំង, ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០
ចៅក្រម

បញ្ជាក់៖ -ក្នុងករណីមានជំងឺ ឬមានមូលហេតុផ្សេងទៀតមិនអាចបង្ហាញខ្លួនបាន សូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុនោះជូនតុលាការ។
-ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក។
-ទម្រង់នេះប្រើសម្រាប់ ភាគី សាក្សី អ្នកចូលរួមអន្តរាគមន៍ក្នុងបណ្តឹង។

ក្រឡាបញ្ជី សេង សាកល

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

សំណុំរឿងរដ្ឋប្បវេណីលេខ៖ ១៣១
ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០

# ដីកាកោះ

យើង ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង។

| | |
|---|---|
| -អញ្ជើញឈ្មោះ មួង ហុក ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ (ជាចុងចម្លើយ)<br>-អាសយដ្ឋានបច្ចុប្បន្នភូមិអណ្តូងច្រុះ ឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ | |
| | សំណុំរឿងរដ្ឋប្បវេណីលេខលេខ ១៣១ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ ។<br>ដើមចោទឈ្មោះ តុប រតនា ភេទស្រី អាយុ២៦ឆ្នាំ ។ |
| កាលបរិច្ឆេទ និង ទីកន្លែងដែលត្រូវ | ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង៨:៣០ ព្រឹក ។<br>នៅបន្ទប់ចៅក្រម ទី៨ នៃសាលាដំបូងខេត្តកំពង់ឆ្នាំង ។ |
| ប្រភេទដំណាក់កាលនៃនីតិវិធី | ចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។ |
| អំពីដំណើររឿង | ប្តឹងសុំលែងលះប្តីឈ្មោះ មួង ហុក ។ |
| យកឯកសារផ្សេងៗភ្ជាប់មកជាមួយ ប្រសិនបើមាន | ឯកសារភស្តុតាងផ្សេងៗដែលពាក់ព័ន្ធ នៅក្នុងសំណុំរឿងនេះ ។ |
| ទណ្ឌកម្ម ជាអាទិ៍ក្នុងករណីដែលមិនបានបង្ហាញខ្លួន ដោយគ្មានមូលហេតុត្រឹមត្រូវ | ចំពោះសាមីភាគី ៖ បើពុំចូលខ្លួនទេនោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតទុកជាការពិតបាន តាមបញ្ញត្តិមាត្រា ១៨០ កថាខណ្ឌទី២ និងមាត្រា ២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ |

សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើ ។

ថ្ងៃចន្ទ ១៤កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ធ្វើនៅកំពង់ឆ្នាំង, ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០
ចៅក្រម

បញ្ជាក់៖ -ក្នុងករណីមានជំងឺ ឬមានមូលហេតុផ្សេងទៀតមិនអាចបង្ហាញខ្លួនបាន សូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុនោះជូនតុលាការ។
-ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក។
-ទម្រង់នេះប្រើសម្រាប់ ភាគី សាក្សី អ្នកចូលរួមអន្តរាគមន៍ក្នុងបណ្តឹង។

Scanned with CamScanner

ឧបសម្ព័ន្ធទី៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

លេខ៧.៨៩០/[illegible]/២០២០

# ដីកាបញ្ជូន

ផ្ញើជូន លោកមេឃុំរលាប្អៀរ

| ល.រ | បញ្ជីរាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ០១ | ដីកាកោះឈ្មោះ | ០២ច្បាប់ | សូមលោកចាត់ប្រគល់ដីកានេះឱ្យបានដល់សាមីខ្លួនផ្ទាល់ ព្រមទាំងរួចបង្វិលសន្លឹកដើមមកដល់សាលាដំបូងវិញឱ្យបានមុនកាលកំណត់ចូលរបស់សាមីខ្លួន។ |
| | សរុប | ០២សន្លឹក | |

ថ្ងៃចន្ទ ១៤កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ខេត្តកំពង់ឆ្នាំង, ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០
ចៅក្រម

ឧបសម្ព័ន្ធទី៧

សាលាដំបូងខេត្តកំពង់ឆ្នាំង
ចូល លេខ 4789
ថ្ងៃទី 21.12.2020
បញ្ជូន [illegible]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំដកពាក្យបណ្ដឹង**

នាងខ្ញុំឈ្មោះ អាយុ៥២ឆ្នាំ ជនជាតិខ្មែរ ទីលំនៅភូមិកែវឡាត ឃុំពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ។

**សូមគោរពចូលមក**
**លោក ចៅក្រមនៃសាលាដំបូងខេត្តកំពង់ឆ្នាំង**

*សូមទានជ្រាប* ។

**កម្មវត្ថុ**:-សុំដកពាក្យសុំដកពាក្យបណ្ដឹងនៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: ២០១ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០២០ ។

**យោង**: សំណុំរឿងរដ្ឋប្បវេណីលេខ: ២០១ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ ។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមជម្រាបជូន **លោកចៅក្រម** មេត្តាជ្រាបថា: កាលពីថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០២០ នាងខ្ញុំបានដាក់ពាក្យបណ្ដឹង នៅសាលាដំបូងខេត្តកំពង់ឆ្នាំង សុំឲ្យឈ្មោះ ហ៊ិន ហ៊ាន និងឈ្មោះ គា ស្រីយ៉ា ប្រគល់ដីទំហំទទឹង២១ម៉ែត្រ គុណនឹងបណ្ដោយ៤០ម៉ែត្រ ស្ថិតនៅភូមិកែវឡាត ឃុំពន្លៃ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ហើយនៅពេលនេះ នាងខ្ញុំសុំដកពាក្យឈប់ប្ដឹងក្នុងសំណុំរឿង ខាងលើនេះបន្តទៀតហើយ ដោយមូលហេតុថាមានការភាន់ច្រឡំ ។

អាស្រ័យហេតុដូចបានជម្រាប និងរៀបរាប់ជូនដូចខាងលើ សូម **លោកចៅក្រម** មេត្តាអនុញ្ញាតឲ្យនាងខ្ញុំបានដកពាក្យបណ្ដឹងនេះដោយក្ដីអនុគ្រោះ ។

ក្រែងពុំប្រាកដនាងខ្ញុំ សូមផ្ដិតមេដៃទុកជាចំណាំស្រាប់ ។

ថ្ងៃចន្ទ ៧កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤
កំពង់ឆ្នាំង , ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០
ស្នាមមេដៃស្ដាំ

ឧបសម្ព័ន្ធទី៨

សាលាដំបូងខេត្តកំពង់ឆ្នាំង
ចូល
លេខ 1194
ថ្ងៃទី 28.04.2020
បញ្ជូន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្តឹង

-ដើមចោទឈ្មោះ ភេទស្រី កើតថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៩៨ ជាតិខ្មែរ របររកស៊ីកម្មការនី អាសយដ្ឋានភូមិអណ្តូងច្រុះ ឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ទូរស័ព្ទលេខ: ០៩៦ ៨៤៥ ០០៧៣ ។

-ចុងចម្លើយឈ្មោះ ភេទប្រុស កើតថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៣ ជាតិខ្មែរ របររកស៊ីមិនពិតប្រាកដ អាសយដ្ឋានភូមិអណ្តូងច្រុះ ឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ទូរស័ព្ទលេខ:០៩៦ ៦៤៧ ៧២០៩ ។

<u>សូមគោរពចូលមក</u>

លោក ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង

<u>*សូមទានជ្រាប*</u> ។

**១-ខ្លឹមសារសាលក្រមដែលទាមទារអោយតុលាការចេញ :**

- សុំលែងលះប្តី ។
- សុំគ្រប់គ្រងកូនប្រុសឈ្មោះ ជា បញ្ញា កើតថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ។
- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់នាងខ្ញុំ ។

**២-ការបញ្ជាក់ការទាមទារ:**

មូលហេតុដែលនាងខ្ញុំ សុំឱ្យតុលាការចេញសាលក្រមដូចខាងលើ ដោយសារតែនាងខ្ញុំនឹងឈ្មោះ មួង ហុក ជាប្តីប្រពន្ធនឹងគ្នា ។

**៣-អង្គហេតុដែលជាមូលហេតុនៃការទាមទារ :**

នាងខ្ញុំ និង ឈ្មោះ មួង ហុក បានរៀបអាពាហ៍ពិពាហ៍កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៦ និង បានចុះអាពាហ៍ពិពាហ៍កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ ។ ក្នុងចំណងប្តីប្រពន្ធនាងខ្ញុំមានកូនប្រុសមួយនាក់ឈ្មោះ ជា បញ្ញា កើតថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ពុំមានទ្រព្យសម្បត្តិរួម និង បំណុលដែលជំពាក់គេនោះទេ មូលហេតុដែលនាងខ្ញុំសុំលែងលះ ដោយសារតែប្តីប្រើប្រាស់គ្រឿងញៀន មិនគិតជួយរកស៊ីចិញ្ចឹមប្រពន្ធកូន ហេតុផលទាំងអស់នេះហើយ ធ្វើឱ្យនាងខ្ញុំអស់ទំនុកចិត្តលើប្តីទាំងស្រុង លែងមានមនោសញ្ចេតនាអាណិតស្រលាញ់គ្នា ជាប្តីប្រពន្ធ តទៅទៀតនាងខ្ញុំយល់ថាបើបន្តការរស់នៅជាប្តីប្រពន្ធនឹងគ្នា ក៏ពុំមានសុភមង្គលអ្វីដែរ ដូចនេះមានតែការចែកផ្លូវគ្នាដើររៀងៗខ្លួនទៅ ទើបជាការប្រសើរ ។

សេចក្តីដូចបានរៀបរាប់ និង ជម្រាបជូនខាងលើ សូមលោកប្រធានសាលាដំបូងខេត្តមេត្តាពិនិត្យ និង សម្រេចតាមការទាមទាររបស់នាងខ្ញុំដោយក្តីអនុគ្រោះ ។

ធ្វើនៅថ្ងៃអង្គារ៍ ០៧កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦២
កំពង់ឆ្នាំង, ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០

**ស្នាមមេដៃស្តាំ**



ឧបសម្ព័ន្ធទី៩

សាលាដំបូងខេត្តកំពង់ឆ្នាំង
ចូល
លេខ 1510
ថ្ងៃ 24-06-2019
ម៉ោង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំបញ្ចូលភស្តុតាង**

ខ្ញុំបាទឈ្មោះ [redacted] ភេទប្រុស អាយុ៣៣ឆ្នាំ និងប្រពន្ធឈ្មោះ **អ៊ិន សារ៉ាយ** ភេទស្រី អាយុ៣១ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិរល្ងងប្រេង ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

**គោរពជូនមក**

**លោក អ៊ី ម៉ាថរ: ចៅក្រមនៃសាលាដំបូងខេត្តកំពង់ឆ្នាំង**

**កម្មវត្ថុ:** សុំបញ្ចូលភស្តុតាងជាឯកសារចូលក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ១១១ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩។

តបតាមកម្មវត្ថុខាងលើខ្ញុំបាទនិងនាងខ្ញុំ សូមជម្រាបជូនលោកចៅក្រមឱ្យបានជ្រាបថានៅថ្ងៃទី០២ខែឧសភា ឆ្នាំ២០១៩ ឈ្មោះ ទូច សុផានី បានដាក់ពាក្យបណ្តឹងប្តឹងពួកខ្ញុំទាំងពីរនាក់ថាបានទៅកាន់កាប់ដីរបស់គាត់។

ខ្ញុំបាទ និងនាងខ្ញុំ សូមជម្រាបជូនលោកចៅក្រមឱ្យបានជ្រាបថា ការលើកឡើងរបស់ ទូច សុផានី ខាងលើមិនពិតនោះទេ ដោយដីទាំងនោះ ពួកខ្ញុំបាទបានកាន់កាប់តាំងពីឆ្នាំ១៩៨៤ មកម្លេះ ។

ដូចនេះខ្ញុំបាទ នាងខ្ញុំ សូមបញ្ចូលភស្តុតាងជាឯកសារ និងសាក្សីដឹងឮដូចខាងក្រោម៖

១-សៀវភៅគ្រួសារ ✓

២-សំបុត្របញ្ជាក់កំណើត✓

៣-សៀវភៅស្នាក់នៅ✓

៤-ប័ណ្ណក្បាលដីលេខ ២៣៦៨✓

៥-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ✓

៦-លិខិតរះអាង✓

៧-រូបថតភស្តុតាង ✓

៨-ចាន់ យ៉ម ភេទស្រី អាយុ៤៦ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិក្លែងពណ៌ ឃុំព្រៃមូល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

៩-អ៊ុយ ម៉ៅ ភេទប្រុស អាយុ៥៣ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិក្លែងពណ៌ ឃុំព្រៃមូល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

អាស្រ័យដូចបានជម្រាបខាងលើ សូមលោកចៅក្រមទទួលយកភស្តុតាងដាក់ចូលសំណុំរឿងដោយក្តីអនុគ្រោះ។

សូមលោកចៅក្រមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំទាំងពីរនាក់។

ធ្វើនៅថ្ងៃទី.២១....ខែមិថុនា ឆ្នាំ២០១៩

ហត្ថលេខាឬស្នាមមេដៃអ្នកស្នើសុំ

ប្តី ប្រពន្ធ

ឧបសម្ព័ន្ធទី១០

CS Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

សំណុំរឿងរដ្ឋប្បវេណីលេខ៖១៣១
ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០

**កំណត់ហេតុស្តីពី**
**នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

-សញ្ញាណនៃរឿងក្តី៖ សុំលែងលះប្តីឈ្មោះ មួង ហុក ។

-កាលបរិច្ឆេទ៖ ពីរពាន់ម្ភៃ ខែសីហា ថ្ងៃទីម្ភៃបួន វេលាម៉ោង ប្រាំបួន ព្រឹក។

-ទីកន្លែង៖ បន្ទប់ចៅក្រមទី៨ នៃសាលាដំបូងខេត្តកំពង់ឆ្នាំង។

**ដោយមានសមាសភាព**

លោក , ចៅក្រម នៃសាលាដំបូងខេត្តកំពង់ឆ្នាំង។

អមដោយលោក ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកំពង់ឆ្នាំង។

**ភាគីមាន÷**

-ភាគីដើមចោទឈ្មោះ តុប រតនា ភេទស្រី អាយុ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករសំណង់ ទីលំនៅសព្វថ្ងៃនៅភូមិអណ្តូងច្រុះ ឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

-ភាគីចុងចម្លើយឈ្មោះ មួង ហុក ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅភូមិអណ្តូងច្រុះ ឃុំរលាប្អៀរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

**១. ខ្លឹមសារ នៃសាលក្រមដែលដើមចោទបានទាមទារ៖**

-សុំលែងលះប្តីឈ្មោះ មួង ហុក ។

-សុំសិទ្ធិគ្រប់គ្រងកូនឈ្មោះ ជា បញ្ញា កើតនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨។

តុលាការបានព្យាយាមធ្វើការផ្សះផ្សាភាគី តែភាគីពុំព្រមសះជាតាមការផ្សះផ្សាឡើយ ហេតុដូច្នេះ តុលាការសម្រេចចាប់ផ្តើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដូចខាងក្រោម៖

**២. សេចក្តីថ្លែងការណ៍របស់ភាគី៖**

ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា៖នាងខ្ញុំ និងឈ្មោះ មួង ហុក បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាកាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៦ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ ហើយការរស់នៅជាមួយគ្នានេះប្តីប្រពន្ធនាងខ្ញុំមានកូនប្រុសម្នាក់ឈ្មោះ ជា បញ្ញា កើតនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨។ អំឡុងពេលរួមរស់នៅជាមួយគ្នាពួកយើងពុំមានទ្រព្យសម្បត្តិ និងបំណុលដែលជំពាក់គេនោះទេ ហើយមូលហេតុដែលនាងខ្ញុំសុំលែងលះ ដោយសារតែប្តីនាងខ្ញុំបានប្រើប្រាស់គ្រឿងញៀន ខ្ញុំបានដឹងថាគាត់ប្រើប្រាស់ថ្នាំញៀននៅឆ្នាំ២០១៨ មុនចុះសំបុត្រអាពាហ៍ពិពាហ៍ ហើយរស់នៅពុំចុះសម្រុងជាមួយគ្នា គាត់តែងតែដើរចោលខ្ញុំបាត់ពីរផ្ទះមួយ

Scanned with CamScanner

ចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្ញុំបាទសូមជម្រាប់លោកចៅក្រមថាកាលពីមុន ខ្ញុំបាទពិតជាធ្លាប់ប្រើប្រាស់គ្រឿងញៀនប្រាកដមែន ហើយខ្ញុំក៏ធ្លាប់ចុះចេញពីផ្ទះ ជួនកាលមួយយប់។ ខ្ញុំបានសម្រេចចិត្តច្បាស់ហើយថាខ្ញុំព្រមលែងលះពីប្រពន្ធរបស់ខ្ញុំបាទ។

ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា៖ នាងខ្ញុំសូមទាមទារគ្រប់គ្រងចិញ្ចឹមកូនប្រុសឈ្មោះ ជា បញ្ញា ដោយមិនទាមទារអាហារកិច្ចអ្វីឡើយ។

ចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្ញុំបាទក៏ព្រមប្រគល់កូនប្រុសឈ្មោះ ជា បញ្ញា កើតនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ ឲ្យទៅប្រពន្ធជាអ្នកគ្រប់គ្រងពុំមានជំទាស់អ្វីទេ។ ប៉ុន្តែ ខ្ញុំបាទសុំសិទ្ធិចូលជួបជាមួយកូនមួយខែពីរដងផងដែរ។

តុលាការបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅវេលាម៉ោង ០៩ ព្រឹក ថ្ងៃខែឆ្នាំដដែល។

| | | | | |
|---|---|---|---|---|
| ចុងចម្លើយ | ដើមចោទ | មេធាវីដើមចោទ | ក្រឡាបញ្ជី | ចៅក្រម |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

<u>សាលាដំបូងខេត្តកំពង់ឆ្នាំង</u>

# អំណាត់ហេតុស្តីពី
# នីតិវិធីត្រៀមសម្រាប់ទាញហេតុផល

សញ្ញាណរឿងលេខ: ១២៩ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង។

ចៅក្រមលោកស្រី ( ) ចៅក្រមសាលាដំបូងខេត្តកពង់ឆ្នាំង។

ក្រឡាបញ្ជីលោក ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំង។

កាលបរិច្ឆេទ: ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង០៩ និង ៣០ នាទី ។

ទីកន្លែង: សាលាដំបូងខេត្តកំពង់ឆ្នាំង ។

ភាគីបណ្តឹង:

ដើមចោទ: ធនាគារវឌ្ឍនៈអាស៊ីចំកាត់ សាខាខេត្តកំពង់ឆ្នាំង មានអាស័យដ្ឋានអាគារលេខE៦១៤ ផ្លូវជាតិលេខ៥ ភូមិស្រែព្រីង សង្កាត់កំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង តំណាងដោយលោក យាន ភក្ត្រា តួនាទីជាបុគ្គលិកផ្នែកនីតិកម្ម នៃធនាគារវឌ្ឍនៈ អាស៊ីចំកាត់ ដែលមានមេធាវី អ៊ាង សូសែង ជាមេធាវីតំណាងដោយអាណត្តិ។

សហចុងចម្លើយ: ឈ្មោះ ភេទប្រុស កើតថ្ងៃទី ០៧.១០.១៩៧០ សញ្ញាតិខ្មែរ ត្រូវជាប្តី និងប្រពន្ធឈ្មោះ មាន មុំ ភេទស្រី កើតថ្ងៃទី ០១.១១.៩៧៩ ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងបី សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង។

ខ្លឹមសារដែលស្នើសុំឲ្យសាលាដំបូងខេត្តកំពង់ឆ្នាំងចេញសាលក្រម:

១. បង្គាប់ឲ្យចុងចម្លើយសងប្រាក់មកដើមចោទនូវប្រាក់ដើមចំនួន USD ១០.៨០០,០០ (ដប់ពាន់ប្រាំបីរយដុល្លារអាមេរិកគត់) ។

២. បង្គាប់ឲ្យចុងចម្លើយសងមកដើមចោទនូវការប្រាក់ដើមចំនួន ១៤,៤០ % (ដប់បួនក្បៀសសែសិបភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន USD ១០.៨០០,០០ (ដប់ពាន់ប្រាំបីរយដុល្លារអាមេរិកគត់) គិតចាប់ពីថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

៣. បង្គាប់ឲ្យចុងចម្លើយសងមកដើមចោទនូវប្រាក់ពិន័យក្នុងអត្រាចំនួន ២៥ % (ម្ភៃប្រាំភាគរយ) ក្នុងមួយឆ្នាំនៃប្រាក់ដើមចំនួន USD ១០.៨០០,០០ (ដប់ពាន់ប្រាំបីរយដុល្លារអាមេរិកគត់) គិតចាប់ពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

៤. បង្គាប់ឲ្យចុងចម្លើយសងប្រាក់ថ្លៃសេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងការចំណាយផ្សេងៗ លើនីតិវិធីដែលមានចំនួនសរុប USD ២.០០០,០០ (ពីរពាន់ដុល្លារអាមេរិកគត់) ឲ្យមកដើមចោទ។

Scanned with CamScanner

៥. សុំឲ្យតុលាការប្រកាសថាសាលក្រមនេះមានអនុភាពអនុវត្តបណ្ដោះអាសន្ន។

ចៅក្រមៈ ថ្ងៃនេះ តុលាការបានដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (សាកសួរភាគី) ហើយតុលាការបានកោះហៅគូភាគីទាំងពីរនាក់ ហើយតុលាការបានទទួលរបាយការណ៍អំពីការបញ្ជូនរបស់គូភាគីរួចរាល់ហើយ ហេតុដូចនេះតុលាការអោយដើមបណ្ដឹងធ្វើសេចក្ដីថ្លែងការណ៍អំពីពាក្យសុំ។

ដើមចោទ: ខ្ញុំសូមថ្លែងការណ៍ដូចនៅក្នុងសេចក្ដីថ្លែងការណ៍សម្រាប់នីតិត្រៀមសម្រាប់ការទាញហេតុផលរបស់លោករមេធាវីចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៨។

តុលាការអនុញ្ញាតអោយភាគីចុងចម្លើយធ្វើសេចក្ដីថ្លែងការណ៍តប។

ចុងចម្លើយ: ចំពោះការទាមទារចំនុចទីមួយ ទីពីរ និងការទាមទារចំនុចទីបី ខ្ញុំទទួលស្គាល់ការទាមទារ។ ចំពោះការទាមទារចំនុចទីបួន ទាក់ទងនិងការទាមទារថ្លៃសេវាកម្មច្បាប់ ពេលវេលា និងការចំណាយផ្សេង ចំនួន USD ២.០០០,០០ (ពីរពាន់ដុល្លារអាមេរិកគត់) ខ្លួនមិនយល់ព្រមទេ ដោយមិនមានលទ្ធភាពសងឡើយ។ ដោយឡែកចំនុចដែលស្នើលសុំអោយសាលក្រមមានអនុភាពអនុវត្តបណ្ដោះអាសន្នបាន នោះខ្ញុំមិនព្រមទេ ដោយហេតុរឹបអូសផ្ទះខ្ញុំ តើបានកន្លែងណានៅ។

តុលាការបញ្ជាក់ពីការព្រមព្រៀង និងចំនុចវិវាទ:

ចំនុចព្រមព្រៀង: ភាគីដើមចោទ និងចុងចម្លើយ បានព្រមព្រៀងទៅលើចំណុចនៃការទាមទារនូវចំនុច

១. បង្គាប់ឲ្យចុងចម្លើយសងប្រាក់មកដើមចោទនូវប្រាក់ដើមចំនួន USD ១០.៨០០,០០ (ដប់ពាន់ប្រាំបីរយដុល្លារអាមេរិកគត់) ។

២. បង្គាប់ឲ្យចុងចម្លើយសងមកដើមចោទនូវការប្រាក់ដើមចំនួន ១៤,៤០ % (ដប់បួនក្បៀសសែសិបភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន USD ១០.៨០០,០០ (ដប់ពាន់ប្រាំបីរយដុល្លារអាមេរិកគត់) គិតចាប់ពីថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

៣. បង្គាប់ឲ្យចុងចម្លើយសងមកដើមចោទនូវប្រាក់ពិន័យក្នុងអត្រាចំនួន ២៥ % (ម្ភៃប្រាំភាគរយ) ក្នុងមួយឆ្នាំនៃប្រាក់ដើមចំនួន USD ១០.៨០០,០០ (ដប់ពាន់ប្រាំបីរយដុល្លារអាមេរិកគត់) គិតចាប់ពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

ចំនុចវិវាទ:

ភាគីចុងចម្លើយ មិនយល់ព្រមនិងការទាមទារទាក់ទងនឹងចំនុចទីបួន ទាក់ទងនិងការទាមទារថ្លៃសេវាកម្មច្បាប់ ពេលវេលា និងការចំណាយផ្សេង ចំនួន USD ២.០០០,០០ (ពីរពាន់ដុល្លារអាមេរិកគត់) ខ្លួនមិនយល់ព្រមទេ ដោយមិនមានលទ្ធភាពសងឡើយ។ និងចំនុចដែលស្នើសុំអោយសាលក្រមមានអនុភាពអនុវត្តបណ្ដោះអាសន្នបាន ។

ជាសំនួរថាតើចំនុចនៃការទារទាមលើថ្លៃសេវាកម្មច្បាប់ ពេលវេលា និងការចំណាយផ្សេង ចំនួន USD ២.០០០,០០ (ពីរពាន់ដុល្លារអាមេរិកគត់) វាមានភាពត្រឹមត្រូវទៅតាមផ្លូវច្បាប់ និងបំពានលើកិច្ចសន្យារបស់គូភា

Scanned with CamScanner

គឺដែលបានកំណត់លើប្រាក់ពិន័យ ២៥% ដែរឬទេ? ហើយការស្នើសុំអោយសាលក្រមមានអនុភាពអនុវត្តបណ្តោះអាសន្នបាន មានមូលដ្ឋានត្រឹមត្រូវតាមផ្លូវច្បាប់ឬទេ?

ដោយតុលាការឃើញថា និតិវិធីនៃការត្រៀមបានរកឃើញនៅចំនុចវិវាទ និងកំណត់អោយគូភាគីដាក់ភស្តុតានៅអោយបានមុនថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ និងកំណត់កាលបរិច្ឆេតទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ វាលាម៉ោង ពីរ និង សាមសិបនាទី ហើយតុលាករមិនធ្វើការកោះហៅទៀតទេដោយចាត់ទុកថាបានទទួលដំណឹងដំណឹងពីកាលបរិច្ឆេទនេះរួចរាល់ហើយ ។

បញ្ចប់កំណត់ហេតុនេះនៅថ្ងៃខែឆ្នាំ ដដែលខាងលើនេះ ។

**ដើមចោទ** **សហចុងចម្លើយ** **ក្រឡាបញ្ជី** **ចៅក្រម**





Scanned with CamScanner

ឧបសម្ព័ន្ធទី១១

# គន្ថីទី ១
# បទប្បញ្ញត្តិទូទៅ

## ជំពូកទី ១
## គោលបំណងនៃក្រមនីតិវិធីរដ្ឋប្បវេណី គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី ការទទួលខុសត្រូវរបស់តុលាការ និង គូភាគី

**មាត្រា ១.–** គោលបំណងនៃក្រមនីតិវិធីរដ្ឋប្បវេណី

នីតិវិធីដែលទាក់ទងទៅនឹងបណ្តឹងរដ្ឋប្បវេណី ត្រូវធ្វើតាមបញ្ញត្តិនៃក្រមនេះ លើកលែងតែក្នុងករណីដែលច្បាប់ផ្សេងបានកំណត់ពិសេស ។

**មាត្រា ២.–** គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី សិទ្ធិតឹងពាក់តុលាការ

១-បណ្តឹងរដ្ឋប្បវេណីមានគោលបំណងឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន ។

២-ជនគ្រប់រូបត្រូវបានធានានូវសិទ្ធិតឹងពាក់តុលាការចំពោះវិវាទរដ្ឋប្បវេណី ។

**មាត្រា ៣.–** សិទ្ធិទាមទារឱ្យសាកសួរ គោលការណ៍ចំពោះមុខ

១-ភាគីណាក៏មិនអាចត្រូវបានជម្រះក្តីដោយមិនបានសាកសួរ ឬ កោះហៅឡើយ ។

២-ក្នុងករណីណាក៏ដោយ តុលាការត្រូវគោរពគោលការណ៍ចំពោះមុខ ។

**មាត្រា ៤.–** ការទទួលខុសត្រូវរបស់តុលាការ និង ភាគី

តុលាការត្រូវប្រឹងប្រែង ដើម្បីកំប់រងបណ្តឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌និងឆាប់រហ័ស ឯភាគីត្រូវអនុវត្តបណ្តឹងរដ្ឋប្បវេណីដោយសុចរិតនិងស្មោះត្រង់ ។

**មាត្រា ៥.–** ភាសាដែលប្រើក្នុងតុលាការ សិទ្ធិរបស់ភាគីក្នុងការស្នើសុំឱ្យមានអ្នកបកប្រែ

១-នៅក្នុងតុលាការ ត្រូវប្រើភាសាខ្មែរ ។

២-ភាគីដែលមិនអាចយល់ភាសាខ្មែរ អាចស្នើសុំរកអ្នកបកប្រែភាសាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ហើយប្រសិនបើសាមីខ្លួនពុំមានលទ្ធភាពរកខ្លួនឯងបានទេ រដ្ឋ

ភាពចាំបាច់តម្រូវឱ្យធ្វើការទាមទារនោះជាមុន ។

**មាត្រា ៧៧.–** ការបញ្ចូលការទាមទារច្រើនចំណុចទៅក្នុងបណ្ដឹងតែមួយ

ការទាមទារច្រើនចំណុច អាចយកមកបញ្ចូលក្នុងបណ្ដឹងតែមួយបាន លុះត្រាតែបណ្ដឹងនោះដោះស្រាយដោយនីតិវិធីប្រភេទដូចគ្នា ។

**មាត្រា ៧៨.–** ការពិនិត្យពាក្យបណ្ដឹង

១-ក្នុងករណីដែលពាក្យបណ្ដឹងផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៧៥ (របៀបដាក់ពាក្យបណ្ដឹង និង ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង) ខាងលើនេះ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះ ចំពោះពាក្យបណ្ដឹងនោះ ក្នុងអំឡុងពេលនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលពន្ធសម្រាប់ដាក់ពាក្យបណ្ដឹង មិនត្រូវបានបង់តាមបញ្ញត្តិនៃមាត្រា៦១ (ពន្ធដាក់ពាក្យសុំ) នៃក្រមនេះ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើដើមចោទមិនបានកែតម្រូវចំណុចខ្វះទេ តុលាការត្រូវលើកពាក្យបណ្ដឹងចោល ដោយដីកាសម្រេច ។

៣-ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

**មាត្រា ៧៩.–** ការបញ្ជូនពាក្យបណ្ដឹង

១-ពាក្យបណ្ដឹងត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់ ។

២-បញ្ញត្តិនៃមាត្រា ៧៨ (ការពិនិត្យពាក្យបណ្ដឹង) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលពាក្យបណ្ដឹងមិនអាចបញ្ជូនទៅបាន ។ បញ្ញត្តិនោះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលដើមចោទមិនបានបង់ប្រាក់សម្រាប់បញ្ជូនពាក្យបណ្ដឹងទុកជាមុន ។

**មាត្រា ៨០.–** ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង

១-នៅពេលដែលពាក្យបណ្ដឹងត្រូវបានដាក់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលយ៉ាងរហ័ស និង កោះហៅគូភាគី ។

២-កាលបរិច្ឆេទដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្ដឹងត្រូវបានដាក់ លើកលែងតែក្នុងករណីដែលមានមូលហេតុពិសេស ។

**មាត្រា ៨១.–** ការលើកបណ្ដឹងចោល ដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់

ក្នុងករណីដែលបណ្ដឹងមានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបានទេ តុលាការអាចលើកបណ្ដឹងនោះចោល ដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន ។

**មាត្រា ៨២.–** ការលើកបណ្ដឹងចោលក្នុងករណីដែលមិនបានបង់ជាមុននូវប្រាក់សម្រាប់ធ្វើការកោះហៅ

១-ក្នុងករណីដែលតុលាការបានបង្គាប់ឱ្យដើមចោទបង់ជាមុននូវប្រាក់ ដែលជាចាំបាច់សម្រាប់កោះហៅភាគីឱ្យចូលមកនៅកាលបរិច្ឆេទតាមបញ្ញត្តិនៃក្រមនេះ ដោយកំណត់អំឡុងពេលសមរម្យ តែដើមចោទមិនបានបង់ប្រាក់នោះជាមុនទេ តុលាការអាចលើកចោលបណ្ដឹងដោយដីកាសម្រេចបាន លុះត្រាតែចុងចម្លើយគ្មានការតវ៉ា ។

២-ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

**មាត្រា ៨៣.–** ការហាមបណ្ដឹងជាន់គ្នា

ចំពោះរឿងក្ដីដែលតុលាការកំពុងចាត់ការ ភាគីមិនអាចប្ដឹងទៀតបានឡើយ ។

**មាត្រា ៨៤.–** ការបន្ថែម ឬ ការផ្លាស់ប្ដូរនូវកម្មវត្ថុនៃបណ្ដឹង

១-ដើមចោទអាចបន្ថែម ឬ ផ្លាស់ប្ដូរនូវកម្មវត្ថុនៃបណ្ដឹង រហូតដល់ពេលចប់ការទាញហេតុផលដោយផ្ទាល់មាត់បាន លុះត្រាតែមិនមានការប្ដូរមូលដ្ឋាននៃការទាមទារ ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលធ្វើឱ្យនីតិវិធីនៃបណ្ដឹងមានការយឺតយ៉ាវខ្លាំងដោយសារការបន្ថែម ឬ ការផ្លាស់ប្ដូរនោះ ។

២-ការបន្ថែម ឬ ការផ្លាស់ប្ដូរនូវកម្មវត្ថុនៃបណ្ដឹង ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ។

ហេតុផល និង ត្រូវដឹកនាំចាត់ចែងការទាញហេតុផលដោយផ្ទាល់មាត់ ។

២-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអនុញ្ញាតឱ្យជនណាម្នាក់និយាយបាន និង អាចហាមជនដែលមិនស្ដាប់បញ្ជារបស់ខ្លួនមិនឱ្យនិយាយបាន ។

**មាត្រា ៩០.–** សិទ្ធិឱ្យបំភ្លឺ ជាអាទិ៍

១-ដើម្បីឱ្យចំណុចនៃអង្គហេតុ និង អង្គច្បាប់ដែលទាក់ទងនឹងបណ្ដឹង មានភាពច្បាស់លាស់ តុលាការអាចសាកសួរភាគី ឬ ឱ្យភាគីអះអាង ឬ បញ្ជាក់ភស្តុតាង ចំពោះចំណុចនោះ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់បាន ។

២-ភាគីអាចទាមទារឱ្យតុលាការសួរសំណួរចាំបាច់ទៅភាគីម្ខាងទៀត នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់បាន ។

៣-នៅក្រៅពីកាលបរិច្ឆេទ តុលាការអាចបង្គាប់ឱ្យភាគីត្រៀមខ្លួននឹងរៀបចំការឆ្លើយបំភ្លឺ នៅកាលបរិច្ឆេទបន្ទាប់ ដោយបញ្ជាក់ចំណុចដែលតុលាការយល់ឃើញថា ត្រូវការឱ្យបំភ្លឺជាចាំបាច់ ។

**មាត្រា ៩១.–** បណ្ដឹងតវ៉ាចំពោះការដឹកនាំនីតិវិធីបណ្ដឹង

ក្នុងករណីដែលភាគីបានធ្វើបណ្ដឹងតវ៉ា ចំពោះការដឹកនាំការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់ ឬ ចំពោះការចាត់ចែងរបស់តុលាការ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៩០ (សិទ្ធិឱ្យបំភ្លឺ ជាអាទិ៍) ខាងលើនេះ តុលាការត្រូវសម្រេចសេចក្ដី ចំពោះបណ្ដឹងតវ៉ានោះ ដោយដីកាសម្រេច ។

**មាត្រា ៩២.–** ករណីយកិច្ចស្រាវជ្រាវរបស់ភាគី

ភាគីត្រូវធ្វើការស្រាវជ្រាវឱ្យបានលំអិតជាមុន នូវទំនាក់ទំនងនៃអង្គហេតុចំពោះសាក្សី និង ភស្តុតាងផ្សេងៗ ដើម្បីធ្វើការអះអាង និង បញ្ជាក់ឱ្យបានគ្រប់គ្រាន់ច្បាស់លាស់ក្នុងបណ្ដឹង ។

**មាត្រា ៩៣.–** ពេលដែលត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន

មធ្យោបាយតទល់ ឬ ការពារខ្លួន ត្រូវដាក់ឱ្យតុលាការនៅពេលណាមួយដែលសម-

**មាត្រា ៩៣.-** ពេលដែលត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួន

មធ្យោបាយតទល់ ឬ ការពារខ្លួន ត្រូវដាក់ឱ្យតុលាការនៅពេលណាមួយដែលសម-



រម្យ ទៅតាមដំណើរការនៃបណ្តឹង ។

**មាត្រា ៩៤.-** ការលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ

១-ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់ទៅតុលាការយឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ ដោយចេតនា ឬ ដោយកំហុសដ៏ធ្ងន់ធ្ងររបស់ភាគី តុលាការអាចចេញដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនបាន តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រសិនបើតុលាការយល់ឃើញថា ការដាក់មធ្យោបាយនោះ ធ្វើឱ្យមានការយឺតយ៉ាវក្នុងការបញ្ចប់នីតិវិធីនៃបណ្តឹង ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដែរ ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនដែលមានអត្ថន័យមិនច្បាស់លាស់ ក្នុងករណីដែលភាគីមិនបានធ្វើការបំភ្លឺចាំបាច់ ឬ មិនបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកោះហៅឱ្យមកបំភ្លឺទេ ។

**មាត្រា ៩៥.-** អង្គហេតុដែលអាចយកមកធ្វើជាមូលដ្ឋាននៃសាលក្រម

តុលាការមិនអាចយកអង្គហេតុណា ដែលភាគីណាមួយមិនបានអះអាង មកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ ។

**មាត្រា ៩៦.-** ការចាត់ទុកថាបានសារភាព

១-ក្នុងករណីដែលភាគីមិនបានបង្ហាញច្បាស់លាស់ នូវឆន្ទៈតវ៉ាអំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផលដោយផ្ទាល់មាត់ទេ ភាគីនោះត្រូវបានចាត់ទុកថា បានសារភាពអំពីអង្គហេតុនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតុលាការគិតពិចារណាអំពីដំណើរការ និង ខ្លឹមសារនៃរឿងក្តី ហើយយល់ឃើញថា ភាគីនោះបានតវ៉ាអំពីអង្គហេតុ ។

២-ក្នុងករណីដែលភាគីធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនមិនដឹងអំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង ភាគីនោះ ត្រូវបានសន្មតថា បានតវ៉ាអំពីអង្គហេតុនោះ ។

**មាត្រា ៩៧.-** ការសាកល្បងធ្វើការផ្សះផ្សា

តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ទោះបីជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាល

ណាក៏ដោយ ។

**មាត្រា ៩៨.–** ការបាត់បង់នូវសិទ្ធិប្ដឹងតវ៉ាស្ដីអំពីនីតិវិធីនៃបណ្ដឹង

១-ក្នុងករណីដែលភាគីម្ខាង ឬ តុលាការ បានធ្វើសកម្មភាពបណ្ដឹងណាមួយដែលផ្ទុយពីបញ្ញត្តិអំពីនីតិវិធីនៃបណ្ដឹង ភាគីអាចប្ដឹងតវ៉ាចំពោះសកម្មភាពនោះទៅតុលាការ ហើយអាចអះអាងអំពីមោឃភាពនៃសកម្មភាពនោះបាន ។

២-ក្នុងករណីដែលភាគីដឹង ឬ អាចដឹងអំពីភាពខុសច្បាប់ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ហើយមិនបានធ្វើការប្ដឹងតវ៉ានៅពេលសមរម្យទេ ភាគីនោះត្រូវបាត់បង់សិទ្ធិប្ដឹងតវ៉ានេះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមិនអាចបោះបង់សិទ្ធិនេះបាន ។

**មាត្រា ៩៩.–** ការបំបែក និង ការរួមបញ្ចូលរឿងក្ដី

១-តុលាការអាចបង្គាប់ឱ្យបំបែក ឬ បញ្ចូលរឿងក្ដី ដោយដីកាសម្រេច ឬ អាចលុបចោលដីកាសម្រេចនោះបាន ។

២-ក្នុងករណីតុលាការ បានបង្គាប់ឱ្យបញ្ចូលរឿងក្ដីដែលមានភាគីខុសគ្នា នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅពេលភាគីដែលមិនមាននិកាសសាកសួរសាក្សី ដោយសារសាក្សីនោះត្រូវបានសាកសួររួចហើយមុនពេលបញ្ចូលរឿងក្ដី បានដាក់ពាក្យសុំសាកសួរសាក្សីនោះ តុលាការត្រូវសាកសួរសាក្សីនោះ ។

**មាត្រា ១០០.–** ការចូលរួមរបស់អ្នកបកប្រែ ជាអាទិ៍

១-ប្រសិនបើជនដែលទាក់ទងនឹងនីតិវិធីវេហ្យវេណី មិនអាចយល់ភាសាខ្មែរ ឬ ថ្លង់ ឬ គ តុលាការត្រូវឱ្យមានអ្នកបកប្រែដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ចូលរួមជាមួយនឹងជននោះ ។ ប៉ុន្តែ តុលាការអាចសួរជនដែលថ្លង់ ជាអក្សរ ឬ ឱ្យជនដែលគ ធ្វើសេចក្ដីថ្លែងការណ៍ ជាអក្សរបាន ។

២-បញ្ញត្តិស្ដីពីអ្នកធ្វើកោសលវិច័យនៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកបកប្រែ លើកលែងតែមានភាពផ្ទុយនឹងលក្ខណៈនោះ ។

## ផ្នែកទី ២
## ឯកសារត្រៀម

**មាត្រា ១០១.–** ឯកសារត្រៀម

១-នៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀមបាន ។

២-នៅក្នុងឯកសារត្រៀម ត្រូវមានសរសេរអំពីមធ្យោបាយតទល់ ឬ ការពារខ្លួន និង សេចក្តីថ្លែងការណ៍ ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនរបស់ភាគីម្ខាងទៀត ។

៣-នៅក្នុងឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង ត្រូវមានសរសេរអំពីការឆ្លើយតប ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរទាមទារនៅក្នុងពាក្យបណ្តឹង និង ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង និង អង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង ជាអាទិ៍ ។

**មាត្រា ១០២.–** ពេលវេលាដែលត្រូវដាក់ឯកសារត្រៀម ជាអាទិ៍

តុលាការអាចកំណត់អំឡុងពេលដែលត្រូវដាក់ឯកសារត្រៀមលើកដំបូងរបស់ចុងចម្លើយ ឬ ឯកសារត្រៀមដែលមានសរសេរអំពីការអះអាងចំពោះចំណុចជាក់លាក់ណាមួយ ឬ ត្រូវធ្វើការស្នើសុំឱ្យពិនិត្យភស្តុតាងដែលទាក់ទងនឹងចំណុចជាក់លាក់ណាមួយ ។

## ផ្នែកទី ៣
## នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

**មាត្រា ១០៣.–** គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំនូវសេចក្តីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីយល់មិនស្របគ្នា និង រៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យ បានល្អិតល្អន់ ។

**មាត្រា ១០៤.–** ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសាកល្បងផ្សះផ្សាជាដំបូងសិន លើកលែងតែយល់ឃើញថាមិនសមរម្យ ។

**មាត្រា ១០៥.–** កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

១-នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចចូលរួមបាន ។

២-កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនចាំបាច់បើកជាសាធារណៈទេ ។ ប៉ុន្តែ តុលាការអាចអនុញ្ញាតឱ្យអ្នកដែលតុលាការយល់ឃើញថាសមរម្យចូលស្ដាប់ជាអ្នកសង្កេតការណ៍បាន ។

**មាត្រា ១០៦.–** សកម្មភាពនៃបណ្ដឹង ជាអាទិ៍ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការអាចចេញដីកាសម្រេចដែលទាក់ទងនឹងការស្នើសុំឱ្យពិនិត្យភស្តុតាង ឬ ដីកាសម្រេចផ្សេងទៀតដែលអាចសម្រេចបាន ក្រៅពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ និង អាចពិនិត្យភស្តុតាងជាឯកសារ ដោយមានកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្ដី និង ភស្តុតាង ។

**មាត្រា ១០៧.–** ការបញ្ជាក់អំពីអង្គហេតុដែលនឹងត្រូវបំភ្លឺ ជាអាទិ៍

នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់ការរៀបចំចំណុចវិវាទនៃរឿងក្ដី និង ភស្តុតាងហើយ នោះតុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគីនូវអង្គហេតុដែលនឹងត្រូវបំភ្លឺនៅពេលពិនិត្យភស្តុតាងនៅពេលក្រោយ ។

**មាត្រា ១០៨.–** អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ក្រោយពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬ ការការពារខ្លួនថ្មីបានទៀតទេ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមធ្យោបាយនោះ ទាក់ទងនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឥន្ទានុសិទ្ធិរបស់ខ្លួន ឬ ករណីដែលការដាក់មធ្យោបាយថ្មីនោះ មិនធ្វើឱ្យមានការយឺត

យកវិវេលនីតិវិធីនៃបណ្តឹង ឬ ករណីដែលភាគីបានធ្វើសេចក្តីបញ្ជាក់ដំបូងថា ខ្លួនមិនអាចដាក់មធ្យោបាយនោះ មុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយគ្មានកំហុសធ្ងន់ធ្ងរឡើយ ។

**មាត្រា ១០៩.–** កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

តុលាការត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៅគ្រប់កាលបរិច្ឆេទនីមួយៗ ។

**មាត្រា ១១០.–** ចំណុចជាបួបមន្តនៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

១-នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវចំណុចខាងក្រោមនេះ :

ក-សញ្ញាណរឿងក្តី ។

ខ-ឈ្មោះចៅក្រម និង ក្រឡាបញ្ជី ។

គ-ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និង អ្នកបកប្រែដែលបានបង្ហាញខ្លួន ។

ឃ-ពេលវេលា និង ទីកន្លែង ។

២-ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និង ក្រឡាបញ្ជី ត្រូវចុះហត្ថលេខាលើកំណត់ហេតុដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១១១.–** ចំណុចសារធាតុនៃកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវសេចក្តីសង្ខេបអំពីសកម្មភាពដែលបានធ្វើឡើងនៅកាលបរិច្ឆេទនីមួយៗ ហើយជាពិសេស ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នូវចំណុចខាងក្រោមនេះ :

ក-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និង ចម្លើយតបរបស់ចុងចម្លើយចំពោះការទាមទារនោះ ។

ខ-ខ្លឹមសារនៃអង្គហេតុដែលបានអះអាង និង ការស្នើសុំឱ្យពិនិត្យភស្តុតាង ។

គ-ការទទួលស្គាល់ ឬ មិនទទួលស្គាល់របស់ភាគី ចំពោះអង្គហេតុដែលបានអះអាងដោយភាគីម្ខាងទៀត និង ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះភាពត្រឹមត្រូវ

នៃឯកសារ ។

ឃ-ការដកពាក្យបណ្ដឹង ការផ្សះផ្សា ការលះបង់ការទាមទារ និង ការទទួលស្គាល់ការទាមទារ ។

ង-ចំណុចដែលតុលាការបានបង្គាប់ឱ្យកត់ត្រា និង ចំណុចដែលតុលាការអនុញ្ញាតឱ្យកត់ត្រា តាមការទាមទាររបស់ភាគី ។

ច-ការសម្រេចសេចក្ដីដែលបានធ្វើឡើងនៅកាលបរិច្ឆេទនោះ ដោយមិនធ្វើជាលាយលក្ខណ៍អក្សរ ។

**មាត្រា ១១២.–** ការប្ដឹងតវ៉ាចំពោះសេចក្ដីកត់ត្រានៃកំណត់ហេតុ ស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាអាទិ៍

១-ក្នុងករណីដែលភាគី ឬ អ្នកដទៃទៀតដែលពាក់ព័ន្ធ ប្ដឹងតវ៉ាចំពោះសេចក្ដីកត់ត្រានៅក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះ ត្រូវកត់សេចក្ដីប្ដឹងតវ៉ានេះ នៅក្នុងកំណត់ហេតុនោះ ។

២-ភាពត្រឹមត្រូវក្នុងការអនុវត្តតាមបញ្ញត្តិទាក់ទងនឹងរបៀបធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចបញ្ជាក់បាន ដោយកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតែប៉ុណ្ណោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកំណត់ហេតុនេះបានបាត់ ឬ បានវិនាស ។

## ផ្នែកទី ៤

## ការទាញហេតុផលដោយផ្ទាល់មាត់

**មាត្រា ១១៣.–** ការកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីមកចូលរួម ។